# ពុទ្ធប្បវត្តិកថាសង្ខេប



រៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

**ភិក្ខុ ធម្មប្បញ្ញោ គង់ សុភាព**

# ពុទ្ធប្បវត្តិកថាសង្ខេប



រៀបរៀងដោយ: ភិក្ខុមិតប្បញ្ញោ គង់ សុភាព

ថ្ងៃ ១៥ កើត ខែ ស្រាពណ៍ ឆ្នាំ ម្សាញ់ បញ្ចស័ក

ព.ស. ២៥៥៧ / គ.ស. ២០១៣

# ព្រះអធិបតីគាំទ្រក្នុងការបោះពុម្ពសៀវភៅ



## ព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ

ព្រះរាជាគណៈថ្នាក់ទោគណៈមហានិកាយ និងជាឧត្តមជីប្រឹក្សា

គណសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា



ព្រះសុមង្គលសីលាចារ្យ ឥន្ទកេសរោ ពេជ្យ សន

ព្រះមេគណខេត្តសៀមរាប



ព្រះអានាភរោ ជុំ គឹម ឡេង

ចាល័ង្គកណាខេត្តសៀមរាប



ព្រះគេសចណ្ណោ តង់ គន

ជម្ទជរខេត្តសៀមរាប

## អ្នកមានឧបការៈត្រួតពិនិត្យ និងកែសម្រួល



## ភិក្ខុខេមភិរតោ ស៊ាន ជា សែន

គ្រូឧត្តមសាចារ្យបង្រៀនបាលី



## ភិក្ខុឋានចារោ អ៊ាត ប៊ុន រដ្ឋ ( បញ្ញាវន្ត )



ភិក្ខុអគ្គញ្ញាណោ មុត សំបូរ
សមណៈសិស្សពុទ្ធិកាវិទ្យាល័យ



ភិក្ខុមតិធរោ យឹម សាមុត (សមណៈនិស្សិត)

ភិក្ខុខន្តិបរមោ ភោគ កង (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

ភិក្ខុព្រហ្មសុវណ្ណោ ម៉ែន ចំរើន (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

ភិក្ខុជុតិបញ្ញោ ចន ច៉ា (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

លោកម្ចាស់សាំ ហេង (ឧទ្ទេសាចារ្យបង្រៀនបាលី)

ភិក្ខុធរោ ឡុម ធូលី (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

ភិក្ខុថេរោធម្មោ ថាំង ស្រេង (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

លោកម្ចាស់ ឡាយ ពេជ្រ វណ្ណា (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

លោកម្ចាស់គ្រូ សុមនោ ហេង ប៊ុនជា (គ្រូធម្មាចារ្យ)

ភិក្ខុបញ្ញាបជ្ជោតោ យេង សុភស្ត្រ(សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

លោកម្ចាស់ កល្យាណធម្មោ ម៉ន សាមឿន (ធម្មពិធីករ)

លោកម្ចាស់ ហួត ធី (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

លោកម្ចាស់ ស៊ី សំណាង (លេខាអនុគណស្រុកស្វាយលើ)

ភិក្ខុសច្ចមុនី រី រ៉េន (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

លោកម្ចាស់ព្រឿន ព្រីម (សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌)

## ផ្នែកបច្ចេកទេស

ភិក្ខុសោត សំវរោ ស៊ាន រីណា (សមណៈសិស្សពុទ្ធិកវិទ្យាល័យ)

លោកម្ចាស់ កែន ប្រុស (សមណៈសិស្សពុទ្ធិកវិទ្យាល័យ)

លោកម្ចាស់ យ៉ាត យស (សមណៈសិស្សពុទ្ធិកវិទ្យាល័យ)

# អារម្ភកថា

រឿងពុទ្ធប្បវត្តិ ដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដក ជាសេចក្ដីខ្លី ៗ ធ្លុះដោយដុំ ៗ ដោយអន្លើ ៗ ក្នុងអដ្ឋកថាទើបឃើញមានសេចក្ដីពិស្ដារ, ប៉ុន្ដែក៏មិនជាហូរហែប៉ុន្មានដែរ ។ ក្នុងជំនាន់ខាងក្រោយមក ព្រះគន្ថរចនាចារ្យទាំងឡាយ បានតែងបករណវិសេសជាច្រើនយ៉ាង ដូចគម្ពីរបឋមសម្ពោធិជាដើម នោះទើបមានសេចក្ដីពិស្ដារទាក់ទងគ្នាល្អ ។ តមកទៀតពួកអ្នកប្រាជ្ញជាន់ដើម បានបង្រួញសេចក្ដីនៃរឿងឲ្យខ្លី ៗ ហៅថារឿងពុទ្ធប្បវត្តិ ។ ពាក្យថា " **ពុទ្ធប្បវត្តិ** " នេះស្រូបសេចក្ដីវែងឆ្ងាយណាស់គឺដំណាលពីរឿងរបស់ព្រះពុទ្ធជាម្ចាស់ នៃយើងតាំងពីចាប់កសាងបារមី ដរាបដល់បានត្រាស់ រហូតដល់បរិនិព្វាន ។ ប៉ុន្ដែបច្ចុប្បន្ននេះ សៀវភៅពុទ្ធប្បវត្តិសង្ខេបខ្លះ ខុសសេចក្ដីខ្លះ ៗ អំពីគម្ពីរព្រះត្រៃបិដក និងអដ្ឋកថាធ្វើឲ្យអ្នកសិក្សាជំនាន់ក្រោយ យល់ច្រឡំក្នុងរឿងនេះ ដូចជាច្រឡំថា " ព្រះអង្គប្រសូតពីឆ្អឹងជំនីរ ជាដើម " ។ ព្រោះហេតុនេះ ទើបខ្ញុំព្រះករុណាអាត្មាភាព ព្យាយាមរៀបចំនូវសៀវភៅ ពុទ្ធប្បវត្តិកថាសង្ខេប នេះសាជាថ្មីម្ដងទៀត ដោយ

ស្រាវជ្រាវយកសៀវភៅ ពុទ្ធប្បវត្តិសង្ខេប ដែលរៀបរៀងដោយបណ្ឌិតអ្នកប្រាជ្ញជំនាន់ដើម ដែលបោះពុម្ពផ្សព្វផ្សាយដោយពុទ្ធសាសនាបណ្ឌិត្យ យកមកធៀបជាមួយគម្ពីរព្រះត្រៃបិដក មានព្រះវិន័យខ្លះ ព្រះសូត្រខ្លះ, ព្រមទាំងអដ្ឋកថា និង បករណវិសេសឯទៀតខ្លះ ដែលសម្តែងពីរឿងនេះ យកមកធៀបគ្នាបំផ្លើញសេចក្តីឲ្យខ្លី ហើយរៀបរៀងសាជាថ្មីដាក់ឈ្មោះថា " **ពុទ្ធប្បវត្តិកថាសង្ខេប** " ព្រមទាំងដាក់បញ្ចូលរូបភាព ដើម្បីឲ្យអ្នកសិក្សាខាងក្រោយងាយស្រួល នឹងចំណាំចាប់បាន នូវរឿងរបស់ព្រះពុទ្ធជាអង្គម្ចាស់នៃយើងនេះ ។

## ឧទ្ទិសកថា

ដោយអានុភាព នៃសេចក្តីព្យាយាម រៀបរៀងនូវសៀវភៅពុទ្ធប្បវត្តិកថាសង្ខេបនេះ ខ្ញុំព្រះករុណាអាត្មាភាព សូមឧទ្ទិសថ្វាយនូវព្រះរាជកុសលនេះ ដល់អតីតសម្តេចព្រះសង្ឃរាជ សម្តេចសង្ឃនាយក ព្រះរាជាគណៈ ព្រមទាំងវីរៈសមណៈ គ្រប់ព្រះអង្គ និង អតីតព្រះមហាក្សត្រ ព្រះមហាវីរៈក្សត្រ ជាពិសេស សូមឧទ្ទិសថ្វាយព្រះរាជកុសលនេះចំពោះ **អតីតព្រះមហាក្សត្រគឺៈ**

ព្រះករុណា ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតា ឯករាជ្យជាតិបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រមទាំងជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ដែលទ្រង់បានយាងទិវង្គតទៅហើយនៅក្នុងថ្ងៃ១៥កើត ខែកត្តិក ឆ្នាំ រោង ចត្វាស័ក.ព.ស.២៥៥៦ វេលាម៉ោង ១:២០ នាទី រំលង អាធ្រាត្រនោះ សូមឲ្យព្រះអង្គបានយាងទៅសោយសុខ ក្នុងសុគតិភពចុះ ។ ជាពិសេសសូមថ្វាយព្រះរាជកុសលនេះ ចំពោះសម្តេចព្រះសង្ឃរាជ សម្តេចសង្ឃនាយក ព្រះរាជាគណៈគ្រប់ឋានានុក្រម ជាពិសេសទៅទៀត សូមថ្វាយព្រះរាជកុសលនេះដល់ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សូមទ្រង់មានព្រះកាយពលមាំមួន ព្រះសុខភាពល្អ ព្រះប្រាជ្ញាញាណឈ្លាសវៃ ព្រះជន្មយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ ដល់ប្រជានុរាស្ត្រទាំងឡាយ និង សូមជូននូវបុណ្យកុសលនេះ ចំពោះរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីរាជការ គ្រប់-

លំដាប់ថ្នាក់ សូមបានសេចក្តីសុខ ដោគជ័យសម្រេចរាល់ភារៈកិច្ចទាំងឡាយទាំងពួង ។

ម្យ៉ាងទៀត សូមឲ្យអ្នកនៅក្នុងដែនកម្ពុជរដ្ឋ និង លោកអ្នកដែលបានអាន និង សិក្សានូវសៀវភៅនេះ សូមបានសេចក្តីសុខ ដល់នូវការលូតលាស់ចម្រើន និង សន្តិភាព ហើយជាពិសេសសូមបានជាឧបនិស្ស័យ មានបញ្ញារួចផុតចាកទុក្ខ ក្នុងអនាគតជាតិកុំបីឃ្លាងឃ្លាតឡើយ ។ សូមឲ្យព្រះពុទ្ធសាសនា រុងរឿងចម្រើន សូមព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព អស់កាលជាអង្វែងទៅហោង ។

# ជីវៈប្រវត្តិសង្ខេប



ភិក្ខុបិតប្បញ្ញោ គង់ សុភាព

**ភិក្ខុបិតបញ្ញោ គង់ សុភាព** ប្រសូតនៅថ្ងៃពុធ ១៥ កើត ខែស្រាពណ៍ ឆ្នាំកុរ ព.ស.២៥២៦ នៅក្នុងជំរុំណងចាន់ ព្រំដែនខ្មែរ / ថៃ ។

ញោមប្រុស ឈ្មោះ **គង់ ជា** ញោមស្រីឈ្មោះ **សន រ៉ន**

-**ភិក្ខុគង់ សុភាព** ជាកូនទី៣ ក្នុងគ្រួសារ ចំណោមបងប្អូន ៨ នាក់ គឺ:

-បងស្រីទី ១ ឈ្មោះ **គង់ រ៉ា** -បងស្រីទី២ ឈ្មោះ **គង់ រ៉េត**

-ប្អូនប្រុសទី៤ឈ្មោះ**គង់ គឿន** -ប្អូនស្រីទី៥ ឈ្មោះ **គង់ រិទ្ធី**

-ប្អូងស្រីទី ៦ ឈ្មោះ **គង់ រី** -ប្អូនស្រីទី ៧ ឈ្មោះ **គង់ រ៉ាម**

-ប្អូនប្រុសទី៨ ឈ្មោះ **គង់ សុភា** ។

❖បានចូលសាងបព្វជ្ជា ជាសាមណេរ នៅក្នុងថ្ងៃអង្គារ ៨ រោច ខែ ចេត្រ ឆ្នាំម្សាញ់ បញ្ចស័ក **ព.ស.២៥៤៤** ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០២ ហើយឧបសម្បទាជាភិក្ខុ នៅថ្ងៃអាទិត្យ ១៥ រោច ខែចេត្រ ឆ្នាំរកា សប្តស័ក **ព.ស ២៥៤៨** ត្រូវនឹងថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០០៥ ។

**កំរិតសិក្សា:** ថ្នាក់បរិញ្ញាបត្រ ផ្នែកត្រៃបិដកជុំរកិច្ច

ꕥꕥ📖ꕥꕥ

# មាតិកា


ឈ្មោះអត្ថបទ ទំព័រ

អារម្ភកថា

ឧទ្ទិសកថា

ជីវប្រវត្តិសង្ខេប

ធម៌បទសារភញ្ញ..........១

ទូរេនិទាន..........២

មហាសម្មតិវង្សបរិច្ឆេទទី១..........៤

អាវាហបរិច្ឆេទទី២..........១០

តុសិតបរិច្ឆេទទី៣..........១៥

គព្ភាភិនិក្ខមនបរិច្ឆេទទី៤..........២៣

លក្ខណៈបរិគ្គហណបរិច្ឆេទទី៥..........២៩

រាជាភិសេកបរិច្ឆេទទី៦..........៣៤

មហាភិនិក្ខមនបរិច្ឆេទទី៧..........៤៥

ទុក្ករៈកិរិយាបរិច្ឆេទទី៨..........៥៦

ពុទ្ធបូជាបរិច្ឆេទទី៩..........៧៤

មារវិជយបរិច្ឆេទទី១០..........៨៧

អភិសម្ពោធិបរិច្ឆេទទី១១..........៩៥

ពោធិសព្វញ្ញុតបរិច្ឆេទទី១២.......................................១០១

ព្រហ្មផ្សេបរិច្ឆេទទី១៣.......................................១១៨

ធម្មចក្កបរិច្ឆេទទី១៤.......................................១២២

យសបព្វជ្ជបរិច្ឆេទទី១៥.......................................១២៩

ឧរវេលគមនបរិច្ឆេទទី១៦.......................................១៣៧

អគ្គសាវកបព្វជ្ជាបរិច្ឆេទទី១៧.......................................១៥០

កបិលវត្ថុគមនបរិច្ឆេទទី១៨.......................................១៦២

ពិម្ពាពិលាបបរិច្ឆេទទី១៩.......................................១៧០

សក្យបព្វជ្ជាបរិច្ឆេទទី២០.......................................១៧៧

មេតេយ្យព្យាករណបរិច្ឆេទទី២១.......................................១៨៧

ពុទ្ធបិតុនិព្វានបរិច្ឆេទទី២២.......................................១៩២

បរិនិព្វានបរិច្ឆេទទី២៣.......................................១៩៨

ចប់ពុទ្ធាធិវាសនដ្ឋាន.......................................២១៥

ពុទ្ធប្បវត្តិសង្ខេប.......................................២១៦

កំណាព្យ.......................................២២២

នាមសប្បុរសជន.......................................២២៤

# បទសរភញ្ញ

**សូម**ថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្ស និងទេវតា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។

**ចង្អុល**ឲ្យដើរផ្លូវកណ្ដាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ អាចកាត់សង្សារ ៈទុក្ខបាន ។

**សាសនា**ព្រះអង្គ នៅសព្វថ្ងៃ សត្វមាននិស្ស័យ ពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន កាន់តាមលំអានបានក្ដីសុខ ។

**ឥតមាន**សុខណាស្មើក្ដីស្ងប់ បញ្ចាប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះ តទៅមុខ ក្ដីសុខនឹងមានព្រោះធម៌ស្ងប់ ។

**ខ្ញុំសូម**បង្គំ ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរតន៍ គួរគោរព ជាម្លប់ត្រជាក់ នៃលោកា ។

**ព្រះរូប**ព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គ ព្រះសាស្ដា
សូមគុណត្រៃរ័ត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ ។

# ពុទ្ធប្បវត្តិកថាសង្ខេប

( ទូរេនិទាន )

បានឮមកថា ព្រះសម្មាសម្ពុទ្ធជា**នរាសភ** [១] កាលព្រះអង្គ ទ្រង់ស្វែងរកនូវពោធិញ្ញាណនៅឡើយ ព្រះអង្គទ្រង់យោនយកកំណើត កើតជាព្រាហ្មណ៍នាមថា **សុមេធបណ្ឌិត** មានទ្រព្យសម្បត្តិច្រើន បានលះទ្រព្យសម្បត្តិចេញទៅសាងព្រះផ្នួស បួសជា**តាបសឥសី** នៅព្រៃហេមពាន្ត បានសម្រេចឈាន និង អភិញ្ញាបានចរលើលាមកតាមអាកាស បានឃើញមហាជនមីរដេរដាស់ កំពុងធ្វើផ្លូវថ្នលដើម្បីថ្វាយព្រះ**ទសពល ព្រះនាមទីបង្ករ** ទ្រង់យាងចេញអំពីមហាវិហារ **សុទស្សនៈ** ចូលទៅកាន់ **នគរអមរវតី** តាបសក៏បានទទួលនាទី ១ កន្លែង ដើម្បីធ្វើដោយខ្លួនឯង ។ កាលបើផ្លូវនោះ ពុំទាន់សម្រេចនៅឡើយ, ជួនជាព្រះសម្មាសម្ពុទ្ធទ្រង់យាងមកដល់ ។ គ្រានោះ**សុមេធតាបស** ក៏ក្រាលនូវសំពត់សំបកឈើ ព្រមទាំងស្បែកសត្វ លើភក់ពណ៌ខ្មៅ ហើយក្រាបចុះដេកធ្វើជាស្ពាន យាងព្រះទ្រង់ញាណ ព្រមទាំងនិមន្តសង្ឃសាវ័ក ឲ្យជាន់លើខ្លួនឆ្លងភក់, ព្រះទសពល ទ្រង់ពិចារណាហើយព្យាករថា តាបសនេះ

១.នរាសភៈ មនុស្សប្រសើរ (ព្រះសម្មាសម្ពុទ្ធ),

នឹងបានជា ***ពុទ្ធង្កុរបណ្ឌូលសារពេជ្ញតាញាណ***[១] អំណឹះត ទៅនឹងបានត្រាស់ជាព្រះពុទ្ធ ១ អង្គ ព្រះនាមថា"***គោតម***" ។



តាំងពីពេលនោះ រៀងដរាបមក ព្រះបរមពោធិសត្វនៃ យើងក៏ព្យាយាមបំពេញបារមីទាំងឡាយ ៣០ ប្រការ ឥតមាន សម្រាកឲ្យអាក់ខាន អស់កាលប្រមាណ ៤ អសង្ខេយ្យ និង ១ សែនកប្ប ដរាបមកទល់ភទ្ទកប្ប[២]នេះ ។

២.***ភទ្ទកប្ប:*** *កប្បដ៏ចំរើនមានព្រះពុទ្ធកើតឡើង និងត្រាស់៥ ព្រះអង្គ, ១.សព៌េជ្ញ,សារពេជ្ញ ឬសរពេជ្ញ: ខ្មែរប្រើ (សព្វញ្ញូ)*

## (មហាសម្មតិវង្សបរិច្ឆេទទី១)

ក្នុងកាលជាខាងដើម នៃភទ្ទកប្បនេះ ព្រះបរមពោធិសត្វ នៃយើងទាំងឡាយ ទ្រង់កើតជាស្ដេចព្រះនាម ***មហាសម្មតិទេវរាជ*** បបមក្សត្រសោយរាជសម្បត្តិ ក្នុងសកលជម្ពូទ្វីបនេះ ទ្រង់មានព្រះរាជឱរសព្រះនាម ***រោជរាជ***, ព្រះបាទរោជរាជនោះ មានព្រះរាជឱរសព្រះនាម ***កល្យាណរាជ***, ព្រះបាទកល្យាណរាជនោះ មានព្រះរាជឱរសព្រះនាម ***វរកល្យាណរាជ***, ព្រះបាទវរកល្យាណរាជនោះ មានព្រះរាជបុត្រព្រះនាម ***សក្កមន្ធាតុ*** , ព្រះបាទសក្កមន្ធាតុនោះ មានព្រះរាជបុត្រព្រះនាម ***ឧបោសថរាជ*** ,ព្រះបាទឧបោសថរាជនោះ មានព្រះរាជបុត្រព្រះនាម ***វររាជ*** ,ព្រះបាទវររាជនោះ មានព្រះរាជឱរសព្រះនាម ***ឧបវររាជ*** , ព្រះបាទឧបវររាជនោះ មានព្រះរាជឱរសព្រះនាម ***មឃទេវរាជ*** បានសោយរាជ្យសម្បត្តិ ត ព្រះរាជវង្សជាលំដាប់មក ។

លំដាប់ពីនោះមក ព្រះរាជវង្សានុវង្ស បានសោយរាជ្យសម្បត្តិ ត ៗ គ្នា មកមានចំនួន ៨៤,០០០ ព្រះអង្គទៀត ទើបមកដល់ឱក្កាកវង្សទាំង ៣ គឺ ***ព្រះបឋមឱក្កាករាជ ១ ទុតិយឱក្កាករាជ ១ , តតិយឱក្កាករាជ ១*** ។ ព្រះបាទតតិយឱក្កាករាជនោះមានព្រះមហេសី ៥ ព្រះអង្គគឺៈ

***ព្រះនាងហង្ឋា ១ ព្រះនាងចិន្តា ១ ព្រះនាងជន្តុ ១ ព្រះនាងជាលិនី ១ ព្រះនាងវិសាខា ១ ។***

ព្រះនាង**ហង្ឋា** ដែលជាអគ្គមហេសី មានព្រះរាជបុត្រា ៨ ព្រះអង្គគឺ ***និកាកមុខរាជកុមារ ១ ,ករណ្ឌុរាជកុមារ ១ ហត្ថិនិកេសីរាជកុមារ ១ និបុររាជកុមារ និង ព្រះរាជបុត្រី ៥ ព្រះអង្គគឺ ព្រះនាងបិយារាជកុមារី ១ សុបិយារាជកុមារី ១ អានន្ទារាជកុមារី ១ ជីវិតារាជកុមារី ១ ជីវិតសេនារាជកុមារី ១*** រួមជាព្រះរាជបុត្រ និងព្រះរាជធីតាទាំងអស់ ៩ ព្រះអង្គ ។

ក្នុងពេលជាខាងក្រោយមក ព្រះនាង**ហង្ឋាអគ្គមហេសី** ជាចម្បង ទ្រង់សោយព្រះវិលាល័យទៅ ។ ព្រះរាជាទ្រង់លើកមហេសីទី ២ ឲ្យឡើងជាអគ្គមហេសីថ្មី ។ ព្រះអគ្គមហេសីថ្មីនេះ បានព្រះរាជបុត្រា ១ អង្គ បាន ៥ ខែ ព្រះនាងក៏នាំទៅគាល់ព្រះរាជបិតា ។ ព្រះមហាក្សត្រទ្រង់មានព្រះរាជហឫទ័យ ស្នេហាទ្រង់ត្រាស់ ព្រះរាជឱង្ការថា យើងប្រទានពរដល់នាង ៗ ចង់បានអ្វី ? ចូលឲ្យបានសម្រេចដូចចិត្ត...។ ព្រះមហេសីក៏ទូលស្នងព្រះរាជឱង្ការថា "ខ្ញុំម្ចាស់ចង់បានតែរាជសម្បត្តិឲ្យបុត្រនេះ សូមព្រះអង្គរាជទាន ឲ្យបានសម្រេចដូចប្រាថ្នា" ព្រះរាជាក៏ទ្រង់ធ្ងក់ព្រះឱរមានព្រះរាជហឫទ័យកន្ទះរា និងលៃថាដូចម្តេចក៏ពុំកើត ទើបត្រាស់ព្រះរាជឱង្ការហៅ ព្រះរាជបុត្រទាំង ៨ អង្គ-

មកជួបជុំគ្នា ហើយត្រាស់ថា " ហៃបាទាំងឡាយ! បិតាជ្រុលសម្ដីនឹងអគ្គមហេសីនេះ, បើដូច្នេះ អ្នកទាំងឡាយជួយពិចារណា តើគួរឲ្យបិតាធ្វើដូចម្ដេចទៅវិញ ? ព្រះរាជបុត្រាទាំង ៤ ព្រះអង្គ ក្រាបបង្គំទូលថា " ពុំគួរព្រះរាជបិតាបង់ពាក្យសច្ចៈទេ " ។ ព្រះរាជាត្រាស់ថា បើដូច្នេះមានតែអ្នកទាំងឡាយ ចេញទៅព្រៃសិនចុះ អ្នកទាំងឡាយចង់បានអ្វីជញ្ជូនយកទៅចុះ លើកលែងតែគ្រឿងប្រដាប់សម្រាប់រាជ្យចេញ ។ ព្រះរាជបុត្រាទាំង ៤ អង្គ មានព្រះ*ឱ្ភាកមុខៈ* ជាប្រធាន បានថ្វាយបង្គំលាព្រះរាជបិតា និងព្រះរាជវង្សានុវង្ស ទ្រង់ព្រះកន្សែងថ្ងៃង ព្រះសំណោកសោកអាល័យ ហើយនាំគ្នាចេញចាក**រាជបុរី** ព្រមទាំង**ព្រះរាជភគិនី**[១] ទាំង ៥ ព្រះអង្គ និងបណ្ដាជនប្រុសស្រីជាបរិវារជាច្រើន ទៅតាមអស់មាគ៌ា ៣ យោជន៍ ក៏ពុំទាន់អស់ពពួកពលសេនាទាំងនោះផង ។

ព្រះរាជកុមារីទាំងឡាយ បានប្រឹក្សាគ្នាថា"ពួកសេនាទាហានមានចំនួនច្រើន បើនឹងទៅច្បាំងដណ្ដើមយកនគរ**ស្ដេចសាមន្តរាជ**[២] ឯណានីមួយក៏បាន ប៉ុន្តែប្រយោជន៍អ្វីដល់ការបៀតបៀនគេដូច្នោះ ហេតុនេះគួរតែយើងទៅនៅឯព្រៃហេមពាន្តដើម្បីកសាងនគរថ្មី ។

១.(ភគិនីៈ ប្អូនស្រី ឬបងស្រី នេះរាជស័ព្ទ), ២.សាមន្តរាជៈ ព្រះរាជាក្នុងប្រទេសជិតខាង

គ្រានោះ ព្រះបរមពោធិសត្វ នៃយើងកើតក្នុងត្រកូលមហាសាលព្រះនាម**កបិលព្រាហ្មណ៍** លះបង់សម្បត្តិចេញទៅសាង ព្រះផ្នួសបួសជាតាបសឥសី នៅក្នុងអាស្រមមួយនាសំយាបព្រៃហេមពាន្ត ។ កបិលតាបសនោះ ចេះស្ទាត់ជំនាញខាង**ភូមិតលវិទ្យា** ស្គាល់គុណ និងទោស នៃផែនដីសព្វអន្ទើ បានឃើញភូមិភាគត្រង់កន្លែងនោះ ជាទីមានជ័យល្អព្រោះថា បើសត្វសាហាវទាំងឡាយ មានសីហៈ និងខ្លាជាដើម ដេញម្រឹគទៅក្តី ឆ្មាដេញកណ្តុរទៅក្តី ពស់ដេញកង្កែបទៅក្តី ដល់ទៅត្រង់កន្លែងនោះ សត្វឥតអំណាចទាំងនោះ អាចបែរមុខមកគំរាមសត្វ ដែលមានអំណាចវិញ សត្វដែលមានអំណាច ក៏ថយចេញទៅទីឯទៀតទៅ ។

កាលព្រះរាជកុមារទាំងឡាយ មានឱកាកមុខរាជកុមារ ជាដើមកំពុងស្វែងរកទីកន្លែង ដើម្បីកសាងព្រះនគរថ្មី ស្រាប់តែបានជួប**កបិលតាបស** ៗ បានដឹងរឿងរ៉ាវអំពីរាជដំណើរ របស់ព្រះរាជបុត្រទាំងឡាយ ហើយក៏ប្រគល់ទីបណ្ណាសាលានោះ ថ្វាយព្រះរាជបុត្រទាំងឡាយ ដើម្បីកសាងព្រះនគរថ្មី ។ ព្រះរាជបុត្រទាំងឡាយ ព្រមទាំងពពួកពលយោធា ជាបរិវារទាំងឡាយ ក៏នាំគ្នាចាប់ផ្តើម

កសាងនគរថ្មី ហើយតាំងនាមថា "**កបិលវត្ថុបុរី**" ដោយហេតុថា ទីជាទីអាស្រ័យរបស់ **កបិលតាបស** ។

តពីនោះមកអាមាត្យ ៨ នាក់ ដែល**ព្រះបាទឱក្កាក:** បរមរាជបិតាចាត់មកជាអ្នកថែទាំរក្សា មើលការខុសត្រូវដល់ព្រះរាជបុត្រាបុត្រីទាំងនោះ ក៏ប្រជុំពិភាក្សាគ្នាថា "ព្រះរាជកុមារកុមារីទាំងឡាយ បានចំរើនវ័យវឌ្ឍនាការគ្រប់ ៗ ព្រះអង្គហើយ គួរយើងរៀបចំពិធីរាជាភិសេក ហើយក៏នាំគ្នាទៅគាល់ ក្រាបបង្គំទូលស្នើរសេចក្តីនោះ នឹងព្រះរាជកុមារ រាជកុមារីគ្រប់ ៗ ព្រះអង្គ សម្រេចសេចក្តីថា ត្រូវតាំងព្រះ**ជេដ្ឋភគិនី** ( ព្រះរាជធីតាច្បង ) ក្នុងនាទីជាព្រះមាតាត្រូវអភិសេក ព្រះរាជកុមារទាំង ៤ ព្រះអង្គ ជាមួយ និង ព្រះរាជបុត្រីទាំង ៤ ព្រះអង្គ ដែរតាមលំដាប់ ៗ គ្នា ដើម្បីកុំឲ្យមាន**សម្ភិន្នជាតិ** (ច្រឡូកច្រឡំដោយលោហិត) នៃជនដែលមិនបរិសុទ្ធព្រះរាជវង្សនេះ មាននាមបញ្ញត្តិថា "**សក្យវង្ស**" បានសោយរាជ្យសម្បត្តិ ត ៗ គ្នា មកជាច្រើនជួរក្សត្រ ដរាបដល់ព្រះបាទ**សិវិរាជ** , ព្រះបាទ**សញ្ជ័យរាជ**, និង ព្រះបាទ**វេស្សន្តរ** ។

ក្នុងសិវិរាជវង្សនេះ បានកែប្រែនាម**នគរកបិលវត្ថុ** ហៅថា**នគរជេតុត្តរ** វិញ ។ ព្រះវេស្សន្តររាជ សោយទិវង្គត

ទៅ ព្រះរាជឱរសនាម **ជាលី** ដែលបានរាជាភិសេកជាមួយ និងព្រះនាង **កណ្ហាជិនា** ជាព្រះកនិដ្ឋភគិនី ( ប្អូនស្រី ) បានគ្រងរាជ្យសម្បត្តិតរៀងមក មានព្រះរាជបុត្រព្រះនាម **សិវិវាហនៈ** ព្រះបាទសិវិវាហន មានព្រះរាជឱរសព្រះនាម **សីហសរាជ** បានគ្រងរាជ្យ ត ៗ មក **១៦១.០០០ ព្រះអង្គ** ទើបបានមកដល់ រាជ្យរបស់**ព្រះបាទ ជយសេន** ។

ព្រះបាទជយសេន មានព្រះរាជបុត្រនាម **សីហហនុ** បានរាជាភិសេកជាមួយ និង អគ្គមហេសី ព្រះនាម **កាញ្ចនា** ជាកនិដ្ឋភគិនី របស់**ព្រះបាទអញ្ជនៈ នគរទេវទហៈ** ហើយទ្រង់ផ្លាស់នាមនគរជាកបិលវត្ថុវិញ ។

ព្រះបាទ**សីហហនុ** មានព្រះរាជបុត្រា ៣ អង្គ គឺៈ **សុទ្ធោទនៈ ១ សុក្កោទនៈ ១ អមិតោទនៈ ១** ,មានព្រះរាជធីតា ២ ព្រះអង្គគឺ **នាងអមិត្តា ១ បមិត្តា ១** ។ ចំណែកខាង**ព្រះនាងយសោធរា** រាជបុត្រីរបស់ព្រះបាទ **ជយសេន** បានជាមហេសីព្រះ**បាទអញ្ជនៈ** មានព្រះរាជបុត្រី ២ ព្រះអង្គ គឺព្រះនាង **មាយា ១ បជាបតី ១** និងរាជបុត្រា ២ ព្រះអង្គគឺ **សុប្បពុទ្ធ ១ ទណ្ឌបាណិ ១** ។

## ( ចប់មហាសម្មតិវង្សបរិច្ឆេទទី១ )

* * * * *

# ( អាវាហបរិច្ឆេទទី២ )

សម័យកាលនោះ ព្រះបាទ**សីហហនុរាជ** មានព្រះរាជហឫទ័យប្រាថ្នានឹងអភិសេក **ព្រះសិរីសុទ្ធោទនៈរាជកុមារ** ទ្រង់ឲ្យអញ្ជើញព្រាហ្មណ៍ ៨ នាក់ មកទ្រង់ព្រះរាជបញ្ជាឲ្យទៅរកព្រះរាជកញ្ញា ប្រកបដោយបញ្ចពិធកល្យាណី និង លក្ខណៈ ៦៤ ប្រការ ទើបទ្រង់ព្រះរាជទាន នូវព្រះរាជទ្រព្យចំនួន ៨០០០ **កហាបណៈ** ដល់ព្រាហ្មណ៍ព្រមទាំង **មណិបិលន្ធនៈ** (១) ផ្តាំថាបើព្រាហ្មណ៍រកបានខត្តិយកញ្ញា ត្រូវប្រដាប់នូវគ្រឿងប្រដាប់នេះសម្គាល់ ព្រាហ្មណ៍ទាំង ៨ នាក់នោះ ក៏ទទួលទៅស្វែងរក ។

ក្នុងកាលនោះ ព្រះនាងសិរិមហាមាយា មានបុណ្យកុសលកសាង តាំងអំពីសាសនា **ព្រះពុទ្ធវិបស្សី** ដរាបមក នាងបានមកកើតជា រាជធីតារបស់**ព្រះបាទអញ្ជនៈ** ជនាធិរាជ ព្រះនាងប្រកបដោយបញ្ចពិធកល្យាណី និង លក្ខណៈ ៦៤ ប្រការ មានវ័យវឌ្ឍនាព្រះជន្ម ១៦ វស្សា ក្នុងកាលជិតមាសបុណ្ណមី ខាងដើមគឺម្ហូវដូវ ព្រះនាងក៏នាំបរិវារទៅក្រសាលក្នុងឧទ្យាន ។

ក្នុងកាលនោះ ព្រាហ្មណ៍ទាំង ៨ នាក់ ដែលព្រះបាទ**សីហហនុរាជ** ត្រាស់ប្រើមក ក៏ដើរស្វែងរកក្នុងនគរ

១.**មណិបិលន្ធនៈ** គ្រឿងប្រដាប់តាក់តែងវមណី

ដទៃមិនបាន លុះមកដល់**ទេវទហនគរ** ក៏ដើរទៅក្នុងឧទ្យានបានឃើញ **ព្រះនាងសិរិមហាមាយា** ដែលប្រកបដោយ**បញ្ចពិធកល្យាណី** និងលក្ខណៈ ៦៤ ប្រការ, ក៏សន្ទនាសាកសួរសព្វគ្រប់ ហើយក៏ថ្វាយ**មណិមិលន្ធនៈ**ដល់ព្រះនាង, ហើយទើបទៅកាន់សំណាក់ព្រះបាទជនាធិរាជក្រាបទូលសព្វសេចក្តី ។

**ព្រះបាទអញ្ជនៈ**ទ្រង់យល់ព្រមនឹងថ្វាយដល់ព្រាហ្មណ៍ទាំងឡាយ ៗ ក៏ត្រឡប់ទៅកាន់**កបិលវត្ថុបុរី** ក្រាបបង្គំទូលសេចក្តីនោះ ដល់ព្រះបាទសីហហនុរាជ សព្វគ្រប់ប្រការ ។

ក្នុងថ្ងៃដែលព្រាហ្មណ៍មកដល់នោះ ព្រះបាទ**សីហហនុរាជ** ទ្រង់ឃើញសុបិននិមិត្តក្នុងរាត្រីនោះដែរ, ឯសុបិននោះ ប្រាកដជាពីរប្រការគឺ **ទ្រង់ឃើញថា រតនវិមានមួយមានជាន់ ១៨ ផុសឡើងអំពីភូមិភាគ ក្នុងទីកណ្តាលជម្ពូទ្វីប ទៅដល់ភវគ្គព្រហ្ម ប្រការ ១ , មួយទៀតទ្រង់ឃើញថាមានមហាគង្គាមួយវែងជ្រៅក្រៃពេក ដ៏ដេរដាសដោយរលកធំ ៗ មានមហាបុរសម្នាក់ ដែលនៅក្នុងប្រាសាទនោះ តាក់តែងសំពៅ និង ចម្លងនូវសត្វទាំងឡាយ អំពីត្រើយអាយ ទៅកាន់ត្រើយនាយប្រការ ១ ។**

**ព្រះបាទសីហហនុរាជ** កាលទ្រង់បានព្រះសណ្តាប់

ពាក្យព្រាហ្មណ៍ក្រាបបង្គំទូលដូច្នោះ ព្រះអង្គមានព្រះរាជហឫទ័យរីករាយ ទ្រង់បង្គាប់ឲ្យអាមាត្យ តាក់តែងមគ្គវិថីអំពីកបិលវត្ថុបុរី ទៅដល់**ទេវទហនគរ**, ព្រះអង្គក៏យាងទៅកាន់ទេវទហនគរ លុះទៅដល់**លុម្ពិនីឧទ្យាន** ក៏ជួបនិងព្រះបាទអញ្ជនៈជនាធិបរាជ ស្តេចសន្ទនាដោយព្រះរាជឱង្ការផ្សេង ៗ ទ្រង់ត្រាស់បង្គាប់ជាងការយ៉ាងឯក ឲ្យតាក់តែងមហាប្រាសាទ និងរៀបអភិសេក ។

ខណៈនោះក៏**កម្បនាការ**(១) ដល់**បណ្ឌុកកម្ពលសិលាសនា**(២) សម្តេចអមរិន្ទ្រាធិរាជ ទ្រង់ជ្រាបច្បាស់នូវហេតុ ទ្រង់បង្គាប់ទៅវិស្សុកម្មទេវបុត្រ ឲ្យមកនិម្មិតប្រាសាទដ៏ប្រកបដោយគ្រឿងឧបករណ៍ទាំងពួង ។ ព្រះរាជា និងខត្តិយវង្សទាំងពីរនគរ ក៏នាំពួកពលទៅ រាជាភិសេកព្រះរាជបុត្រាបុត្រី ក្នុងប្រាសាទដ៏ប្រសើរ ជាការស្រេចហើយ ក៏ត្រឡប់ទៅកាន់ព្រះនគរវិញ ។ ចំណែកខាង**ព្រះបាទសិរីសុទ្ធោទនៈ** និង **ព្រះនាង សិរីមហាមាយាទេវី** ក៏បានឧបដ្ឋាកព្រះមាតា និង បិតាដោយគោរព, ព្រះអង្គប្រតិបត្តិនូវ**ទសពិធរាជធម៌ ១០** ប្រការ និង ប្រកបដោយសីល តាមបុរាណរាជប្បវេណីគ្រប់ប្រការ ។

**១.កម្បនាការ:** កម្រើកញ័រ, **២.បណ្ឌុកកម្ពលសិលា:** (ថ្មមានសម្បុលដូចជាសំពត់កម្ពល់ពណ៌លឿងទុំ, ជាថ្មទិព្វជាអាសនៈរបស់ព្រះឥន្ទ ។

## រាជាភិសេកព្រះបាទសុទ្ធោទនៈ និងព្រះនាង សិរិមហាមាយាទេវី



ព្រះបាទសីហហនុរាជទ្រង់ ព្រះទិវង្គតទៅ ព្រះរាជសុណិសាខត្តិយវង្ស និង អាមាត្យសព្វមុខមន្ត្រីទាំងពួង ក៏រៀបចំ ធ្វើឈាបនកិច្ចបូជា ព្រះភ្លើងស្រេចហើយ ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់សោយរាជសម្បត្តិស្នង ព្រះវររាជបិតាជាសុខក្សេមក្សាន្ត ។

(ចប់អារាហាបរិច្ឆេទទី២)

✵✵✵✵✵✵✵

# តុសិតបរិច្ឆេទទី៣

*( អវិទូរេនិទាន )*

បានឮមកថា ព្រះបរមពោធិសត្វ នៃយើងបានទទួលការព្យាករណ៍ អំពីសំណាក់ព្រះពុទ្ធ ២៤ ព្រះអង្គ មាន **ព្រះពុទ្ធទីបង្ករ**ជាដើម ព្រះអង្គឧស្សាហ៍បំពេញបារមីធម៌ **ទាំងឡាយ ៣០ ប្រការ មហាបរិច្ចាគ ៥ ចរិយា ៣** ក្នុងកាលជាចន្លោះនោះ ដល់បានទទួលការព្យាករណ៍ អំពីសំណាក់ ***ព្រះពុទ្ធកស្សបៈ*** ជាបរិយោសានចំនួន ៤ ***អសង្ខេយ្យ និង ១ សែនកប្ប*** ព្រះបរមពោធិសត្វបានមាននាមថា ***ជោតិបាល*** បានបួសជាភិក្ខុ ហើយបានស្តាប់នូវព្រះសម្មាសម្ពុទ្ធ ***ព្រះនាមកស្សបៈ*** ទ្រង់ព្យាករណ៍ ហើយតាំងចិត្តជ្រះថ្លា ឧស្សាហ៍បំពេញនូវបារមីធម៌ លុះច្យុតចាកអត្តភាពនោះ ហើយក៏អន្ទោលទៅក្នុងភពតូច និងភពធំ ដរាបមកដល់កើតក្នុង ***នគរជេតុត្តរ*** ទ្រង់មាននាមប្បញ្ញត្តិថា ***វេស្សន្តរ*** ។

ព្រះបាទវេស្សន្តររាជ ទ្រង់ព្រះរាជទាននូវ ***សត្តសតកមហាទាន*** ដល់ពួកយាចក ។ តេជានុភាព នៃមហាទានរបស់ព្រះបរមពោធិសត្វ ក្នុងកាលនោះ អាចញ៉ាំងមហាប្រឹថពីឲ្យញាប់ញ័រ ហើយព្រះអង្គក៏ចេញទៅសាងបព្វជ្ជា ជាឥសី

គង់នៅក្នុងបណ្ណសាលាទៀប **ភ្នំគិរីវង្កត** ព្រះអង្គបរិច្ចាគព្រះរាជបុត្រាបុត្រី និង អគ្គមហេសី ជាកំពូលបារមីឲ្យដល់ព្រាហ្មណ៍ ទើបព្រះអង្គយាងមកគង់ ក្នុងព្រះនគរវិញ ។ លុះអស់ព្រះជន្ម សោយព្រះទិវង្គតទៅបាន ទៅកើតក្នុង **តុសិតពិភព** ទ្រង់ព្រះនាមថា **សន្តុសិតទេវបុត្រ** សោយទិព្វសម្បត្តិ និង ឥស្សរិយយសដ៏ប្រសើរ ក្នុង**តុសិតពិភព** ។

សន្តុសិតទេវបុត្របរមពោធិសត្វ ស្ថិតនៅតុសិតពិភព ដែលមានព្រះជន្ម **៤០០០ ឆ្នាំទិព្វ ស្មើនឹង ៥៧ កោដិ និង ៦០ សែន ឆ្នាំ មនុស្ស ។**



គ្រានោះ ទេវតាដែលស្ថិតនៅក្នុងចក្កវាឡទាំងមួយម៉ឺន បានចូលទៅអារាធនាសន្តុសិតទេវបុត្ត ដោយពាក្យថា:

*កាលនេះជាកាលគួរដល់ព្រះអង្គ សូមព្រះអង្គច្យុតទៅកើតក្នុងផ្ទៃនៃមាតា បានត្រាស់ដឹងនូវព្រះនិព្វាន ហើយចម្លងសត្វលោកព្រមទាំងទេវតា ឲ្យរួចចាកវដ្តសង្សារ ។*

## *ព្រះបរមពោធិសត្វរមិលមើលបញ្ចលោកន:*



ព្រះបរមពោធិសត្វ សណ្តាប់ហើយ ទ្រង់ក៏រមិលនូវមហាលោកន:ទាំង ៥ ប្រការគឺ: **កាល ១ ប្រទេស ១ ទ្វីប ១ ត្រកូល ១ មាតា ១** រមិលមើលពិចារណា ហើយទើបឲ្យបដិញ្ញាដល់ទេវតាទាំងឡាយ ។

ព្រះបរមពោធិសត្វ ដែលរមិលមើលនូវ**មហាលោកនៈ** ទាំង ៥ ប្រការនោះ ព្រោះអាស្រ័យហេតុជាធម្មតាថា បើកាលណាសត្វ មានអាយុច្រើនជាង**មួយសែនឆ្នាំ** ឡើងទៅ ថយតិចចុះពី **១០០ ឆ្នាំ** មក ។ កាលនោះ ព្រះពុទ្ធមិនដែលចុះមកកើតទេ អាយុមនុស្សយ៉ាងច្រើនត្រឹម **១ សែនឆ្នាំ**, យ៉ាងតិចត្រឹម **១០០ ឆ្នាំ** ទើបព្រះពុទ្ធចុះមកកើតក្នុងលោក។

-ព្រះបរិមពោធិសត្វ រមិលមើលនូវប្រទេសនោះគឺ: ព្រះពុទ្ធមិនដែលកើតក្នុង**បច្ចន្តប្បទេសទេ**, បុគ្គលទាំង-ឡាយមានយសច្រើន មានព្រះពុទ្ធជាដើម រមែងកើតតែក្នុង**មជ្ឈិមប្រទេស**ប៉ុណ្ណោះ ។

-ព្រះបរមពោធិសត្វ រមិលមើលនូវទ្វីបនោះ គឺព្រោះទ្វីបទាំង ៣ ព្រះពុទ្ធមិនដែលកើតទេ តែងតែកើតក្នុង **ជម្ពូទ្វីប** មួយប៉ុណ្ណោះ ។

-ព្រះបរមពោធិសត្វ រមិលមើលនូវត្រកូលនោះគឺ ដ្បិតថា ព្រះពុទ្ធមិនដែលកើត ក្នុងត្រកូលទាបទេតែងតែកើតក្នុងត្រកូលពីរគឺ ***ខត្តិយត្រកូល ១ ព្រាហ្មណ៍ត្រកូល ១*** ។

-ព្រះបរមពោធិសត្វ រមិលមើលនូវមាតានោះគឺ ដ្បិតថា ស្រីដែលជាពុទ្ធមាតា មិនមែនជាស្រីឡេះឡោះ មិនមែនជាអ្នកលេងសុរាជាដើម , ពុទ្ធមាតានោះ ជាស្រីមាន

អភិនីហារ កសាងមកអំពីអតីតភព មានបារមីធម៌ បំពេញគ្រប់ ១ សែនកប្បហើយ ។ **សន្តុសិតទេវរាជ** នោះ រមិលមើលនូវបញ្ចមហាវិលោកនៈ ស្រេចហើយ ព្រះអង្គ ច្យុតចាក **តុសិតពិភព** មកបដិសន្ធិក្នុងផ្ទៃនៃ **ព្រះនាងសិរីមហាមាយា** ក្នុងសក្យត្រកូលនា ថ្ងៃព្រហស្បត្តិ៍ ពេញបូណ៌មី ខែ អាសាឍ ឆ្នាំ រកា ។

**(សន្តុសិតទេវបុត្តចុតិ)**



បានឮមកថា ក្នុងកាលមុន ៧ ថ្ងៃ អំពីថ្ងៃពេញបូណ៌មី ខែ អាសាឍនោះ មហាជនក្នុងនគរកបិលវត្ថុនោះ បបួលគ្នាលេងមហាស្រព ។ រីឯ**ព្រះនាងសិរីមហាមាយា** ក៏តាក់តែងកាយដោយគ្រឿង **សុគន្ធវិលេបនៈ** ហើយក្រសាលនក្ខត្តឫក្សអស់ ៧ ថ្ងៃ ។



លុះដល់ថ្ងៃពេញបូណ៌មី វេលាព្រឹកព្រះនាងទេវីស្រង់ទឹកស្រេច ហើយក៏បរិច្ចាគទ្រព្យចំនួន ៤ **សែនកហាបណៈ** ឲ្យជាទាន ព្រះនាងសោយស្រេច ក៏សមាទានឧបោសថសីល ហើយឡើងផ្ទុំ**សិរីសយនា** ។

# (សុបិននិមិត្ត)



លុះដល់បច្ចូលសម័យ ព្រះនាងទេវីក៏បានឃើញសុបិននិមិត្ត ។ ឯសុបិននិមិត្តនោះ ព្រះនាងឃើញថា "ស្តេចចតុលោកបាលមហារាជទាំង ៤ រូប មកលើកព្រះនាងទាំងសិរីសយនា នាំទៅកាន់ព្រៃហេមវន្ត ហើយតាំងទុកលើ **មនោសិលា** ដ៏ធំប្រមាណ ៦០ យោជន៍ ខាងក្រោមដើមរាំងធំមួយដើមកម្ពស់ ៧ យោជន៍ ។ កាលនោះ ព្រះនាងទេវីទាំងឡាយ ជាទេពីរបស់ស្តេចចតុមហារាជទាំងឡាយនោះ

មកយាងព្រះនាងទៅស្រង់ទឹក ក្នុង**ស្រះអនោតត្ត**[១] ដុះជម្រះព្រះកាយថ្វាយព្រះនាង ហើយលាបដោយ**គន្ធវិលេបនៈ** [២]ជាទិព្វក្នុងទីជិតស្រះនោះ មានភ្នំប្រាក់មួយមាន**សុវណ្ណវិមាន** (វិមានមាស) មួយស្ថិតនៅលើភ្នំប្រាក់នោះ នាងទេពធីតាទាំងឡាយ ក៏យាងព្រះនាងឲ្យទៅផ្ទំ ក្នុងសុវណ្ណវិមាន ឲ្យយកព្រះសិរៈ(ក្បាល) ទៅទិសខាងកើត ក្នុងទីជិត**រជតបព៌ត**នោះ មាន**សុវណ្ណគិរី** (ភ្នំមាស) មួយមាន**សេតហត្ថី១**[៣] ត្រាច់ចរលើសុវណ្ណបព៌ត ចុះចាកសុវណ្ណគិរីមកឡើងលើ**រជតបព៌ត សេតហត្ថី** នោះ មានប្រមោយកាន់យកនូវ**សេតបុទម** [៤] ហើយបន្លឺនូវ**កោញ្ចនាទ**[៥] ចូលមកក្នុងសុវណ្ណវិមាន ដើរប្រទក្សិណព្រះនាង ៣ ជុំ ហើយហាក់បីដូចជាទៅក្នុង**ឧទរ** [៦] ប្រទេសខាងស្តាំ , ព្រះបរមពោធិសត្វចុះចាប់បដិសន្ធិ ក្នុងពេលនោះឯង ។ បុព្វនិមិត្ត ៣២ ប្រការ មាន**កម្បនាទ**(ការកក្រើកញាប់ញ័រ) លោកធាតុជាដើម មានពន្លឺភ្លឺទូទៅជាទីបំផុត ដើម្បីសម្តែងនូវគុណនោះ ៗ ក៏កើតឡើងក្នុងខណៈនោះ ។ កាលបើរាត្រីភ្លឺឡើង ព្រះនាងក៏យាងទៅក្រាបបង្គំទូល នូវសុបិននិមិត្តនោះដល់**ព្រះបាទសិរីសុទ្ធោទនៈ**។

*__១.អនោតត្តស្រះ__ គឺជាស្រះដែរមិនត្រូវកម្តៅថ្ងៃ ហើយមានទឹកត្រជាក់គួរអោយចង់ផឹក ចង់ងូត __២.គន្ធវិលេបនៈ__ គ្រឿងក្រអូប សម្រាប់ស្អិតស្អាងរាងកាយ, __៣. សេតហត្ថីៈ__ (ដំរីស), __៤.សេតបុទមៈ__ ផ្កាឈូកពណ៌ស __៥.កោញ្ចនាទៈ__ ការបន្លឺសូរស័ព្ទ ឬសម្លេង , __៦.ឧទរៈ__ (ពោះ.ផ្ទៃ),*

# ( ព្រះបរមពោធិសត្វបដិសន្ធិ )



ក្នុងកាលនោះ ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ត្រាស់ឲ្យរាជបុរស ទៅអញ្ជើញព្រាហ្មណ៍មកទាយ, ព្រាហ្មណ៍ទាំងឡាយនោះ សោតក៏ធ្វើទំនាយតាមប្រភេទ គ្រប់ប្រការ ។ ព្រះពោធិសត្វទ្រង់ចុះបដិសន្ធិ **នៅថ្ងៃព្រហស្បតិ៍ ១៥ កើត ខែ អាសាឍ ឆ្នាំ រកា វេលាជិតភ្លឺ** សឹងប្រកបដោយហេតុអស្ចារ្យផ្សេង ៗ ។

## (ចប់តុសិតបរិច្ឆេទទី៣)

# ( គព្ភាភិនិក្ខមនបរិច្ឆេទទី៤ )

កាលព្រះនាងទេវីទ្រង់គភ៌ ស្ដេចចតុលោកបាលមហារាជទាំង ៤ ក្នុងចក្រវាឡនេះ មានដៃកាន់ព្រះខ័នមកជួយរក្សា , មិនត្រឹមតែស្ដេចមហារាជទាំង ៤ ក្នុងចក្រវាឡនេះប៉ុណ្ណោះឡើយ សូម្បីស្ដេចចតុលោកបាលមហារាជ ទាំង ១ ហ្មឺនចក្កវាឡ មានព្រះហស្តកាន់ព្រះខ័នមកជួយអភិបាលរក្សា ព្រះនាងជាពុទ្ធមាតា ដរាបដល់គ្រប់ ១០ ខែជាកំណត់ ។ ចំណែកខាង ព្រះពោធិសត្វ ដែលនៅក្នុងឧទរនោះ ព្រះអង្គគង់ពែនព្រះភ្នែន បែរព្រះភក្ត្រទៅខាងព្រះឧទរនៃព្រះមាតា ព្រះ**បិដ្ឋិ**បែរទៅខាង**បិដ្ឋិ** ( ខ្នង ) ព្រះមាតាមិនដូចជា សត្វទាំងឡាយដទៃឡើយ ។ លុះនាងទេវីមានគភ៌បរិបូរ ក៏មានប្រាថ្នានឹងយាងទៅកាន់ ***ទេវទហៈនគរ*** ជាភូមិកំណើរខ្លួន ទៅក្រាបបង្គំទូលដល់ព្រះភស្ដារបស់ព្រះនាង ។ ព្រះរាជាទ្រង់អនុញ្ញាត ហើយទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យអាមាត្យតាក់តែង នូវរាជវិថីជាទីស្ដេចយាងទៅតាំងពី ***នគរកបិលព័ស្ដុ*** ដរាបដល់***នគរទេវទហៈ*** ។ លុះដល់បុព្វណ្ហសម័យ ថ្ងៃបុណ្ណមី ខែ វិសាខ កាលបើរាត្រីភ្លឺឡើង ព្រះនាងក៏យាងទៅក្រាបបង្គំទូលលា ព្រះភស្ដាទ្រង់យាងទៅដោយ**សុវណ្ណសិវិកា** (យានដំរិះមាស) ។



លុះដល់ ***លុម្ពិនីឧទ្យាន*** ជាចន្លោះនៃនគរទាំងពីរគឺៈ ***នគរកបិលព័ស្តុ ១ នគរទេវទហៈ ១*** ។ ព្រះនាងទេវី កាលបានទស្សនាសាលវ័ន ក៏មានព្រះរាជហឬទ័យ ចង់ចូលទៅប្រពាតក្នុងព្រៃនោះ រាជអាមាត្យក៏យាងព្រះនាងចូលទៅ ។ ព្រះនាងយាងទៅដល់ក្រោមដើម ***សាលព្រឹក្ស*** (ដើមរាំងភ្នំ) ហើយក៏មានព្រះរាជហឬទ័យ ចង់តោងមែកសាលព្រឹក្ស មិនអាច នឹងឈោងព្រះហស្តទៅចាប់បានឡើយ ។

ខណៈនោះ មែកសាលព្រឹក្សក៏ទន់ទាប ចូលឲ្យព្រះនាងចាប់ កាលព្រះនាងកំពុងចាប់នូវមែកសាលព្រឹក្សល់កម្មជ្ជវាតក៏កម្រើកឡើង ។ ជនទាំងឡាយបានដឹងហេតុក៏យក**ព្រះសន្ធិយា** ( វាំងនន ) ទៅបិទបាំងក្រោមដើមសាលព្រឹក្ស ហើយចេញមកក្រៅ , ទេវតាទាំង ១ ម៉ឺនលោកធាតុ ក៏មកប្រជុំគ្នាក្នុងទីនោះ ។

ព្រះបរមពោធិសត្វ ក៏ប្រសូតចាកព្រះឧទរនៃព្រះមាតា មានព្រះកាយដ៏ល្អបរិសុទ្ធក្នុង**ថ្ងៃ សុក្រ ពេញបូណ៌មី ខែ វិសាខ ឆ្នាំ ច ។**

## ( ហេតុអស្ចារ្យក្នុងថ្ងៃប្រសូត )

ក្នុងថ្ងៃដែល ព្រះពោធិសត្វប្រសូតនោះ មានទោរទឹកក្តៅ និង ទឹកត្រជាក់ ហូរធ្លាក់ចុះមកលាងមន្ទិលគភ៌ព្រះអង្គ **សុទ្ធាវាសមហាព្រហ្ម** ទាំង ៤ ក៏ទទួលព្រះមរបពោធិសត្វ ដោយបណ្តាញមាស ។ ស្តេចចាតុលោកបាលមហារាជទាំង ៤ អង្គក៏ទទួលពីមហាព្រហ្ម, ពួកស្រីស្នំទទួលពីចាតុលោកបាលមហារាជទៅទៀត ។ ឯព្រះមហាបុរស ក៏ចុះចាកហត្ថាស្រីស្នំ ទ្រង់ឈរលើភូមិភាគ ដោយព្រះបាទទាំងពីរ ។ មហាព្រហ្មក៏យកស្វេតច្ឆ័ត្រ មកបើកបាំងថ្វាយ **សុយាមទេវរាជ** ក៏យកវាល**វិជនី**(ផ្លិត) មកបក់ថ្វាយ, ទេវបុត្រមួយអង្គទៀត-

កាន់យកកែវ ៧ ប្រការ ។ ទេវបុត្រមួយអង្គកាន់យក ***សុវណ្ណបាទុកា*** (ទ្រនាប់ជើងមាស) ទេវបុត្រមួយអង្គ កាន់មកុដគ្រឿង***កកុធភ័ណ្ឌ***(១) ទាំងនោះក៏ឃើញប្រាកដដល់ភ្នែកមនុស្សទាំងឡាយ ។ ព្រះមហាបុរស ទ្រង់ឈរលើភូមិភាគបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ យាងទៅបាន ៧ ជំហានហើយពោលអសភិវាចាថា:

***អគ្គោហមស្មិ លោកស្ស***
***ជេដ្ឋោហមស្មិ លោកស្ស***
***សេដ្ឋោហមស្មិ លោកស្ស***
***អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ***

***យើងជាអគ្គបុគ្គលលើលោក , យើងជាបុគ្គលដ៏ចម្បងក្នុងលោក, យើងជាបុគ្គល ដ៏ប្រសើក្នុងលោក, ជាតិនេះ ជាជាតិចុងក្រោយរបស់យើង ជាតិថ្មីទៀតមិនមានឡើយ ។***

ទ្រង់យាងទៅលើផែនដី ប្រាកដដូចជាយាងទៅដោយអាកាស , ព្រះកាយមិនបានបិទបាំង ដោយសំពត់ប្រាកដដូចជា ទ្រង់ប្រដាប់សំពត់ និង គ្រឿងអាភរណៈទាំងពួង, ព្រះអង្គជាកុមារតូច ប្រាកដដូចជាមនុស្សធំដែលមានអាយុ ១៦ ឆ្នាំ ។

## ( សហជាតវត្ថុ៧ប្រការ )

ក្នុងថ្ងៃដែលមហាបុរសប្រសូតនោះ មានសហជាតវត្ថុ ដែលកើតព្រមក្នុងថ្ងៃនោះ ៧ គឺៈ

-នាងពិម្ពា ១

-ព្រះអានន្ទ ជាបុត្រនៃព្រះសុក្កោទនៈ ១

- នាយឆន្នអាមាត្យ ១

- កាឡុទាយីអាមាត្យ ១

- សេះកណ្ឋករាជអាជនេយ្យ ១

- ដើមមហាពោធិព្រឹក្ស ១

- កំណប់ទ្រព្យទាំងបួន ១ ។

## (កំណប់ទាំង ៤)

-កំណប់ទ្រព្យមួយឈ្មោះ **សង្ខនិធិ** មានសំណុំមាត់មូលជុំវិញ ១ គាវុត ។

-មួយឈ្មោះ **ឯលនិធិ** មានសំណុំមាត់មូលជុំវិញកន្លះយោជន៍

-មួយឈ្មោះ **ឧបលនិធិ** មានសំណុំមាត់មូលជុំវិញ ៣ គាវុត ។

-មួយឈ្មោះ **បុណ្ឌរិកនិធិ** មានសំណុំមាតមូលជុំវិញ ១យោជន៍ ជម្រៅរហូតដល់ ទីបំផុតនៃផែនដីដូចគ្នាទាំង ៤ ។

ក្នុងកាលនោះ ពួកខត្តិយទាំងពីរនគរ ក៏កើតបីតិសោមនស្ស ហើយក៏យាងព្រះមហាបុរស ព្រមទាំងព្រះមាតា ត្រឡប់ចូល ទៅក្នុងក្រុងកបិលវត្ថុបុរីវិញ ។



## (ចប់គព្ភាភិនិក្ខមនបរិច្ឆេទទី៤)

✵✵✸✸✵✵

# ( លក្ខណបរិគ្គហណបរិច្ឆេទទី៥ )

ក្នុងថ្ងៃដែលបរមពោធិសត្វ ប្រសូតនោះ ទេវតាទាំងឡាយ ដែលនៅក្នុងតាវត្តឹង្សពិភព មានសម្តេចអមរិន្ទ្រាធិរាជ ជាដើម មានព្រះទ័យត្រេកអរ ចរចាដល់គ្នា និង គ្នាថា " ព្រះរាជបុត្រ របស់ព្រះបាទសិរិសុទ្ធោទនៈមហារាជ ដែលប្រសូតនោះ នឹងបានត្រាស់ជា ព្រះសព្វញ្ញុពុទ្ធ ទ្រង់សម្តែងធម្មចក្រ , យើងនឹងបានឃើញ នូវព្រះពុទ្ធមិនខានឡើយ " ទើបទេវតាទាំងឡាយ បបួលគ្នាថ្វាយពរស័ព្ទសាធុការ ធ្វើសក្ការបូជាច្រើនក្រៃលែង ទូទៅទាំងទេវលោក ។

ក្នុងសម័យនោះ តាបសឈ្មោះ***កាឡទេវិល*** ជាអ្នកបាននូវ**អដ្ឋសមាបត្តិ** មានឫទ្ធិច្រើនជា**ជីតុន**[១] ព្រះបាទសិរីសុទ្ធោទនៈ បានឮពាក្យទេវតាដូច្នោះ ក៏ចេញចាកទិវាវិហារ ចុះចាកទេវលោក មកកាន់សំណាក់ព្រះបាទសិរីសុទ្ធោទនៈ ដល់ហើយក៏ថ្វាយព្រះពរសួរថា បុត្រមហារាជប្រសូតហើយឬ? អាត្មាភាពចង់ឃើញ , ព្រះរាជាទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យនាំព្រះរាជបុត្រមក ដើម្បីថ្វាយបង្គំតាបស ។

ខណៈនោះ ព្រះបាទទាំងពីរ នៃព្រះបរមពោធិសត្វ ក៏ត្រឡប់ទៅជាប្រតិស្ឋានលើ**ជដា** (ផ្នួងសក់តាបស) ទៅវិញ

***១.ជីតុន*** . ពាក្យក្រហស្ថ ហៅអ្នកបួសដែលជាញាតិ ឬ ដែលស្និតស្នាល ដោយបានផ្គត់ផ្គង់នូវបច្ច័យ ៤

តាបសឃើញហេតុជាអស្ចារ្យ ក៏ក្រោកចាកអាសនៈ ធ្វើអញ្ជលីទូលព្រះបាទ ព្រះមរបពោធិសត្វ ។



ព្រះវររាជបិតាទតឃើញហើយ ក៏ធ្វើអភិវន្ទនាការ ព្រះរាជឱរស ដោយសេចក្ដីសម្គាល់ថា ដូចជាមហាព្រហ្ម ។ តាបសក៏ពិចារណាបានឃើញថា ព្រះរាជកុមារនេះ នឹងបានត្រាស់ជាព្រះពុទ្ធ មិនមានសង្ស័យឡើយ ។ លុះដឹងដូច្នោះហើយ ក៏សើចហើយត្រឡប់ជាយំវិញ , មនុស្សទាំងឡាយសួរហេតុនោះ ។ ទើបតាបសប្រាប់ហេតុនោះថា ដែលអាត្មាសើចនោះ ដោយសេចក្ដីត្រេកអរ នឹងព្រះអយ្យ

បុត្របានត្រាស់ជាព្រះពុទ្ធ , ដែលអាត្មាឃំនោះ ដោយគំនិតគិតអាណិតខ្លួនឯងថា ជាមនុស្សឥតភ័ព្វមិនបានទាន់ព្រះអយ្យបុត្រ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ។

លំដាប់នោះ តាបសពិចារណាតទៅទៀត ក៏បានឃើញ**នាឡក:** ជាក្មួយថានឹងបានទាន់ , ទើបថ្វាយព្រះពរលាទៅកាន់សំណាក់ប្អូនស្រីនៃខ្លួន ដល់ហើយក៏ឲ្យហៅ**នាឡក:**កុមារមក, កាលបើនាឡកកុមារមកដល់ហើយ, តាបសប្រាប់ថា " **ម្នាលបានាឡក: ព្រះរាជឱរសនៃព្រះបាទសិរិសុទ្ធោទន: នឹងបានត្រាស់ជាព្រះពុទ្ធ, បាឯងនឹងបានទាន់ព្រះអង្គ ចូរបាឯងបួសក្នុងថ្ងៃនេះចុះ** " ។ នាឡក:កុមារបានស្តាប់ពាក្យឪពុកធំ ហើយក៏ទទួលព្រម ទើបផ្គងអញ្ជលីឆ្ពោះ ទៅរកព្រះបរមពោធិសត្វថា " **បុរសឯណាជាឧត្តមបុគ្គលក្នុងលោក បព្វជ្ជារបស់ខ្ញុំ ឧទ្ទិសចំពោះបុរសនោះ** " ហើយឲ្យគេកោរសក់ និងពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ប្រកបាត្រក្នុងស្នោក ស្ពាយចូលទៅនៅធ្វើសមណៈធម៌ ក្នុងព្រៃហេមពាន្ត ។

ចំណែកតាបសនោះ លុះធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងអរូបភព ។

## (ព្រាហ្មណ៍៨រូបទាយលក្ខណៈថ្វាយព្រះនាម)



ព្រះបរមពោធិសត្វប្រសូតបាន ៥ ថ្ងៃ ព្រះវររាជបិតាទ្រង់ថ្វាយព្រះនាមដល់ព្រះពោធិសត្វ ទើបបានតាក់តែងរាជនិវាសន៍ បានរោយរាយបុប្ផជាតិ មានលាជជាគម្រប់ប្រាំ ព្រះរាជាឲ្យរៀបចំតាក់តែងខត្តិយ និងព្រាហ្មណ៍សេនាប្រមុខ អាមាត្យក្នុងរាជនិវេសន៍ ព្រះរាជាទ្រង់ឲ្យអញ្ជើញ-ព្រាហ្មណ៍ ១០៨ នាក់ មកគង់លើអាសនៈ អង្គាសដោយភត្តាហារដ៏ប្រណិតស្រេច ហើយបញ្ជូនទៅ នូវមធុបាយាស

ទើបទ្រង់ឲ្យប្រជុំទុកតែព្រាហ្មណ៍ ៨ នាក់ ដែលមាននាមប្រាកដគឺ:

| | | | |
|---|---|---|---|
| រាមព្រាហ្មណ៍ | ១ | លក្ខណៈព្រាហ្មណ៍ | ១ |
| យញ្ញព្រាហ្មណ៍ | ១ | ធជព្រាហ្មណ៍ | ១ |
| សុភោជព្រាហ្មណ៍ | ១ | សុទត្តព្រាហ្មណ៍ | ១ |
| សុយាមព្រាហ្មណ៍ | ១ | កោណ្ឌញ្ញព្រាហ្មណ៍ | ១ |

ព្រាហ្មណ៍ទាំងឡាយនោះ សុទ្ធតែជាអ្នកចេះចាំស្ទាត់នូវក្នុងត្រៃវេទ ជាងព្រាហ្មណ៍ទាំងពួង ។ ព្រាហ្មណ៍ទាំងឡាយ ៧ នាក់ លើកម្រាមដៃពីរ ហើយទាយថា"ព្រះរាជកុមារប្រកបលក្ខណៈ ៣២ ប្រការ, បើព្រះរាជកុមារនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រ តែបើទ្រង់បព្វជ្ជានឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក" ។ ចំណែកឯ **កោណ្ឌញ្ញព្រាហ្មណ៍** ដែលក្មេងជាងគេ លើកតែម្រាមដៃមួយទាយថា ព្រះរាជកុមារ ពុំនៅគ្រប់គ្រងផ្ទះទេ ពិតជានឹងបានត្រាស់ជា ព្រះពុទ្ធពិតប្រាកដ ។

## (ចប់លក្ខណបរិគ្គហាណបរិច្ឆេទទី៥)

❋❋❋❋❋❋❋

## ( រាជាភិសេកបរិច្ឆេទទី៦ )

ក្នុងគ្រានោះ ពួកព្រាហ្មណ៍ទាំងឡាយ បានថ្វាយព្រះនាមដល់ព្រះបរមពោធិសត្វថា "**សិទ្ធត្ថ**" មានន័យថា:" **ជាអ្នកញុំាងប្រយោជន៍គ្រប់យ៉ាង អោយសម្រេចដល់សត្វលោកទាំងពួង** " ។

លុះក្រោយមក ព្រះបរមពោធិសត្វបាននាមថា **គោតម** ដោយអំណាចនៃ**គោតមគោត្រ** ។ ព្រះវររាជបិតាទ្រង់សួរព្រាហ្មណ៍ទាំងឡាយថា បុត្ររបស់យើងឃើញអារម្មណ៍ដូចម្ដេចទើបចេញទៅបួស ?



ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា ព្រះរាជបុត្ររបស់ព្រះអង្គឃើញនិមិត្ត ៤ យ៉ាង គឺ

**មនុស្សចាស់ ១ មនុស្សឈឺ ១**

**មនុស្សស្លាប់ ១ និងអ្នកបួស ១**

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ ក្រាបទូលហើយ ទើបបង្គាប់រអាមាត្យថា **តាំងអំពីថ្ងៃនេះទៅ អ្នកទាំងឡាយ កុំឲ្យមនុស្សមានសភាពយ៉ាងនេះ ចូលមកកាន់ទីជិតកូនយើងឡើយ ។** ហើយទ្រង់តាំងទុកនូវការរក្សាចម្ងាយមួយគាវុត ៗ ក្នុងទិសទាំង ៤ ដើម្បីមិនឲ្យមនុស្សមានសភាពដូច្នេះ ចូលទៅត្រង់វង់ចក្ខុ របស់ព្រះរាជកុមារ ។

លំដាប់នោះឯង ព្រាហ្មណ៍ទាំងឡាយនោះ ផ្ដាំបុត្ររបស់ខ្លួនថា យើងចាស់ហើយ! ព្រះរាជឱរស ព្រះបាទសុទ្ធោទនៈ គង់នឹងបានត្រាស់ជា ព្រះសព្វញ្ញុពុទ្ធយើងមិនទាន់ទេ កាលបើព្រះរាជឱរសនោះ ទ្រង់បព្វជ្ជាបានត្រាស់ជាព្រះពុទ្ធ ហើយអ្នកទាំងឡាយ បួសក្នុងសំណាក់ព្រះពុទ្ធនោះចុះ ។ ព្រាហ្មណ៍ទាំង ៧ នាក់នោះឋិតនៅជរាបដល់អស់អាយុ ហើយក៏ទៅកើតតាមយថាកម្មរបស់ខ្លួនទៅ ។

ចំណែកខាងកោណ្ឌញ្ញព្រាហ្មណ៍ មិនមានរោគព្យាធិក៏ឋិតនៅឡើយ ។ ចំណែកពពួកញាតិ ប៉ែតសិបពាន់ពីរដង ក៏ប្ដេជ្ញាគ្នាថា ព្រះសិទ្ធត្ថរាជកុមារនេះ បានត្រាស់ជាព្រះពុទ្ធក្ដី បានជាស្ដេចចក្រពត្តិក្ដី យើងនឹងថ្វាយបុត្រម្នាក់ៗ គ្រប់ៗគ្នា ។

## ព្រះនាងសិរិមហាមាយាសោយទិវង្គត



ចំណែកព្រះនាងសិរិមហាមាយា រាប់អំពីថ្ងៃប្រសូតព្រះបរមពោធិសត្វបាន៧ ថ្ងៃ ព្រះនាងក៏សោយវិលាល័យ[១] ទៅកើតក្នុង**តុសិតពិភព** ។

**១.វិលាល័យ:** អគ្គមហេសី(ក្សត្រិយ៍) ទ្រង់រាជអស់ព្រះជន្ម , ដំណើរស្លាប់ទៅកើតស្ថានសួគ៌

ព្រះនាងសោយវិលាល័យនោះ ដោយហេតុដែលប្រសូតព្រះពោធិសត្វ ក៏ទេគឺពិតជាដោយអស់ព្រះជន្ម ។

ឯព្រះនន្ទកុមារ ក្មេងជាងព្រះបរមពោធិសត្វពីរបីថ្ងៃ កាលនន្ទកុមារប្រសូតមក , ព្រះនាងបជាបតិគោតមី បានឲ្យមេនំបំបៅព្រះនន្ទកុមារ ព្រះនាងសោតក៏សម្រេចកិច្ចជាមេនំបំបៅព្រះបរមពោធិសត្វ ជាលំដាប់រៀងមក ។ ក្នុងកាលថ្ងៃមួយជា ខាងក្រោយមក ព្រះរាជាទ្រង់រាជបញ្ជាឲ្យអាមាត្យតាក់តែងព្រះនគរ កាលទ្រង់ស្តេចទៅកាន់ទីច្រត់ព្រះនង្គ័ល ព្រះអង្គឲ្យនាំព្រះរាជឱរសទៅផង ទ្រង់ទៅជាមួយពួកព្រាហ្មណ៍ និង គហបតីអាមាត្យទាំងពួង ។

ក្នុងទីជិតកសិដ្ឋាននោះ មានដើម***ជម្ពូព្រឹក្ស*** (ដើមព្រីង) ១ ដើម មានមែក និង ស្លឹកក្រាស់ជិត មានសណ្ឋានដូចជាមណ្ឌប ។ ព្រះរាជាទ្រង់ឲ្យរៀបចំ ទីសយនាថ្វាយពោធិសត្វផ្ទំក្រោមដើមព្រីងនោះ ទើបស្តេចយាងច្រត់ព្រះនង្គ័ល មេនំទាំងឡាយ ឲ្យព្រះពោធិសត្វផ្ទំ ហើយក៏បបួលគ្នាទៅមើល មហាក្សត្រស្តេចច្រត់ព្រះនង្គ័ល ។

ព្រះបរមពោធិសត្វ ទ្រង់ទតមិនឃើញអ្នកណាមួយសោះ ក៏តើនចាកសយនាគង់ផ្គត់ព្រះភ្នែន កំណាត់យកអានាបាស្សតិ ញ៉ាំងបឋមជ្ឈានឲ្យកើតឡើង ។

# ព្រះពោធិសត្វបានសម្រេចបឋមឈាន

## *ក្រោមដើមព្រីង ក្នុងថ្ងៃច្រត់ព្រះនង្គ័លព្រះជន្ម ៧ វស្សា*

## *ព្រះបិតាបានថ្វាយបង្គំលើកទីពីរ*



ក្នុងកាលនោះឯង ស្រាប់តែស្រមោលឈើទាំងឡាយឯទៀតជ្រេទៅ, ឯស្រមោលដើមព្រីងនោះ នៅមូលផ្តុំឥតជ្រេឡើយ ។ មេនំត្រឡប់មកវិញបាន ឃើញព្រះពោធិសត្វគង់លើសយនា ទើបទៅក្រាបបង្គំទូលដល់ព្រះរាជា ។

លំដាប់នោះ ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់យាងមក ឃើញ នូវបាដិហារ្យដ៏អស្ចារ្យនោះ ***ទ្រង់ក៏ថ្វាយបង្គំព្រះរាជបុត្រ របស់ព្រះអង្គម្តងទៀតជា លើទីពីរ*** ។

ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ប្រត់ព្រះនេត្តលរួចស្រេច ហើយ, លុះសាយណ្ហសម័យ ទ្រង់នាំពោធិសត្វចូលកាន់ នគរវិញ ។ ហើយព្រះរាជា ទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យ កសាងប្រាសាទថ្វាយព្រះសិទ្ធត្ថកុមារ ។



ព្រះបរមពោធិសត្វ ចម្រើនព្រះជន្មបាន ៧ វស្សា ព្រះរាជាទ្រង់ត្រាស់សួរ អាមាត្យទាំងឡាយថា **ក្មេងអាយុ ៧ ឆ្នាំ ស្រឡាញ់របស់អ្វី ?** អាមាត្យក្រាបបង្គំទូលថា **ក្មេងអាយុ ៧ ឆ្នាំ ចូលចិត្តលេងទឹក** ទើបព្រះរាជាទ្រង់ឲ្យជីកស្រះបោក្ខរណីថ្វាយ ព្រះបរមពោធិសត្វ ។

ខណៈនោះ ក៏ក្ដៅទៅដល់អាសនៈ សម្ដេចអមរិន្ទ្រាធិរាជ ទើបស្ដេចត្រាស់ ប្រើវិស្សកម្មទេវបុត្រ មកនិម្មិតស្រះថ្វាយ ។ វិស្សកម្មទេវបុត្រ ចុះមកនិម្មិតស្រះបោក្ខរណីប្រកបដោយកែវ ៧ ប្រការ ។





ចាប់ដើមពីកាលនោះមក ព្រះបរមពោធិសត្វក៏យាង ទៅក្រសាល ក្នុងស្រះបោក្ខរណី ជាលំដាប់ដរាបដល់ ព្រះជន្ម ១៦ វស្សា ទើបព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ឲ្យជាង កសាងប្រាសាទ ៣ សមគួរដល់រដូវទាំង ៣ គឺៈ

**-ប្រាសាទ ១ មានជាន់ ៩ សមគួរដល់ហេមន្តរដូវ**

**-ប្រាសាទ ១ មានជាន់ ៧ សមគួរដល់គិម្ហរដូវ**

**-ប្រាសាទ ១ មានជាន់ ៥ សមគួរដល់វស្សានរដូវ ។**

លុះដល់ កសាងរួចស្រេចហើយ ព្រះរាជាទ្រង់បាន បញ្ជូនព្រះរាជបណ្ដាំ ដល់ស្ដេចសក្យរាជទាំងឡាយ ឲ្យ បញ្ជូនព្រះរាជធីតាមកថ្វាយ ។ ស្ដេចសក្យរាជទាំងឡាយ

បានតបមកវិញថា ព្រះរាជបុត្តរបស់ព្រះអង្គ គ្រាន់តែមានរូបរាងល្អ តែពុំចេះសិល្បសាស្ត្រអ្វីសោះ ។ ព្រះបាទសិរីសុទ្ធោទនៈទ្រង់ជ្រាប ហើយក៏យាងទៅកាន់សំណាក់ព្រះរាជបុត្រ ប្រាប់តាមដំណើរនោះ ។

ព្រះបរមពោធិសត្វតបថា " សូមព្រះវររាជបិតាកុំព្រួយឡើយ " សូមទ្រង់ប្រជុំពួកញាតិចុះ ខ្ញុំព្រះអង្គ នឹងសម្តែងសិល្បៈថ្វាយ ។



# ស្តេចសក្យរាជទាំងឡាយ នាំខត្តិយកញ្ញាមកថ្វាយព្រះបរមពោធិសត្វ

ស្តេចសក្យរាជទាំងឡាយ មានការកោតខ្លាចហើយ ទើបរៀបចំ ប្រដាប់រាជធីតារបស់ខ្លួន បញ្ជូនមកថ្វាយព្រះបរមពោធិសត្វ ។ ខត្តិយកញ្ញា ដែលសក្យរាជទាំងអស់ មានចំនួន ៤ ម៉ឺនអង្គ ។



## ( ព្រះអង្គទ្រង់រាជាភិសេក )

ក្នុងកាលនោះ ព្រះវររាជបិតា ទ្រង់បានរៀបចំរាជាភិសេក ព្រះបរមពោធិសត្វ ជាមួយនឹងព្រះនាងពិម្ពាយសោធរា ជាអគ្គមហេសី ក្នុងរាជ្យសម្បត្តិនាឆ្នាំឆ្លូវ ។



ព្រះបរមពោធិសត្វ ទ្រង់រៀបអភិសេក និងគ្រងរាជ្យ **នៅថ្ងៃអាទិត្យ ១៥ កើត ខែ កត្តិត ឆ្នាំ ឆ្លូវ ក្នុងជន្មាយុ ១៦ ព្រះវស្សា ។** ព្រះបរមពោធិសត្វ គង់នៅក្នុងប្រាសាទទាំង ៣ ដ៏សមគួរដល់ឧតុកាល ។

(ចប់រាជភិសេកបរិច្ឆេទទី៦)

✲✲✲✲✲✲✲

# ( មហាភិនិក្ខមនបរិច្ឆេទទី៧ )



ក្នុងសម័យថ្ងៃមួយ ជាខាងក្រោយមក ព្រះបរមពោធិសត្វ ទ្រង់សព្វព្រះរាជហឫទ័យ និង យាងទៅក្រសាលឧទ្យា ទ្រង់ឲ្យនាយសារថីទឹមសេះសិន្ធព[១] ជាមង្គលពីរគូរស្រេច ហើយព្រះមហាបុរស ទ្រង់ឡើងគង់លើរាជរថ មានពួកសេនាអាមាត្យចោមរោមជាបរិវារ ស្ដេចទ្រង់ទៅកាន់ឧទ្យាន ។

១.*សេះសិន្ធព:* គឺសេះមានពូជពីដែនសិន្ធវៈ ហើយមានល្បឿនឆាប់ទាន់ចិត្ត

លំដាប់នោះ ***សុទ្ធាវាសទេវបុត្រ*** មកនិម្មិតជា ***មនុស្សជរា*** ដើរទៅពីមុខ , ព្រះបរមពោធិសត្វ និង សារថីបានឃើញ ព្រះមហាបុរសក៏សួរ នាយសារថី ៗ ក្រាបទូលសព្វគ្រប់ ប្រការ ព្រះអង្គមានសេចក្ដីសង្វេគ ទើបទ្រង់យាងត្រឡប់ មកវិញ ។

លុះថ្ងៃក្រោយមក ស្ដេចទ្រង់យាងទៅម្ដងទៀត បាន ជួប និង ***មនុស្សព្យាធិ*** ឈឺបម្រះនឿល , ស្ដេចទ្រង់យាងទៅ ជាគម្រប់បីដងក៏ឃើញ ***មនុស្សស្លាប់*** ។ ព្រះអង្គទ្រង់សាក សួរ នាយសារថី ៗ ក៏ក្រាបបង្គំទូលសព្វគ្រប់ តាមដំណើរ ក្នុងពេលនោះ ទ្រង់សង្វេគក៏យាងត្រឡប់វិញ ។ ក្រោយមក ទៀត ព្រះពោធិសត្វ ទ្រង់យាងទៅជាគម្រប់ ៤ ដង បាន ឃើញ ***បព្វជិត*** ទ្រង់ក៏ត្រាស់សួរសារថី ៗ ក៏ក្រាបទូលសព្វ ប្រការ ។ នាយសារថី ដែលក្រាបទូលនូវ***ទេវទូត***ទាំង ៤ បានដោយអំណាចនៃ***សុទ្ធាវាសទេវតា*** បញ្ជូនចិត្ត ។ នៅពេល ព្រះបរមពោធិសត្វ ទ្រង់បានព្រះសណ្ដាប់ ហើយក៏មាន ព្រះរាជហឫទ័យសោមនស្ស ក្នុងភេទបព្វជ្ជា ទើបស្ដេច យាងទៅ ក្រសាលឧទ្យានដល់ហើយ ទ្រង់ក៏ចុះស្រង់ទឹក ក្នុងស្រះបោក្ខរណីជាមង្គល ស្រេចហើយទ្រង់យាងឡើង មកគង់លើផែនសីលា ។

ខណៈនោះ ទ្រង់មានសេចក្ដីប្រាថ្នា ប្រដាប់ដោយគ្រឿងប្រដាប់, ***វិស្សកម្មទេវបុត្រ*** ក៏ក្លែងភេទជា ខ្មាន់ព្រះកេសាមកប្រដាប់ថ្វាយ ។ ព្រះបរមពោធិសត្វ ស្ដេចទៅកាន់ឧទ្យានម្ដង ៗ កន្លងទៅ ៤ ខែ ។ ព្រោះព្រះបរមពោធិសត្វនៃយើងមានព្រះជន្មតិច និង ឧបនិស្ស័យមិនទាន់ដល់ ។



ក្នុងសម័យកាលនោះ ព្រះនាងពិម្ពាយសោធរា ក៏ប្រសូតព្រះរាជបុត្រគឺ "***រាហុលកុមារ***" ព្រះបាទសិរីសុទ្ធោទនៈបញ្ជូនអាមាត្យ ឲ្យទៅក្រាបទូលដល់បរមពោធិសត្វ ។

កាលបើអាមាត្យ ទៅក្រាបបង្គំទូល តាមព្រះរាជបណ្តាំ ហើយទ្រង់មានព្រះរាជឱង្ការថា" ***រាហុលកុមារជាចំ-ណងធំ ប្រសូតហើយ*** " ។ ទើបព្រះអង្គឡើងគង់លើរាជរថត្រឡប់ទៅ ដល់រាជនិវេសន៍ក្នុងពេលនោះ ។ លំដាប់បន្ទាប់មក ទ្រង់ក៏បានព្រះសណ្តាប់នូវគាថា ដែលព្រះនាង***កេសាគោតមី*** ពោលថា:

***និព្វុតានូនសាមាតា និព្វុតោនូនសោបិតា***

***និព្វុតានូនសានារី យស្សាយំ ឦទិសោបតិ***

***ព្រះសិទ្ធត្ថអង្គនេះ បើបានជាបុត្រនៃព្រះមាតាណា ព្រះមាតានោះ រលត់ទុក្ខដោយពិត, បើបានជាបុត្រនៃបិតាណា ព្រះបិតានោះ រលត់ទុក្ខដោយពិត, បើបានជាប្តីនៃនារីណា នារីនោះ រលត់ទុក្ខដោយពិត ។***

ព្រះបរមពោធិសត្វ នូវពេលបានព្រះសណ្តាប់ ហើយក៏មានព្រះហឫទ័យសោមនស្ស ទ្រង់ដោះកែវមុក្តាហារ អំពីព្រះសូរង់បញ្ជូនទៅ ព្រះរាជទានដល់ ព្រះនាងខត្តិយកញ្ញានោះ ។ ព្រះមហាបុរស ទ្រង់យាងឡើងលើប្រាសាទសោយស្រេច ហើយទើបទ្រង់យាងចូលទៅកាន់ ទីសេយ-នា ក្រឡាព្រះបន្ទំ ស្តប់ស្តល់អស់បឋមយាម ។

ព្រះបរមពោធិសត្វ ទតឃើញវិការៈ នៃស្រីរបាំដូចជាសាកសពនាង**នាដកិត្តី** (ស្រីរបាំ) ដែលប្រគំតូរ្យតន្ត្រីលេង

ប្រគំដេកលក់ទៅ ក៏សម្ដែងវិប្បការៈផ្សេង ៗ មានដេកអាក្រាតកាយជាដើម ។





លុះដល់មជ្ឈិមយាម ព្រះបរមពោធិសត្វ ទ្រង់តើនឡើងក៏ទតឃើញវិប្បការៈ នៃស្រីរបាំក៏មានសេចក្តីសង្វេគ ព្រោះក្នុងទីប្រាសាទ ដូចជាពាសពេញដោយ សាកសព ទើបទ្រង់ដាស់ឆន្នអាមាត្យ ឲ្យទៅនាំយកសេះ***កណ្ឋកអាជានេយ្យ*** មកព្រះអង្គក៏យាងចូលទៅក្នុងបន្ទប់ ប្រាថ្នានឹងលើកបីព្រះរាជបុត្រ ទ្រង់ឃើញព្រះនាង***យសោធរាពិម្ពា*** ផ្ទំដាក់ព្រះហស្តគង់លើព្រះរាជឱរស ព្រះអង្គយាងចេញមកវិញដោយទ្រង់ព្រះចិន្តាថា "***គ្រាក្រោយសឹមមកឃើញមុខកូន***" ទ្រង់ក៏យាងចុះពីប្រាសាទ ។



# ( ព្រះអង្គទ្រង់យាងបព្វជ្ជា )

ក្នុងកាលនោះ ឆន្នអាមាត្យបានរៀបចំសេះចាំស្រេច ព្រះបរមពោធិសត្វ ក៏ឡើងគង់លើខ្នងសេះ **អាជនេយ្យ** មានខ្លួនប្រវែង ១៨ ហត្ថ ព្រះអង្គទ្រង់ត្រាស់ ឲ្យឆន្នអាមាត្យតោងកន្ទុយ ។



ព្រះអង្គយាងចាកពជនិវេសន៍ ទៅដល់ខាងក្រៅនគរ ទ្រង់បែរទតមកមើលនគរវិញ ។ ទីកន្លែងនោះឈ្មោះថា "**អនិវត្តនចេតិយ**" ។

# មារឃាត់ព្រះអង្គមិនឲ្យទៅបព្វជ្ជា



ខណៈនោះ មារមានចិត្តបាបដឹងហេតុ ហើយចុះចាកទេវលោក មកឋិតនៅក្នុងអាកាស ពោលឃាត់ថា ***នែសទ្ធត្ថ! អ្នកកុំចេញទៅបួសឡើយនៅតែ ៧ ថ្ងៃទៀត សម្បត្តិចក្រពត្តិ នឹងមកដល់អ្នកហើយ*** ។ ព្រះបរមពោធិសត្វតបថាយើងដឹងហើយ យើងមិនអាល័យទេ, មារចិត្តបាបក៏ចៀសចេញទៅ ។

# ( ព្រះអង្គទ្រង់កាត់ព្រះកេសី )



ព្រោះគ្រានោះ ព្រះពោធិសត្វ មានទេវតាចោមរោមជាបរិវារ ព្រះអង្គក៏យាងរំលងនគរទាំង ៣ គឺ ***នគរកបិលវត្ថុ ១***, ***សាវត្ថី ១ វេសាលី ១*** អស់ផ្លូវចម្ងាយ ៣០ យោជន៍ ទៅដល់ ***ស្ទឹងអនោមា*** ទ្រង់សួរឆន្នអាមាត្យគ្រប់ប្រការ ព្រះអង្គក៏បរសេះឆ្វេងទៅត្រើយនាយ ខ្វាចព្រះវរបិតាឲ្យគេទៅតាម ។



គ្រានោះឯង ព្រះបរមពោធិសត្វ ទ្រង់ចុះចាកខ្នងកណ្ឋកៈ គង់លើផ្នូកខ្សាច់ ហើយត្រាស់បង្គាប់ឲ្យឆន្នអាមាត្យ នាំសេះយកគ្រឿងប្រដាប់ ត្រឡប់មកនគរវិញ ដើម្បីថ្វាយដំណឹង ដល់ព្រះវរបិតា ។ នាយឆន្នអាមាត្យក៏នាំសេះទៅផុតទីនោះបន្តិច សេះក៏បែកហឫទ័យស្លាប់ដោយសេចក្ដីអាល័យព្រះអង្គ ហើយក៏បានទៅកើតក្នុងតាវត្តឹង្សពិភពឈ្មោះ ***កណ្ឋកទេវបុត្រ*** ។

ព្រះមហាបុរស ប្រាថ្នានឹងកាត់ព្រះកេសា ខណៈនោះ ***រតនខគ្គាវុធជាទិព្វ*** ក៏ធ្លាក់ចុះមកពីអាកាស ។ ព្រះអង្គកាត់ព្រះកេសា ទុកឲ្យសល់ប្រវែង ២ ធ្នាប់នោះ ក៏វិលជា

***ទក្ខិណាវដ្ត***[១]។ ទើបព្រះអង្គអធិដ្ឋាន***មោលី***[២] ហើយបោះទៅក្នុងអាកាស ព្រះឥន្ទក៏យកប្រអប់កែវមកដាក់ យកទៅបញ្ចុះទុកក្នុង ***ចូឡាមណីចេតិយ*** នាឋានតាវត្តឹង្ស ។

ព្រះបរមពោធិសត្វ ទ្រង់ព្រះចិន្តានឹករកត្រៃចីវរទៀតលំដាប់នោះ ***ឃដិការមហាព្រហ្ម*** ក៏នាំនូវគ្រឿងបរិក្ខា ៨ គឺ ***ចីវរ ៣, បាត្រ ១, កាំបិតកោរ ១ ,បំពង់ម្ជុល ១ , វត្ថពន្ធ ១ ដំរងទឹក ១, មកថ្វាយព្រះអង្គ ។***

ព្រះមហាបុរស ទ្រង់ទទួលគ្រឿងបរិក្ខារ ហើយសមាទាននូវទង់ព្រះអរិយៈ គឺ ទ្រទ្រង់ត្រៃចីវរ ទ្រង់បព្វជ្ជាស្រេចហើយ ទើបប្រទាននូវសំពត់ ១ គូ ដល់មហាព្រហ្ម ។ ***ឃដិកាមហាព្រហ្ម*** ទទួលយកទៅបញ្ចុះទុកក្នុង***ទុស្សចេតិយ*** កម្ពស់ ១២ យោជន៍ក្នុង***ព្រហ្មលោក*** ។ ព្រះបរមពោធិសត្វ ដែលយាងចេញសាងបព្វជ្ជានោះ ព្រះជន្ម ២៩ ឆ្នាំ ចេញទៅក្នុងវេលាមជ្ឈិមយាម ***ថ្ងៃព្រហស្បតិ៍ បុណ្ណមី ខែអាសាឍ ឆ្នាំឆ្លូវ*** ។

១.***ទក្ខិណាវដ្តៈ*** *វិលទៅខាងស្តាំ,* ២.***មោលីៈ*** *កំពូលស្រួចពីលើព្រះសិរស៍*

(ចប់មហាភិនិក្ខមនបរិច្ឆេទទី៧)

✵✵✵✵✵

# ( ទុក្ករកិរិយាបរិច្ឆេទទី៨ )

នាយឆន្នអាមាត្យ ឃើញសេះ***កណ្ឋកៈ*** ស្លាប់ដូច្នោះហើយ ក៏កើតសេចក្តីទុក្ខទួញយំ , លុះបន្ទោបង់នូវសេចក្តីសោក ហើយក៏ស្រាយគ្រឿងប្រដាប់ អំពីសេះកណ្ឋកៈ វេចជាបង្វេចស្ពាយដើរទៅ, លុះទៅដល់***នគរកបិលវត្ថុ*** ហើយក៏នាំគ្រឿងប្រដាប់ទាំងនោះ ទៅថ្វាយព្រះបាទសិរីសុទ្ធោទនៈ ហើយក្រាបទូល តាមបណ្តាំព្រះបរមពោធិសត្វ ។ ចំណែកកោណ្ឌញ្ញព្រាហ្មណ៍បានដឹងថា មហាបុរសចេញសាងបព្វជ្ជា ទើបបបួលកូនព្រាហណ៍ទាំង ៧ នាក់ ដែលទាយលក្ខណៈ ព្រះមហាបុរស ។ ចំណែកកូនព្រាហ្មណ៍មិនព្រម-



ចិត្តគ្នាទាំង ៧ នាក់ឡើយព្រមតែ ៤ នាក់ រួមទាំងកោណ្ឌញ្ញព្រាហ្មណ៍ម្នាក់ទៀតផងត្រូវជា ៥ នាក់ នាំគ្នាចេញទៅសាងបព្វជ្ជាមានឈ្មោះថា **បញ្ចវគ្គីយ៍** ។



ព្រះបរមពោធិសត្វ ទ្រង់បព្វជ្ជា ហើយក៏យាងទៅគង់ក្នុង**អនុបិយម្ពវ័ន** ទ្រង់មិនសោយអាហារអស់ ៧ ថ្ងៃ ព្រះអង្គញុំាងកាលឲ្យប្រព្រឹត្តកន្លងទៅ ដោយសេចក្តីសុខក្នុងភេទបព្វជ្ជា ។ លុះដល់ថ្ងៃជាគម្រប់ ៨ ព្រះមហាបុរស ទ្រង់ប្រដាប់ដោយបាត្រ និងចីវរស្តេចយាងសំដៅទៅ **នគររាជគហៈ** ដើម្បីបិណ្ឌបាត ។

# ព្រះអង្គទ្រង់យាងបិណ្ឌបាត



មនុស្សក្នុងនគរ បានឃើញព្រះបរមពោធិសត្វ មានរូបល្អ ក៏មានចិត្តត្រេកអរ សោមនស្សរីករាយ ត្រេកអរគ្រប់គ្នា ។ ចំណែករាជបុរស បានឃើញព្រះបរមពោធិសត្វ ក៏ទៅក្រាបបង្គំទូល ព្រះបាទពិម្ពិសារថា " បពិត្រព្រះសម្មតិទេព " មានមនុស្សម្នាក់មានរូបល្អចំណាប់ ខ្ញុំព្រះអង្គពុំស្គាល់ថា **ជាទេវតា ឬគ្រុឌ គន្ធព្វ ឬយក្ស ឬក៏នាគទេ**

ត្រេចចរបិណ្ឌបាតក្នុងនគរ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យរាជបុរសក្រាបបង្គំទូល ហើយក៏ទ្រង់បើក**សីហបញ្ជរ**[១] ទតទៅឃើញបរមពោធិសត្វ ទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យរាជអាមាត្យទៅចាំឃ្លាំមើល ។

## ព្រះអង្គទ្រង់ដាក់ប្ដាជ្ញា និង ព្រះបាពិម្ពិសារ



ព្រះមហាបុរស មានឥន្ទ្រីយសង្រួមល្អប្រពៃ ត្រេចចរបិណ្ឌបាត , លុះបានភត្តាហារល្មមមួយចំអែក ទ្រង់យាងចេញចាកនគរ ទៅគង់ក្នុងញកភ្នំ***បណ្ឌវបព៌ត*** ប្រារព្ធនឹង

សោយកត្តាហារ ដោយ**បដិកូលសញ្ញា** ទូន្មាននូវខ្លួនហើយ ទើបព្រះអង្គធ្វើនូវភត្តកិច្ច ។ រាជបុរសដែលតាមមើលនោះ ពេលដែលបានឃើញ ព្រះបរមពោធិសត្វ សោយកត្តា-ហារក្នុងញកភ្នំ ក៏ទៅក្រាបបង្គំទូល ព្រះបាទពិម្ពិសារវិញ តាមដំណើរសព្វគ្រប់ប្រការ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ នូវហេតុនោះហើយ ទើបព្រះអង្គយាងទៅកាន់ សំណាក់ព្រះមរបពោធិសត្វ ទ្រង់សាកសួរអំពីជាតិត្រកូល ។

ព្រះបរមពោធិសត្វ ទ្រង់ក៏ថ្វាយព្រះពរសព្វគ្រប់ប្រការ ព្រះបាទពិម្ពិសារមហារាជជ្រាប ហើយក៏យាងបរមពោធិសត្វ ដោយប្រគល់រាជ្យសម្បត្តិ ឲ្យពាក់កណ្ដាល ។ ព្រះបរមពោធិសត្វ មិនព្រមទទួល ព្រះរាជាទ្រង់ប្ដេជ្ញាជាមួយនឹងព្រះបរមពោធិសត្វថា "**បើព្រះអង្គបានត្រាស់ហើយ សូមមកប្រោសញោមមុនផង**" ព្រះបរមពោធិសត្វ ក៏ទទួលសេចក្ដីប្ដេជ្ញា របស់ព្រះបាទពិម្ពិសារមហារាជ , ព្រះរាជាទ្រង់ក៏យាងចូលទៅក្នុងនគរវិញ ។ ព្រះបរមពោធិសត្វថ្វាយសេចក្ដីប្ដេជ្ញា ដល់ព្រះបាទពិម្ពិសារ ហើយព្រះអង្គទ្រង់ក៏យាងចាក**ភ្នំបណ្ឌវៈ** ទៅកាន់សំណាក់**អាឡារតាបសកាឡាមគោត្រ**, ទ្រង់ខំចម្រើនបានសមាបត្តិ ៧ ។ ទើបទ្រង់យាងទៅសំណាក់ **ឧទ្ទកតាបសរាមបុត្រ** ព្រះអង្គចម្រើនបាន

សម្រេចសមាបត្តិ ៨ ហើយព្រះអង្គសួរធម៌វិសេសតទៅទៀត ឧទ្ទកតាបសក៏ទាល់ ។ ទ្រង់ក៏សន្និដ្ឋានថា "ផ្លូវនេះមិនមែនជាផ្លូវត្រាស់ដឹងទេ " ទើបព្រះអង្គយាងទៅកាន់ **ឧរុវេលនិគម** ទ្រង់តាំងទុកនូវ**មហាបធាន** (កិរិយាព្យាយាមធំ) ក្នុងទីនោះ ។

## ព្រះអង្គយាងទៅសិក្សាក្នុងសំណាក់អាឡារតាបសកាឡាមគោត្រ



# ព្រះអង្គយាងទៅសិក្សាក្នុងសំណាក់ឧទកតាបសរាមបុត្ត



ក្នុងសម័យនោះ កោណ្ឌញ្ញព្រាហ្មណ៍ ដែលបានឃើញបានទាយលក្ខណៈមហាបុរស ហើយបបួលគ្នាទៅបួសនោះ ក៏ដើរត្រេចរកបិណ្ឌបាតក្នុងស្រុក និង និគមបាន

ទៅដល់ទីលំនៅ ព្រះបរមពោធិសត្វ ហើយក៏សុំបម្រើចំពោះព្រះអង្គ ។

# បញ្ចវគ្គីយ៍សុំបម្រើព្រះអង្គ



ព្រះបរមពោធិសត្វ ខំធ្វើបធានកិរិយាអស់ ៦ វស្សា មិនទាន់បានត្រាស់ ក៏ព្រះអង្គបន្ថយអាហារ ជាលំដាប់ ៗ ដរាបដល់ឥតសោយសោះ ។

# ព្រះអង្គបំពេញទុក្ករកិរិយា



ទេវតាក៏នាំយកឱជារសទិព្វមកដាក់ ក្នុងរណ្តៅនៃរោមព្រះពោធិសត្វ ៗ ខំព្យាយាមដរាប ដល់ដួលស្តូកស្តឹងលើផែនដី ។

ខណៈដែលព្រះអង្គដួលនោះ ទេវតាជា**មារកាយិកា** (បក្សពួកមារ) ឃើញព្រះពោធិសត្វដួល គិតស្មានជាព្រះអង្គសុគត ក៏ហោះទៅទូលព្រះបាទសុទ្ធោទនៈ ។

# ព្រះឥន្ទយកពិណមកដេញថ្វាយ



ព្រះរាជាទ្រង់មិនបានជឿ ចំណែកមារក៏ហោះចុះមក ពោលពាក្យចំអកចំអន់ផ្សេង ៗ ហើយត្រឡប់ទៅ ។ សម័យកាលនោះ សក្កទេវរាជយកពិណមក មានខ្សែធូរពេកមានសំឡេងមិនពិរោះ , ខ្សែរឹតតឹងពេកសំឡេងក៏មិនពិរោះ រឹតយ៉ាងកណ្តាល សំឡេងសោតក៏ពិរោះស្រួលល្អ ។ ព្រះអង្គមានស្មារតីឡើង ទ្រង់ពិចារណាថា "អាត្មាអញព្យាយាមតឹងពេកបានជាមិនបានត្រាស់" លុះដល់ថ្ងៃក្រោយមកទៀត ទ្រង់យាងបិណ្ឌបាត សោយអាហារតាមធម្មតាវិញ ។

# ព្រះអង្គមានឥន្ទ្រិយបរិបូរវិញ



ក្នុងពេលដែលព្រះអង្គ សោយនូវអាហារឡើងវិញ ទ្រង់ក៏មានឥន្ទ្រិយបរិបូរ ពេញលេញដូចដើមវិញ លំដាប់នោះ ឯបញ្ចវគ្គីយ៍ទាំងឡាយ បានឃើញព្រះមហាបុរស សោយភោជនាហារឡើងវិញដូច្នោះ ក៏គិតគ្នាថាព្រះសិទ្ធត្ថនេះ ខំធ្វើទុក្ករកិរិយាអស់ ៦ វស្សា មិនបានត្រាស់, ឥឡូវនេះ ត្រឡប់សោយកត្តាហារវិញហើយ កាលណានឹងបានត្រាស់, ប្រយោជន៍អ្វី! យើងនឹងនៅបម្រើទៀតនោះ ។

# បញ្ចវគ្គីយ៍គេចចេញពីព្រះអង្គ



បញ្ចវគ្គីយ៍មិនបានបិតនៅ ក្នុងការព្យាករណ៍របស់ខ្លួនក៏យកបាត្រត្រៃចីវរ ដើរចោលព្រះបរមពោធិសត្វ ទៅកាន់ផ្លូវចម្ងាយ ១៨ យោជន៍ បបួលគ្នាទៅនៅក្នុងព្រៃ***ឥសិបតនមិគទាយវ័ន ទៀប នគរពារាណសី*** តាមសេចក្តីសប្បាយ ។

# ព្រះអង្គទ្រង់សុបិននិមិត្ត



លំដាប់នោះ ព្រះបរមពោធិសត្វ ទ្រង់ឃើញមហាសុបិននិមិត្តទាំង ៥ ក្នុងវេលាបច្ចូសសម័យថ្ងៃ ១៥ កើត ខែវិសាខ , ឯសុបិននិមិត្តទាំង ៥ នោះ ដូច្នេះគឺៈ

# មហាសុបិននិមិត្តទី១



១-ព្រះអង្គឃើញមហាប្រឹថពីជា ទីសយនាក្រឡាបន្ទំ, ភ្នំហិមវន្តជាខ្នើយរងព្រះសិរ , ព្រះហស្តខាងឆ្វេងសណ្តូកចុះ ក្នុងមហាសមុទ្ទទិសបស្ចិម, ព្រះបាទទាំងពីរសណ្តូកចុះក្នុងមហាសមុទ្ទទិសទក្សិណ, នេះជាមហាសុបិនទី ១ ។

# មហាសុបិននិមិត្តទី២



២-ទ្រង់ឃើញស្មៅចិញ្ចៀន ដុះលេចពីព្រះ**នាភី**(ផ្ចិត) ឡើងទៅទល់និងអាកាស, នេះជាមហាសុបិនទី២ ។

# មហាសុបិននិមិត្តទី៣



៣.ព្រះអង្គទ្រង់ឃើញដង្កូវទាំងឡាយ ដែលមានខ្លួនស ក្បាលខ្មៅ វារឡើងពីចុងនៃព្រះបាទា ដរាបដល់ព្រះ**ជានុមណ្ឌល**(ជង្គង់ទាំងមូល) នេះជាមហាសុបិននិមិត្តទី៣ ។

# មហាសុបិននិមិត្តទី៤





៤-ព្រះអង្គទ្រង់ឃើញសត្វបក្សី ៤ ពួក មានវណ្ណៈផ្សេងៗ ហើរពីទិសទាំង ៤ មកក្រាបទៀបព្រះបាទា ហើយត្រឡប់ជាមានវណ្ណសទាំងអស់ , នេះជាមហាសុបិនទី ៤ ។

# មហាសុបិននិមិត្តទី៥



៥-ព្រះអង្គទ្រង់ឃើញថា ទ្រង់យាងចង្ក្រមលើភ្នំលាមកដ៏ធំ ព្រះបាទាមិនបានប្រឡាក់ ដោយលាមកឡើយ, នេះជាមហាសុបិនទី ៥ ។

ព្រះមហាបុរស ទ្រង់ឃើញមហាសុបិនទី ៥ នេះ ហើយព្រះអង្គតើនចាកទីសយនា ទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា "**អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ**" ព្រះអង្គទាយដោយព្រះអង្គឯងសព្វគ្រប់ប្រការថា:

**.ការផ្ទំលើផែនដី** ជាបុព្វនិមិត្ត នៃកិរិយាបាននូវអនុត្តរៈសម្មាសម្ពោធិញ្ញាណ ។

**.ភ្នំហោមវន្តជាខ្នើយរងព្រះសិរ** គឺជាបុព្វនិមិត្ត នៃកិរិយាបាននូវខ្នើយគឺ***សព្វញ្ញុតញ្ញាណ*** ។

**.ការសណ្ដូកព្រះហស្ត និង ព្រះបាទចុះក្នុងសមុទ្រនោះ** គឺជាបុព្វនិមិត្ត នៃកិរិយាសំដែងនូវធម្មចក្រ ដល់ទេវតា និង មនុស្សទាំងឡាយ ។

**.ការផ្ទំផ្ងារលើផែនដី** គឺជាបុព្វនិមិត្ត នៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ចុះឲ្យផ្ងារឡើង ។

**.កិរិយាផ្ទំបើកព្រះនេត្រ** គឺជាបុព្វនិមិត្ត នៃកិរិយាបាននូវទិព្វចក្ខុ ។

**.ការឃើញនូវពន្លឺភ្លឺដរាបដល់ភវគ្គព្រហ្ម** គឺជាបុព្វនិមិត្ត នៃ***អនាវរណញ្ញាណ*** ។

**.ការឃើញ*តិណជាតិ* ដុះអំពីនាភី** គឺជាបុព្វនិមិត្តនៃការសំដែងនូវ***អដ្ឋង្គិកមគ្គ*** ។

**.ការឃើញដង្កូវប្រៃកាយ** គឺជាបុព្វនិមិត្ត នៃបរិស័ទទាំង ៤ ដល់នូវត្រៃសរណគមន៍ស្មើដោយជីវិត ។

.***ការឃើញថាសត្វបក្សី ៤ ពួក*** គឺជាបុព្វនិមិត្តនៃត្រកូលទាំង ៤ ចេញសាងបព្វជ្ជាប្រព្រឹត្តតាម***ធម៌វិន័យ*** ។

.***ការឃើញចង្ក្រមលើភ្នំលាមក*** គឺជាបុព្វនិមិត្តនៃបច្ចុប្បច្ច័យ ដែលកើតឡើងដល់ព្រះអង្គ តែព្រះរាជហឫទ័យមិនជាប់ជំពាក់ក្នុងបច្ច័យទាំង ៤ នោះឡើយ ។

(ចប់ទុក្ករកិរិយាបរិច្ឆេទទី៨)

✲✲✲✲✲

## (ពុទ្ធបូជាបរិច្ឆេទទី៩)

ក្នុងសម័យនោះ មានស្រុកមួយឈ្មោះ***សេនានិគម*** ក្នុងឧរុវេលាប្រទេស មានទារិកាម្នាក់ឈ្មោះ**នាងសុជាតា** ជាធីតានៃ***សេនកុដុម្ពី*** នៅក្នុងប្រទេសនោះ ។ នាងមានវ័យចម្រើនឡើង បានធ្វើនូវសេចក្តីប្រាថ្នាទៀប ដើមជ្រៃមួយដើមថា" ***បើខ្ញុំបានប្តីមានជាតិត្រកូលស្មើគ្នា ហើយបានកូនប្រុសច្បង, ខ្ញុំនឹងធ្វើគ្រឿងពលីកម្ម ដោយការបរិច្ចាគទ្រព្យមួយសែនកហាបណៈ ដល់លោករាល់ ៗ ឆ្នាំ*** " ។

លុះកាលខាងក្រោយមក សេចក្តីប្រាថ្នានៃនាងសុជាតាក៏សម្រេចមិនមានឃ្លាត ។ កាលដែលបរមពោធិសត្វធ្វើទុក្ក-

រកិរិយាអស់ ៦ វស្សា,នាងសុជាតាមានប្រាថ្នា ដើម្បីធ្វើពលីកម្មដល់ទេវតា,នាងបង្គាប់ឲ្យមនុស្សនាំមេគោ១.០០០ក្បាលមកលែងក្នុងព្រៃឈើឯម ឲ្យមេគោបរិភោគឈើឯម ។

លុះដល់វេលាល្ងាច នាងឲ្យយកភាជន៍ ៥០០ មកត្រងទឹកដោះមេគោ ៥០០ យកមកឲ្យមេគោ ៥០០ ដែលមិនរីតទឹកដោះនោះផឹក ។ នាងសុជាតាឲ្យបែងពាក់កណ្តាល ៗ ជរាបដល់នៅសល់តែមេគោ ៨ ។ នាងសុជាតាធ្វើយ៉ាងនេះ ដើម្បីទឹកដោះនោះមានរសផ្អែម, នាងសុជាតាគិតថា:



"វេលាព្រឹកស្អែកនេះជាថ្ងៃបុណ្ណមី ខែវិសាខ , អាត្មាអញនឹងធ្វើពលីកម្ម ដល់ទេវតារក្សាដើមជ្រៃ",លុះព្រឹកឡើងនាងឲ្យរីតទឹកដោះមេគោទាំង ៨ , នាកាលភាជន៍ដែលគេបង្អោនចូលទៅជិតដើមដោះមេគោ, ទឹកដោះក៏ហូរចុះមកខ្លួនឯង។ នាងសុជាតា បានឃើញហេតុជាអស្ចារ្យ ដូច្នោះក៏កាន់យកទឹកដោះ ដោយដៃខ្លួនឯង ប្រារព្ធនឹងចម្អិនមធុបាយាស ។ ពពុះសោត ក៏វិលជាទក្ខិណាវដ្ត ប្រព្រឹត្តទៅជុំវិញមិនបានស្រក់ធ្លាក់ចុះ ខាងក្រៅភាជន៍ឡើយ ។

ខណៈនោះ ស្ដេចចតុលោកបាលទាំង ៤ ក៏ចុះមកជួយរក្សាចង្ក្រាន ។ មហាព្រហ្មយកស្វេតច្ឆ័ត្រ មកបើកបាំង សម្ដេចអមរិន្ទ្រាធិរាជមកថែភ្លើង ។ ទេវតាដែលនៅក្នុងចក្រវាឡ ក៏នាំទិព្វឱជារសមកដាក់ ក្នុងមធុបាយាសដោយអានុភាពនៃខ្លួន ។ នាងសុជាតាឃើញហេតុជាអស្ចារ្យដូច្នោះ ក៏ហៅនាង***បុណ្ណាទាសី*** មកប្រាប់ថា:

***"បុណ្ណាអើយ ! ថ្ងៃនេះទេវតាមានចិត្តត្រេកអរ នឹងយើងក្រៃពេក,ហេតុជាអស្ចារ្យដូច្នេះយើងមិនធ្លាប់ឃើញទេ,ចូរឯងទៅបោសក្រោមដើមជ្រៃជាទីលំនៅនៃទេវតាឲ្យស្អាត"***
នាងបុណ្ណាទាសីក៏ទទួលតាមពាក្យនៃនាងសុជាតា។

លុះរាត្រីកន្លងទៅ ព្រះបរមពោធិសត្វ ទ្រង់ធ្វើសរីរកិច្ច

ស្រេច ហើយព្រះអង្គគង់រង់ចាំភិក្ខាចារវេលា ទើបទ្រង់ស្ដេចទៅគង់នៅក្រោមដើមជ្រៃ ។ លំដាប់នោះ នាងបុណ្ណាទាសីដើរទៅបានឃើញព្រះពោធិសត្វ គង់ទតលោកធាតុបែរទៅកើតមានរស្មីផ្សាយចេញ អំពីព្រះកាយមានវណ្ណៈ ដូចជាមាសក៏កំណត់ថាៈ

ថ្ងៃនេះទេវតាយើង ចុះចាកដើមជ្រៃមករង់ចាំទទួលគ្រឿងពលិកម្មដោយដៃខ្លួនឯង នាងក៏មានចិត្តត្រេកអរត្រឡប់ទៅជម្រាបហេតុនោះ ដល់នាងសុជាតា ។

នាងសុជាតាបានស្ដាប់ពាក្យ នាងបុណ្ណាទាសីក៏មានចិត្តត្រេកអរ ស្រដីតបទៅថា "**បើពិតដូច្នោះមែន, តាំងពីថ្ងៃនេះទៅ នាងចូរឋិតនៅក្នុងនាទីជាធីតានៃយើង**" ទើបនាងសុជាតា ឲ្យគ្រឿងប្រដាប់ទាំងពួង ដល់នាងបុណ្ណាទាសីតាមសមគួរ ហើយឲ្យយកភាជន៍មាសមានតម្លៃ ១ សែនកហាបណៈ មកដាក់មធុបាយាស យកភាជន៍ដទៃមកគ្របស្រេចរុំដោយសំពត់ស ។

នាងសុជាតា តែងខ្លួនស្រេចហើយ ឲ្យនាង**បុណ្ណាទាសី**ទូលភាជន៍ ដើរតាមក្រោយទៅដល់ដើមជ្រៃ ក៏បានឃើញព្រះបរមពោធិសត្វ គង់នៅក្រោមដើមជ្រៃនោះ ទើបលើកមធុបាយាសទៅថ្វាយព្រះអង្គ ។

# ព្រះបរមពោធិសត្វគង់ទតលោកធាតុ



ក្នុងកាលនោះ បាត្រដីដែលឃដិកាមហាព្រហ្មថ្វាយក៏បាត់ទៅ ព្រះបរមពោធិសត្វ ផាករកបាត្រមិនឃើញ ។

# នាងសុជាតាថ្វាយមធុបាយាស



នាងសុជាតាកំណត់ដឹងអាការ នៃព្រះបរមពោធិសត្វ ហើយនាងក៏ថ្វាយទាំងភាជន៍ ដោយពាក្យថា "សេចក្ដីប្រាថ្នានៃខ្ញុំសម្រេចហើយ, ខ្ញុំថ្វាយមធុបាយាស ព្រមទាំងភាជន៍" ហើយនាងក៏ចៀសចេញទៅ ។ ចំណែកខាងមហាបុរសក៏ក្រោកចាកអាសនៈ ធ្វើប្រទក្សិណដើមជ្រៃបីជុំហើយព្រះអង្គ

កាន់យកភាជន៍មាសនោះ យាងទៅកាន់**ស្ទឹងនេរញ្ជរា**ដល់ ហើយព្រះអង្គតម្កល់ភាជនៈ ទុកទៀបឆ្នេរស្ទឹងទើបទ្រង់-

# ព្រះអង្គផ្សងតាជន៍



យាងចុះក្នុងស្ទឹងស្រង់ទឹកស្រេច ហើយទ្រង់ក៏ស្លៀកដណ្តប់ត្រៃចីវរ គង់បែរព្រះភក្ត្រទៅកាន់**បុរត្ថិមទិស**(ទិសបូព៌គឺទិស

ខាងកើត) ព្រះអង្គពូតមធុបាយាស ជាពំនូតប៉ុនគ្រាប់ត្នោត បានចំនួន ៤៩ ពំនូត ។ ព្រះបរមពោធិសត្វ ទ្រង់សោយមិនសល់បន្តិសោះឡើយ រួចហើយទើបព្រះអង្គកាន់យកនូវ **សុវណ្ណភាជន៍** ទ្រង់អធិដ្ឋានថា:

*"បើអាត្មាអញបានត្រាស់ជា ព្រះពុទ្ធពិតប្រាកដ ក្នុងថ្ងៃនេះមែន , សូមឲ្យសុវណ្ណភាជន៍ អណ្តែតច្រាសទឹកឡើង "* ទើបព្រះអង្គបណ្តែតទៅក្នុងស្ទឹង ។ ភាជន៍នោះហាក់បីដូចជាមានចេតនា ក៏អណ្តែតច្រាសទឹកឡើងទៅ សំដែងនូវ **សព្វញ្ញុតញ្ញាណនិមិត្ត**, លុះអណ្តែតច្រាសទឹក ទៅបាន ៨០ ហត្ថ ហើយក៏លិចចុះ ក្នុងអន្លង់មួយជាទីជិតពិភព **កាឡនាគ** ទង្គិចនិងភាជន៍ព្រះពុទ្ធ៣ ព្រះអង្គ ពីបុរាណ ឮសូរក្រិក ៗ !! ហើយសៀតស៊កទ្រ ពីខាងក្រោមភាជន៍ទាំង៣ នោះ ។

*ស្តេចកាឡនាគបាន ឮសូរភាជន៍ទង្គិចគ្នា ក៏ភ្ញាក់ឡើងគិតថា " ពីថ្ងៃម្សិលមិញ ព្រះពុទ្ធបានត្រាស់ ១ ព្រះអង្គ ថ្ងៃនេះព្រះពុទ្ធបានត្រាស់ ១ ព្រះអង្គទៀតហើយ"* ទើបទៅជិតភាជន៍មាស ពោលសរសើរ ព្រះពុទ្ធគុណ ។

ចំណែកខាងព្រះបរមពោធិសត្វ ទ្រង់សម្រាកព្រះកាយក្នុង**សាលវ័ន** ទៀបឆ្នេរស្ទឹង ។

# កាឡនាគរាជសរសើរពុទ្ធគុណ



លុះដល់សាយណ្ហសម័យ ព្រះអង្គយាងចាកសាលវ័ន ពពួកទេវតាទាំង ១ ហ្មឺន លោកធាតុ ក៏ថ្វាយស័ព្ទសាធុការបូជា ដោយផ្កាភ្ញីទាំងឡាយដល់ព្រះអង្គ , ព្រះអង្គទ្រង់យាងឆ្ពោះទៅកាន់ពោធិព្រឹក្ស ។

# ពួកទេវតាសាធុការបូជាផ្កា







# សោត្ថិយព្រាហ្មណ៍ថ្វាយស្មៅ



ក្នុងសម័យនោះ សោត្ថិយព្រាហ្មណ៍ អ្នកច្រូតស្មៅ បានឃើញព្រះបរមពោធិសត្វ ហើយក៏ថ្វាយស្មៅ ។ ព្រះបរមពោធិសត្វ ទ្រង់ស្តេចទៅដល់ដើមពោធិព្រឹក្ស ទ្រង់ក៏ប្រទក្សិណ ហើយគង់នៅត្រង់**ទក្ខិណទិស**[១], **បច្ឆិមទិស**[២], **ឧត្តរទិស**[៣], តាមវារៈទ្រង់បែរព្រះភក្ត្រទៅកាន់ពោធិព្រឹក្ស ។ ចក្រវាឡក្នុងទិសនោះៗ ក៏ញាប់ញ័របីដូចជាក្រាបទូលថា "ទីនេះមិនមែនជាទីកើតរតនបល្ល័ង្កទេ" ។ ព្រះអង្គទ្រង់ជ្រាប ហើយទើបយាងទៅគង់ខាង**បុរត្ថិមទិស** បែរព្រះភក្ត្រ-

១.*ទក្ខិណទិស.* ទិសខាងត្បូង. ២.*ឧត្តរទិស.* ទិសខាងជើង , ៣.*បច្ឆិមទិស*. ទិសខាងលិច

ទៅកាន់**ទិសបស្ចិម** ទីនោះមិនបានញាប់ញ័រ ។ ព្រះអង្គក៏សន្និដ្ឋានថា "ទីនេះជាទីកើត**បល្ល័ង្ក**" ទើបទ្រង់ក្រាលនូវស្មៅតាមធម្មតា ។ **តិណជាតិ**(ស្មៅ) នឹងកើតជារតនបល្ល័ង្កក៏ទេ ? ក្នុងគ្រានោះ***រតនបល្ល័ង្កកម្ពស់ ១៤ ហត្ថ*** ក៏ផុសឡើងក្នុងកាលនោះ ។



ព្រះបរមពោធិសត្វ ទ្រង់ទតរតនបល្ល័ង្ក ហើយឡើងគង់អធិដ្ឋាន ព្យាយាមប្រកបដោយអង្គ៤ ថាៈ "***ស្បែកសរសៃឆ្អឹងឈាម នៃយើងចូររីងស្ងួតអស់ទៅចុះ, បើអាត្មាអញមិនបានត្រាស់ទេ នឹងមិនក្រោកចាករតនបល្ល័ង្កនេះឡើយ***" ទ្រង់អធិដ្ឋានស្រេចហើយ ទើបបែរព្រះបិដ្ឋិទៅកាន់ដើមពោធិព្រឹក្ស ដែលមានកម្ពស់៥០ ហត្ថ ។



ក្នុងកាលនោះ សក្កទេវរាជកាន់យកស័ង្ខមកផ្លុំថ្វាយ គន្ធព្វទេវបុត្រ យកពិណមកប្រគំថ្វាយ , សុយាមទេវបុត្រ យក**ចាមរទិព្វ** *(គ្រឿងប្រដាប់មានសណ្ឋានដូចជាផ្លិត)* មកបក់ថ្វាយ ,សហម្បតីព្រហ្មយកស្វេតច្ឆ័ត្រ មកបាំងថ្វាយ, ស្តេចកាឡនាគរាជ នាំយកនាគកញ្ញាមករាំថ្វាយ ទេវតាក្នុងចក្រវាឡទាំង ១ ហ្មឺន នាំយកទិព្វមាលាមកធ្វើសក្ការបូជា ថ្វាយសព្វសាធុការដល់ព្រះបរមពោធិសត្វគ្រប់ ៗ គ្នា ហើយឈរនៅក្នុងទីនោះ ។

( ចប់ពុទ្ធបូជាបរិច្ឆេទទី៩ )

✵✵✵✵✵

# ( មារវិជយបរិច្ឆេទទី១០ )

សម័យនោះ ទេវបុត្រមារមានចិត្តបាបគិត ក្នុងចិត្តថា "ព្រះសិទ្ធត្ថរាជកុមារនេះ ប្រាថ្នាដើម្បីកន្លងនូវវិស័យនៃអញ,ឥឡូវអញមិនឲ្យព្រះសិទ្ធត្ថនេះកន្លងទេ" ទើបមារកែនសេនា នាំពលមារចេញមក ឯសេនានៃមារនោះកម្រាស់ខាងមុខ ១២ យោជន៍ដូចគ្នា ។

## ព្រះអង្គផ្ចាញ់មារ



មារសេនាទាំងអម្បាលនោះ ក៏ស្ថិតនៅដេរដាសពាស ពេញដរាបដល់កណ្តាប់ចក្រវាឡ ។ មារសេនាចំណែក ខាងលើមារប្រមាណ ៩ យោជន៍ សំឡេងដែលមារ ឃោសនានោះ ឮខ្ទរខ្ទាយទៅចម្ងាយ ១ សែនយោជន៍ ដោយជុំវិញ បីដូចជាសន្ធឹកកក្រើកផែនដីទាំងមូល ។ ទេវបុត្រមារ ឡើងជិះលើ**ដំរីគិរីមេខលា** មានកម្ពស់ ១៥០ យោជន៍ និមិត្តដៃមួយពាន់កាន់គ្រឿងអាវុធ មានប្រការ ផ្សេង ៗ ចំណែកសេនាមារសោត ក៏និម្មិតកាយផ្សេង ៗ មានពណ៌ខៀវលឿងជាដើម មានដៃកាន់គ្រឿងអាវុធផ្សេង ៗ គ្នា សេនាមារមានខ្លួនជាសត្វមានក្បាលជាយក្ស ជំពូក ខ្លះមានខ្លួនជាយក្ស មានក្បាលជាសត្វម្រឹគ និងបក្សី ជាដើម កាយខ្ពស់ផ្សេង ៗ គ្នា, ជំពូកខ្លះកម្ពស់ ១ គាវុត, ខ្លះ ២ គាវុត, ខ្លះ ៣ គាវុត , ខ្លះ ១ យោជន៍ ចូលទៅ កាន់ពោធិមណ្ឌលរាល់ ៗ គ្នា ។ នាកាលមារ និងពលនៃ មារមិនទាន់ ដល់ពោធិមណ្ឌលនៅឡើយ, ទេវតាទាំងឡាយ ដែលនៅក្នុងចក្កវាឡទាំង ១ ម៉ឺន ដែលមកចោមរោម ព្រះបរមពោធិសត្វ ។ ពពួកព្រហ្ម ទេវតា នាគ គ្រុឌ គន្ធព្វ គ្រាន់តែ ឮសំឡេងសន្ធឹកគឹកកង នៃសេនាមារលើកមក ក៏រត់ទៅកាន់ទីដទៃផ្សេង ៗ ។ ចំណែកសក្កទេវរាជ ក៏កាន់

ស័ន្ទលាក់ក្រោយខ្នង រត់ទៅឈរនៅលើភ្នំចក្រវាឡ មហាព្រហ្មក៏ចាប់ កំពូលស្វេតច្ឆ័ត្រ ហោះរត់ទៅ,ស្តេចកាឡនាគក៏នាំនាគកញ្ញាទាំងអស់ រត់ជ្រែកដីចុះ ទៅកាន់ពិភពនាគមានប្រមាណ៥០០ យោជន៍ យកដៃខ្ទបមុខដេក ។ កាលបើទេវតារត់ទៅអស់, ព្រះបរមពោធិសត្វ គង់នៅតែមួយអង្គឯង បីដូចជាមហាព្រហ្មស្ថិតនៅ ក្នុងវិមានមិនខ្លាច នូវពលមារនោះឡើយ ។

លំដាប់នោះ មារាធិរាជក៏ស្រែកប្រាប់ សេនាជាបរិស័ទនៃខ្លួនថា "***ម្នាលអ្នករាល់គ្នា បុរសដទៃស្មើ និងព្រះសិទ្ធត្ថនេះមិនមានឡើយ, យើងចូលទៅបានតែខាងឆ្វេងខាងស្តាំ និងខាងក្រោយប៉ុណ្ណោះ***" ព្រះបរមពោធិសត្វទ្រង់ទតទៅឃើញទិសទាំងបីស្ងាត់ ព្រោះទេវតារត់ទៅអស់ ទ្រង់ឃើញពលមារ លើកមកខ្វាន់ខ្វាប់ អំពីទិសឧត្តរ ទើបទ្រង់ព្រះចិន្តាថា "***ជនអម្បាលនេះ លះបង់អាត្មាអញរត់ទៅអស់ ឲ្យតែអាត្មាអញនៅម្នាក់ឯង, មាតាបិតា បងប្អូនញាតិសន្តាននៃអាត្មាអញ ឯណានីមួយក៏មិនមានឡើយ,បារមីនៃអាត្មាអញទាំង ១០ ប្រការ នេះដូចជាជនជាបរិវារនៃអាត្មាអញ អស់កាលជាយូរណាស់មកហើយ***" ព្រះអង្គនឹកដល់បារមីទាំង១០ប្រការ ស្រេចហើយក៏គង់នៅព្រងើយ ។

លំដាប់នោះ ទេវបុត្តមារក៏បណ្ដាល នូវមណ្ឌល ខ្យល់ឲ្យតាំងឡើងដោយគិតថា "***អញនឹងឲ្យព្រះសិទ្ធត្ថនេះរត់ចេញដោយខ្យល់នេះ***" ។ ឯខ្យល់នោះខ្លាំងណាស់ អាច បក់បោកបាក់កំពូលភ្នំបាន, លុះមកដល់ព្រះបរមពោធិសត្វ ក៏មិនអាចនឹងបក់ សូម្បីតែជាយចីវរ ឲ្យកំរើកបាន ។ លំដាប់នោះ ទេវបុត្តមារក៏បណ្ដាល ***ភ្លៀងធំ, ភ្លៀងដុំថ្ម, ភ្លៀងគ្រឿងប្រហារ, ភ្លៀងរងើកភ្លើង, ភ្លៀងផេះក្ដៅ, ភ្លៀងដីខ្សាច់, ភ្លៀងភក់, បណ្ដាលឲ្យងងឹតផ្សេងអ័ព្ទអស់ទិសទាំង៤***, សភាវៈទាំងឡាយមានខ្យល់ជាដើមនោះ មិនអាចបៀតបៀន ព្រះបរមពោធិសត្វបានឡើយ, ត្រឡប់ក្លាយ ទៅជាគ្រឿងបូជាវិញ ។ ឯមារាធិរាជមិនអាច ដើម្បីឲ្យព្រះបរមពោធិសត្វ រត់ទៅដោយហេតុទាំង៩ ប្រការ មានខ្យល់ និងភ្លៀងជាដើមបាន ទើបបង្គាប់ពួកពលសេនា ឲ្យចូលទៅចាប់ ព្រះបរមពោធិសត្វសម្លាប់ ឬបណ្ដេញ ឲ្យរត់ចេញទៅ ។ ចំណែកក្រុងមារក៏ឡើងអង្គុយលើដំរីមាន ដៃកាន់អាវុធ ១ ពាន់ បរដំរីចូលទៅជិតហើយពោលថាៈ

"***នែសិទ្ធត្ថ! ចូរអ្នកក្រោកចេញចាករតនបល្ល័ង្កនេះ ៗ មិនត្រូវបានអ្នកទេ ត្រូវបានយើងទេតើ***" ។



ព្រះបរមពោធិសត្វ ទ្រង់ក៏ពោលតបទៅមារថាៈ **"ម្នាលមារអើយ ! បារមីទាំង ៣០ប្រការ មហាបរិច្ចាគ ៥ ចរិយា ៣ ប្រការ អ្នកឯងមិនបានបំពេញទេ, បល្ល័ង្កនេះមិនមែនកើតឡើងសម្រាប់អ្នកទេ , បល្ល័ង្កនេះកើតឡើងដោយបុណ្យបារមីនៃយើងទេតើ"** ។ មារមានចិត្តបាបបាន ឮហើយ ក៏រឹងរិតតែក្រេវក្រោធ កាន់យក**ចក្រាវុធ**មានមុខដ៏មុតចោលតម្រង់ទៅ ព្រះបរមពោធិសត្វ ឯ**ចក្រាវុធ** ក៏ក្លាយទៅជាពិតាន ស្ថិតនៅលើព្រះបរមពោធិសត្វ ចំណែកបរិស័ទមារ ក៏លើកយកកំពូលភ្នំធំ ៗ ចោលទៅ

សំដៅព្រះពោធិសត្វ ឯកំពូលភ្នំនោះ ក៏ក្លាយទៅជាផ្កាបូជាវិញ ,ចំណែកទេវតា ដែលរត់ចោល ព្រះបរមពោធិសត្វ ទៅឈរលើភ្នំចក្រវាឡ ចាំមើលក៏គិតគ្នាថា "***ប្រហែលជា ព្រះសិទ្ធត្ថនោះ វិនាសទៅដោយដៃមារហើយដឹង***"។ព្រះមហាបុរស ទ្រង់ព្រះចិន្តាថា "រតនបល្ល័ង្កដែលកើតដល់ពោធិសត្វទាំងឡាយ ក្នុងថ្ងៃជាទីត្រាស់ដឹង បានកើតដល់អាត្មាអញ" ទើបទ្រង់សួរទៅមារថា"អ្នកណាជាបន្ទាល់របស់អ្នក ? មារក៏តបទៅថា " ពួកពលសេនាទាំងឡាយនេះ ជាបន្ទាល់របស់យើង " ។

ព្រះបរមពោធិសត្វតបទៅថា " មារអើយ! បន្ទាល់របស់អ្នកសុទ្ធសឹងមានចេតនា, បុគ្គលណាជាបន្ទាល់នៃយើងមិនមាន" ព្រះអង្គនឹកដល់ទាន ដែលព្រះអង្គឲ្យហើយក្នុងកាលកើតជា***ព្រះវេស្សន្តរ*** ទើបព្រះអង្គបញ្ចេញព្រះហស្ថ ពីក្នុងចីវរចង្អុលទៅផែនដី ហើយតបទៅថា "***មារអើយ ! មហាប្រឹថពីនេះ ជាបន្ទាល់របស់យើង*** " ។ ផែនដីក៏លាន់ ឮសំឡេងឡើង ហាក់បីដូចជាក្រាបទូលថា "យើងខ្ញុំជាបន្ទាល់របស់ព្រះអង្គ " ។

លំដាប់នោះ ព្រះមហាបុរសពិចារណា នូវទានបារមីដែលព្រះអង្គឲ្យដំរី ក្នុងកាលដែលទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ ។ ឯដំរីនាឡាគិរីនោះ ក៏ទប់ទល់មិនបាន

ទន់ជង្គង់លុតចុះលើផែនដី ។ មារសោតក៏លើកដៃទាំង ១ ពាន់ ដាក់លើសិរសាពោលដោយគាថាថា:

***បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ, ក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលណាមួយប្រៀបផ្ទឹមស្មើនឹងព្រះអង្គបានឡើយ, ព្រះអង្គជាព្រះពុទ្ធ, ព្រះអង្គជាសាស្តាចារ្យ, ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់គ្របសង្កត់នូវពួកមារ ,ព្រះអង្គជាអ្នកកាត់ផ្តាច់ នូវអនុស័យក្កិលេស ទ្រង់ឆ្លងផុតចាកសង្សារហើយ សូមទ្រង់ចម្លងនូវខ្ញុំព្រះអង្គជាសត្វផង ។***

មារនមស្ការហើយ ហោះរត់ទៅ សេនាមារក៏រត់ទៅកាន់ទីដទៃ ៗ , ចំណែកទេវតាបានឃើញមាររត់ទៅដូច្នោះក៏ប្រឹក្សាគ្នាថា" មារបរាជ័យ ចាញ់ព្រះមហាបុរសរត់ទៅអស់ហើយ, ព្រះសិទ្ធត្ថនៃយើងឈ្នះមារហើយ" គិតហើយក៏កាន់យក នូវគន្ធមាលាហោះចុះ មកកាន់ពោធិមណ្ឌលមានចិត្តត្រេកអរ ក៏ស្រែកជ័យឃោសថ្វាយព្រះពរជ័យគ្រប់ៗ គ្នាក្នុងគ្រានោះ ។

## ( ចប់មារវិជ័យបរិច្ឆេទទី១០ )

✵✵✵✵✵

# ( អភិសម្ពោធិបរិច្ឆេទទី១១ )



នាកាលព្រះអាទិត្យពុំទាន់អស្តង្គតនៅឡើយ ព្រះមហាបុរស កម្ចាត់បង់នូវពលនៃមារ ដោយបារមីស្រេចហើយ ស្លឹកពោធិព្រឹក្សមានវណ្ណៈ ប្រាកដដូចជា**កែវពាឡ កែវទទឹម** ក៏រុះចុះធ្លាក់មកបូជា ។

# ព្រះអង្គទ្រង់ត្រាស់ដឹង



លុះដល់បឋមយាម ព្រះបរមពោធិសត្វ បាននូវ ***បុព្វេនិវាសានុស្សតិញ្ញាណ*** មានប្រការដ៏ច្រើនដោយ អំណាចព្រះអង្គរលឹកនូវខន្ធសន្តាន ដែលធ្លាប់អាស្រ័យ

នៅហើយក្នុងកាលមុនគឺ ទ្រង់រលឹកតាំងអំពីជាតិទី ១ ទី ២ ដរាបដល់សែនជាតិ និង**សំវដ្តកប្ប វិវដ្តកប្ប** ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ព្រមទាំងគោត្រត្រកូល អាហារ ព្រមទាំងការសោយ នូវសេចក្តីសុខទុក្ខ និងកំណត់អាយុ ។

លុះដល់មជ្ឈិមយាម ព្រះអង្គទ្រង់ជម្រះនូវទិព្វចក្ខុ បាននូវ **ចុតូបបាតញ្ញាណ** ឃើញដោយទិព្វចក្ខុនូវសត្វដែលច្យុត និងកើតថោកទាប ឧត្តមមានសម្បុរល្អ មានសម្បុរអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ដែលប្រព្រឹត្តទៅតាមយថាកម្មគឺឃើញថា “ ***ឱហ្ន៎! សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាអ្នកតិះដៀល នូវព្រះអរិយៈ ជាមនុស្សមិច្ឆាទិដ្ឋិ សមាទាននូវមិច្ឆាទិដ្ឋិកម្មនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ បានកើតក្នុងអបាយភូមិ, មួយវិញទៀតសត្វទាំងឡាយ ដែលប្រកបដោយកាយសុចរិត វចីសុចរិត មនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយៈ ជាមនុស្សសម្មាទិដ្ឋិ សមាទាននូវសម្មាទិដ្ឋិកម្មនោះ លុះទំលាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិទេវលោក*** ” ។

លំដាប់អំពីមជ្ឈិមយាមនោះមក ព្រះមហាបុរសទ្រង់ញាណឲ្យចុះកាន់បច្ចយាការគឺ **បដិច្ចសមុប្បាទធម៌** ក្នុងយាមជាទីបំផុត ។ ព្រះមហាបុរស ទ្រង់ពិចារណាថា

"សត្វលោកដែលដល់ នូវសេចក្តីលំបាក ដោយកើត ចាស់ ឈឺ ស្លាប់ ហើយកើតទៀត ព្រោះមិនបានដឹង នូវឧបាយ សម្រាប់រលាស់ខ្លួនចាកទុក្ខនេះ " ទើបព្រះអង្គមានបរិវិតក្ក ថា: "អ្វីហ្ន៎មាន! ទើបជរា និងមរណៈមាន ?ជរា និងមរណៈ តើមានអ្វីជាបច្ច័យ ? យោនិសោមនសិការៈ ក៏កើតមានដល់ ព្រះអង្គថា "កាលបើជាតិមានហើយ, ជរានិង មរណៈ ក៏មាន ជរានិងមរណៈមានជាតិជាបច្ច័យ "។ ទើបព្រះអង្គមានបរិវិតក្ក ទៅទៀតថា "អ្វីមានទើបជាតិមាន ? ជាតិកើតមានអ្វីជាបច្ច័យ ? ព្រះអង្គទ្រង់ជ្រាបថា " កាលបើភពមាន, ទើបជាតិមាន, ជាតិមានភពជាបច្ច័យ ។ ភពមានឧបាទានជាបច្ច័យ,ឧបាទាន មានតណ្ហាជាបច្ច័យ, តណ្ហាមានវេទនាជាបច្ច័យ, វេទនា មានផស្សជាបច្ច័យ, ផស្សៈ មានសឡាយតនៈ ជាបច្ច័យ, សឡាយតនៈ មាន នាមរូបជាបច្ច័យ, នាមរូបមានវិញ្ញាណ ជាបច្ច័យ, សង្ខារមានអវិជ្ជាជាបច្ច័យ ព្រះអង្គពិចារណា រកឬសគល់ នៃ សេចក្តីទុក្ខឃើញ ។

ដូច្នោះហើយ ទើបពិចារណាជា អនុលោមបណ្តោយ ទៅវិញថា " សង្ខារមានអវិជ្ជាជាបច្ច័យ, វិញ្ញាណមានសង្ខារ ជាបច្ច័យ, សឡាយតនៈ មាននាមរូបជាបច្ច័យ, ផស្សៈ មាន សឡាយតនៈ ជាបច្ច័យ វេទនាមានផស្សៈជាបច្ច័យ, តណ្ហា មានវេទនាជាបច្ច័យ, ឧបាទានមានតណ្ហាជាបច្ច័យ , ភពមាន ឧបាទានជាបច្ច័យ, ជាតិមានភពជាបច្ច័យ, ជរានិងមរណៈ មានជាតិជាបច្ច័យ, សេចក្តីសោកខ្សឹកខ្សួល ទុក្ខទោមនស្ស តានតឹង ក្នុងចិត្តក៏កើតឡើងព្រម " ។ ក្នុងធម៌ដែលព្រះអង្គ មិនធ្លាប់ស្តាប់ក្នុងកាលមុន ក៏កើត ឡើងដល់ព្រះអង្គ ។

*លំដាប់នោះ ព្រះបរមពោធិសត្វ ទ្រង់មានបរិវិតក្កថា" កាលបើ អ្វីហ្ន៎មិនមាន, ទើបជរា និងមរណៈមិនមាន ? ការរលត់ជរា និងមរណៈ ព្រោះរលត់នូវអ្វី"?យោនិសោមនសិការៈ កើតឡើងដល់ព្រះអង្គថា " ជរាមរណៈដែល និងរលត់ទៅព្រោះរលត់ជាតិ, ជាតិរលត់ទៅ ព្រោះរលត់ភព, ភពរលត់ទៅ ព្រោះរលត់ឧបាទាន, ឧបាទានរលត់ទៅ ព្រោះរលត់តណ្ហា ។ ល ។ ការរលត់ទៅនៃកងទុក្ខនោះ យ៉ាងនេះឯង ។ កាលដែលព្រះបរមពោធិសត្វ កំពុង ពិចារណា នូវបច្ចយាការ ដ៏ប្រកបដោយអង្គ១២ប្រការ ជាអនុលោមបដិលោម ដោយអំណាច នៃសេចក្តីវិនាស និងសេចក្តីចំរើនឡើងយ៉ាងនេះ, លោកធាតុទាំងមួយម៉ឺន ក៏កម្បនាការ កម្រើកអស់វារៈ ១២ ដងដរាបដល់ ទឹកទ្រដីជាទីបំផុត ។*

ព្រះមហាបុរស ញុំាំងលោកធាតុមួយហ្មឺន ឲ្យកម្បនាការហើយ ព្រះអង្គក៏បានត្រាស់ចំពោះសភាវធម៌ មាន **សង្ខតធម៌**ជាដើម ដោយបញ្ញាដែលកើត អំពីបារមីដ៏វិចិត្រ ដែលព្រះអង្គសន្សំមក, ព្រះអង្គប្រាស់ចាកផង្គុយជាទីប្រជុំនៃវាសនាដល់ នូវកិរិយាវិសេសដោយ**សព្វញ្ញុតញ្ញាណសម្បត្តិ** ប្រកបដោយគុណរាប់មិនបាន ជាទីប្រជុំព្រមនៃមគ្គញ្ញាណដ៏ប្រសើរ ដូចជាផ្កាឈូករីក, ទ្រង់ប្រកបដោយសិរីសោភគ្គសម្បត្តិ ដ៏រុងរឿងក្រៃពេក ។

ព្រះអង្គបាននូវ ***អាសវក្ខយញ្ញាណ*** ក្នុងមជ្ឈិមយាម ព្រះអង្គបានត្រាស់ដឹងនូវ ***អនុត្តរសម្មាសម្ពោធិញ្ញាណ*** គឺ

ជាធម៌ដែលទេវតា មនុស្ស គ្រុឌ នាគ គន្ធព្វ ញ៉ាំញីមិនបាន ក្នុងវេលាអរុណរះ ឡើងនាព្រឹកថ្ងៃ ១រោច ។

នាកាលព្រះបរមពោធិសត្វ ដល់ហើយនូវភាពជាអង្គ **សព្វញ្ញុពុទ្ធ** លោកធាតុទាំងមួយម៉ឺន សឹងប្រដាប់ដោយគ្រឿងប្រដាប់គឺ ទង់ជ័យដែលទេវតាលើកឡើងក្នុងកណ្ដាប់នៃចក្រវាឡខាងកើត ខាងលិច ខាងត្បូង ខាងជើង ។ ទង់ជាយទង់ជ្រុង ដែលទេវតាប្រតិស្ឋាន តាំងពីលើផែនដីជរាបទល់និងព្រហ្មលោក ។ ដើមឈើប្រកបដោយផ្ការីកស្គុសស្គាយ, ផ្កាឈូកក៏រីកជាសពាសពេញ ។ ដើមឈើ មែកឈើ និងវល្លិ៍ក៏មានផ្កាសំយុងចុះ, ផ្កាឈូកដែលសំយុងចុះ ក្នុងអាកាសក៏មាន, ផ្កាឈូកដែលទំលាយផែនដី ផែនថ្មផុសឡើងហើយរីកក៏មាន ។ លោកធាតុទាំងមួយហ្មឺន សឹងដេរដាសពាសពេញដោយផ្កាឈូក ។ ព្រះដ៏មានព្រះភាគ ដែលទេវតាបូជាហើយដោយគ្រឿងសក្ការៈ គណនាត្រារាប់មិនបានយ៉ាងនេះ ព្រះអង្គបានដល់ នូវសព្វញ្ញុតញ្ញាណ ហើយទើបទ្រង់បន្លឺនូវឧទានគាថា ដែលព្រះពុទ្ធទាំងឡាយមិនបានលះបង់ថា:

***អាត្មាអញកាល មិនទាន់បានជួបប្រទះពោធិញ្ញាណនៅឡើយ រវល់តែស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ហើយអន្ទោលទៅកាន់សង្សារ មានជាតិមិន***

តែមួយ, ជាតិគឺការកើតរឿយ ៗ រមែងនាំមកនូវសេចក្តីទុក្ខ, នៃជាងផ្ទះគឺ តណ្ហា (ឥឡូវនេះ) យើងបានឃើញអ្នកច្បាស់ហើយ, អ្នកឯងនឹងធ្វើនូវផ្ទះគឺ អត្តភាពនេះឲ្យយើងទៀតពុំបានឡើយ, ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នកឯង យើងបានបំបាក់ចោលហើយ ទាំងកំពូលនៃផ្ទះគឺអវិជ្ជា របស់អ្នកឯងសោតទៀត យើងក៏បានបំបាក់ចោលហើយដែរ ចិត្តរបស់យើង បានដល់នូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាស់ហើយ, យើងបានដល់នូវព្រះអរហត្តគឺ ការអស់ទៅ នៃតណ្ហាទាំងឡាយហើយ ។

ព្រះអង្គគង់លើរតនបល្ល័ង្ក ដែលទ្រង់បានត្រាស់ដឹងនោះអស់ ៧ ថ្ងៃ ព្រះអង្គបានត្រាស់ ក្នុងថ្ងៃពុធពេញបូណ៌មី ខែវិសាខ ឆ្នាំរកា ។

(ចប់អភិសម្ពោធិបរិច្ឆេទទី១១)

# ( សត្តិកេនិទាន )

# ( ពោធិសព្វញ្ញុតបរិច្ឆេទទី១២ )

ក្នុងសម័យថ្ងៃនោះ ឯងបរិវិតក្កក៏កើតឡើងដល់ទេវតាជំពូកខ្លះថា "កិច្ចព្រះសិទ្ធត្ថ ប្រហែលជាមានតែប៉ុណ្ណោះទេដឹង បានជាព្រះអង្គ មិនលះអាល័យពីរតនបល្ល័ង្ក" ។ ព្រះអង្គទ្រង់ជ្រាប នូវបរិវិតក្កនៃទេវតា ហើយទើបទ្រង់ហោះឡើង ទៅកាន់អាកាស សំដែងនូវ**បាដិហារិយ៍** កាត់បង់ នូវសេចក្តីសង្ស័យនៃទេវតា ។



ឯបាដិហារិយ៍ ដែលព្រះអង្គសំដែងនោះ គឺសំដែងគំនរភ្លើង និងទរនៃទឹកឲ្យប្រព្រឹត្តិទៅជាគូ ៗ គឺគំនរភ្លើងប្រព្រឹត្តិអំពីកាយ ខាងលើទរទឹកប្រព្រឹត្តិ ទៅអំពីកាយខាងក្រោម ជាដើមដរាបដល់គំនរភ្លើង ប្រព្រឹត្តិទៅអំពីម្រាមព្រះហស្ត ទរទឹកប្រព្រឹត្តិទៅអំពីចន្លោះ ម្រាមព្រះហស្តជាបរិយោសាន ។

## ព្រះអង្គទតមើលរតនបល្ល័ង្កអស់៧ថ្ងៃ



ព្រះដ៏មានព្រះភាគ ទ្រង់សំដែង**យមកប្បដិហារិយ៍** មិនបានទូទៅដល់ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវក ដូច្នោះហើយ ទើបទ្រង់យាងចុះចាកអាកាស ទៅគង់នៅក្នុងចំណែកនៃទិសឦសាន ហើយមានព្រះចិន្តាថា "**សព្វញ្ញុតញ្ញាណ តថាគតបានហើយ លើរតនបល្ល័ង្ក** " ទើបព្រះអង្គទ្រង់ទតរតនបល្ល័ង្កនោះ ដោយព្រះនេត្រមិនបានប៉ប្រិចអស់ ៧ថ្ងៃ ទីនោះមាននាមបញ្ញាត្តិថា**អនិមិសចេតិយដ្ឋាន** ។

## ព្រះអង្គនិម្មិតទីចង្រ្កមកែវ



លំដាប់ពីនោះមក ព្រះអង្គនិម្មិតទីចង្រ្កមកែវនោះ ទ្រង់សោយវិមុត្តិសុខអស់ ៧ ថ្ងៃទៀត ។ ទីនោះមាននាមបញ្ញាតិថា ***រតនចេតិយដ្ឋាន*** ។

ទេវតាទាំងឡាយ និម្មិតនូវផ្ទះកែវ ក្នុងចំណែក**ទិសពាយ័ព្យ** នៃពោធិព្រឹក្សថ្វាយចំពោះព្រះអង្គ, ព្រះសាស្តាក៏ទ្រង់យាងទៅគង់ក្នុងផ្ទះកែវនោះ ដោយព្រះភ្នែនទ្រង់ពិចារណា នូវអភិធម្មបិដកជា ***អនន្តន័យ*** គឺ ***សមន្តបដ្ឋាន*** ដ៏វិសេសអស់ ៧ ថ្ងៃ ។



ភិក្ខុទាំងឡាយ ដែលទ្រទ្រង់អភិធម្មនោះ សំដែងថាមិនមាន, ទីដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ពិចារណានូវ**សត្តប្បករណាអភិធម្ម** ទីនោះមាននាមបញ្ញាត្តិថា **រតនឃរដ្ឋាន** ព្រោះហេតុរតនឃរដ្ឋានមានភូមិភាគគឺ:

***សតិបដ្ឋាន ៤ ដាំចុះនូវសសរ គឺ ឥទ្ធិបាទ ៤ , លើកឡើងនូវជញ្ជាំងគឺ វិន័យបិដក , ដាក់លើក្របគឺសម្មប្បធាន ៤ ,តាំងទុកលើរត និងផ្ទៃគឺសមាបត្តិ ៨, រៀបនូវរបៀបខាងលើគឺ សុត្តន្តបិដក ប្រកបចូលដោយគ្រឿងប្រក់គឺអភិធម្មបិដក ផ្ទះកែវរបស់ព្រះអង្គនោះ ជាវិការៈនៃព្រះសទ្ធម្មទាំងអស់ ។*** អ្នកប្រាជ្ញគប្បីដឹងថា **រតនឃរៈ** នោះជាទីដែលព្រះអង្គពិចារណា នូវបិដកទាំង៣ ***ប្រកបដោយនិកាយ ៥ អង្គ ៩ ប្រកបដោយធម្មក្ខន្ធ ៨៤០០០ ។***

ព្រះអង្គទ្រង់ពិចារណានូវ **វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក** ដោយសព្វញ្ញុតញ្ញាណ ទើបព្រះអង្គមានរស្មី ៦ ពណ៌គឺ ***ខៀវ លឿង ក្រហម ស ហង្សបាទ និង ពណ៌ផ្លេក ៗ*** *(ចម្រុះ)* ផ្សាយចេញពី ព្រះកាយទូទៅសព្វទិសានុទិសទាំងពួង ។ ទ្រង់ពិចារណាទំនងនេះអស់ ៧ ថ្ងៃ, ទីនោះមាននាមបញ្ញាត្តិថា**រតនឃរចេតិយដ្ឋាន** ។

លុះថ្ងៃជាគម្រប់ ៥ ព្រះអង្គយាងចាកចេញ ***រតនឃរៈ*** ទៅកាន់***ដើមអជបាលនិគ្រោធ*** [១] ដល់ហើយព្រះអង្គក៏គង់ពិចារណានូវព្រះសទ្ធម្ម ដែលព្រះអង្គបានត្រាស់ដឹង ប្រារព្ធដើម្បីធ្វើឲ្យវិចិត្រដោយបការៈដ៏ច្រើន, ដ្បិតថាបុគ្គលទាំងឡាយក្នុងលោក ដែលព្រះពុទ្ធទាំងឡាយ អាចទូន្មានបានមាន-



៦ ពួក ដែលប្រកបដោយចរិត ៦ ប្រការ មានរាគចរិតជាដើម មានវិត្តកចរិតជាបរិយោសាន សត្វទាំងឡាយដែលផ្សេង ៗ គ្នាមាន៣ប្រការ ដោយអំណាចនៃ***ឧគ្ឃដិតញ្ញូបុគ្គល***[១]

**១.អជបាលនិគ្រោធៈ** *( ដើមជ្រៃ ) ជាទីអាស្រ័យនៃអ្នកក្សេរពពែ*

***វិបច្ចិតញ្ញូបុគ្គល*** (២) និង***នេយ្យបុគ្គល*** (៣ ។ ទូន្មានបានមាន ៦ ពួក ដោយអំណាចនៃចរិត ព្រះអង្គទ្រង់ពិចារណា នូវសត្វ ដែលមាននិស្ស័យដូច្នេះ ទើបទ្រង់ពិចារណានូវធម៌ដ៏វិចិត្រ ដែលព្រះអង្គទ្រង់ត្រាស់ដឹងទ្រង់សោយនូវ ***វិមុត្តិសុខ*** គង់ក្រោមដើមជ្រៃនោះ ។



*១.**ឧគ្ឃដិតញ្ញូបុគ្គលៈ** អ្នកដឹងធម៌ឆាប់រហ័ស ក្នុងកាលលើកឡើងសម្តែង ២.**វិបច្ចិតញ្ញូបុគ្គលៈ** អ្នកដឹងធម៌ក្នុងកាលអធិប្បាយ, ៣.**នេយ្យបុគ្គលៈ** អ្នកដឹងធម៌ដែលអាចពន្យល់*

លំដាប់នោះ ទេវបុត្រមារជាអ្នកស្វែងរកនូវទោសក៏ចូលទៅក្រាបទូលអារាធនា ឲ្យព្រះអង្គបរិនិព្វាន ។ ព្រះអង្គតបថាៈ **មារអើយ! ភិក្ខុជាសាវ័កតថាគត មិនទាន់មាននៅឡើយ, បើសាវ័កតថាគតមាន ព្រមទាំងបានប្រព្រឹត្តិព្រហ្មចរិយធម៌បរិបូរហើយ, តថាគតក៏មិនទាន់បរិនិព្វានដែរ ។**

កាលបើព្រះអង្គមិនព្រម, មារក៏មានចិត្តទោមនស្ស ទៅអង្គុយក្នុងផ្លូវធំគូសគំនូស ១៦ លើផែនដីគិតនូវន័យផ្សេង ៗ មានទានបារមី ដែលខ្លួនមិនបានកសាងជាដើម ។

## មារអារាធនាព្រះអង្គឲ្យបរិនិព្វាន



# ធីតាមារមកលួងលោមព្រះអង្គ



*លំដាប់នោះ ធីតារបស់មារទាំង ៣ គឺ**នាងតណ្ហា ១ រាគា ១ អារតី ១** ចុះមករកបិតាឃើញកំពុងកើតទុក្ខក៏ជានាថា នឹងទៅលួងលោមព្រះអង្គ ឲ្យលង់ក្នុងអំណាចរបស់ខ្លួន, កាលបើបិតាឃាត់ក៏មិនព្រមតាម ចចេសតែទៅ លុះដល់ហើយក៏ក្លែងភេទផ្សេង ៗ ដើម្បីលួងលោមព្រះអង្គ ។*

ប៉ុន្តែមិនអាច ធ្វើអោយព្រះអង្គញាប់ញ័របានទេ ពីតារបស់មារទាំងឡាយ ទាល់ចំណេះ ក៏ត្រឡប់ទៅកាន់ទេវលោកវិញទៅ ។ ព្រះអង្គក៏គង់សោយ វិមុត្តិសុខក្នុងទីនោះអស់ ៧ ថ្ងៃ ។

## ព្រះអង្គគង់សោយវិមុត្តិសុខនាស្រះមុច្ចលិន្ទ



លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ក្រោកចាកគល់ ***អជបាលនិគ្រោធ*** យាងទៅកាន់ ***ស្រះមុច្ចលិន្ទ***, លុះដល់ហើយទ្រង់គង់នៅទៀបស្រះនោះដោយ ***វិមុត្តិសុខ*** ។

មហាមេឃក៏បង្អុលទឹកភ្លៀងឲ្យធ្លាក់ចុះ មកក្នុងវាល ស្តេចនាគឈ្មោះ**មុចលិន្ទ** ចេញចាកស្រះឡើងមកនិម្មិតកាយដ៏ធំពេនព័ទ្ធជុំវិញ ហើយបើកពពារបាំង គ្របខាងលើព្រះសាស្តា ដើម្បីការពារខ្យល់ភ្លៀងកំដៅថ្ងៃ ។ ព្រះដ៏មានព្រះភាគ ទ្រង់សោយវិមុត្តិសុខក្នុងទីនោះអស់ ៧ ថ្ងៃ ។

## ព្រះអង្គគង់ក្រោមដើមកេសសោយវិមុត្តិសុខ



ក្នុងថ្ងៃទី ៧ ជាគម្រប់ ៧ ដង ព្រះដ៏មានបុណ្យយាង ចាកទីនោះ ទៅគង់ក្រោមដើមកែសអស់ ៧ ថ្ងៃទៀត ដើម្បី ***សោយវិមុត្តិសុខ*** ។ រាប់តាំងពីថ្ងៃព្រះអង្គ គង់ក្រោមដើមពោធិព្រឹក្ស ដរាបដល់ថ្ងៃ ដែលព្រះអង្គគង់ក្រោមដើមកែស ទាំងអស់ត្រូវជា៤៩ ថ្ងៃគត់ ។

## សក្កទេវរាជនាំយកផ្លែស្រម៉ទិព្វមកថ្វាយ



លំដាប់មកសក្កទេវរាជ នាំយកផ្លែស្រម៉ទិព្វមកថ្វាយព្រះសាស្តា ទ្រង់ទទួលយកមកសោយ ។ បន្ទាប់មកសក្ក

ទេវរាជបានយកឈើស្ទន់ និងទឹកខ្ពុរព្រះឱស្ឋថ្វាយព្រះអង្គ, ព្រះអង្គទ្រង់ខ្ពុរព្រះឱស្ឋ ជម្រះស្រេចហើយ ទ្រង់គង់ក្រោមដើមកែសនោះ ។

ក្នុងសម័យនោះ មានពាណិជ ២ នាក់បងប្អូននឹងគ្នា បងឈ្មោះ ***តបុស្សៈ*** ប្អូនឈ្មោះ ***ភល្លិកៈ*** បាននាំពួកឈ្មួញរទេះ៥០០ ផ្ទុកដោយទំនិញទៅលក់នៅឯ ***ឧត្តរបថជនបទ*** ក្នុងមជ្ឈិមប្រទេស លុះដល់ដងព្រៃមានទេវតាមួយអង្គជាញាតិសាលោហិត[១] នៃពាណិជទាំងពីរនាក់ អំពីជាតិមុន ដែលអាស្រ័យក្រោមដងព្រៃប្រាប់ពាណិជថា " ***ម្នាលពាណិជឥឡូវនេះ ព្រះពុទ្ធបានត្រាស់ដឹងហើយ, ព្រះអង្គគង់នៅក្រោមដើមកែស, អ្នកចូលទៅកាន់សំណាក់ព្រះអង្គ ធ្វើកិច្ចនមស្ការហើយ ថ្វាយនូវសដូវដុំ សដូវផង់ដល់ព្រះអង្គ នឹងបានផលប្រយោជន៍ នាំមកនូវសេចក្តីសុខ អស់កាលជាអង្វែង*** " ។

លំដាប់នោះ ពាណិជទាំងពីរនាក់ បានស្តាប់ពាក្យទេវតា ក៏កើតសេចក្តីជ្រះថ្លា ក៏កាន់យកសដូវនាំទៅថ្វាយព្រះអង្គ, ដល់ហើយថ្វាយបង្គំថា " ***បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ទទួលនូវសដូវរបស់យើងខ្ញុំ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខអស់កាលជាអង្វែង*** " ។

១.(ធ្លាប់ជាមាតាពីអតីត)

ព្រះអង្គទ្រង់ព្រះចិន្តាថា បាត្ររបស់តថាគតបាត់ទៅហើយ ក្នុងថ្ងៃដែលទទួលមធុបាយស, តថាគតមិនគួរទទួលអាមិសដោយដៃទេ តថាគតនឹងបាននូវភាជន៍ឯណាទទួល ។

លំដាប់នោះ ស្តេចចតុលោកបាលទាំង ៤ អង្គ បានដឹងបរិវិតក្កក៏នាំយក**បាត្រថ្មកែវឥន្ទនិល** ៤ មកថ្វាយព្រះអង្គ ប៉ុន្តែខណៈនោះ ព្រះអង្គមិនព្រមទទួលទេ ។ ស្តេចចតុលោកបាលទាំងឡាយ ក៏បង្អោន**បាត្រថ្មមានវណ្ណៈ ដូចសណ្តែកបាយ** ទៅថ្វាយព្រះអង្គម្តងទៀត ។



# តបុស្សៈ និង ភល្លិកៈថ្វាយសដូវ



ទើបទ្រង់ទទួលយក ដោយសេចក្តីអនុគ្រោះ ដល់ស្តេចចតុលោកបាលទាំង ៤ អង្គនោះ ។ ហើយទ្រង់តម្រួតលើគ្នាអធិដ្ឋានឲ្យទៅជាបាត្រ ១ ទើបទ្រង់ទទួលនូវសដូវហើយសោយ ។

លំដាប់នោះ ពាណិជទាំងពីរនាក់នោះ ក៏សម្តែងខ្លួនជាឧបាសកដល់នូវ**ទ្វេវាចិកសរណគមន៍** ពាណិជទាំងពីរនាក់នោះ **ជាបឋមឧបាសក** ក្នុងព្រះពុទ្ធសាសនា ។



លំដាប់នោះ ពាណិជទាំងពីរនោះ ទូលសូមនូវវត្ថុសម្រាប់ធ្វើសក្ការបូជា ។ ព្រះសម្មាសម្ពុទ្ធទ្រង់ស្ទាបព្រះសិរសាក៏យកព្រះកេស ៨ សរសៃ ដែលជាប់នឹងព្រះហស្តមក, ព្រះអង្គទ្រង់ព្រះរាជទាន ដល់ពាណិជទាំងពីរនាក់នោះ ។

រីឯពាណិជពីរនោះ ក៏ទទួលយកព្រះកេសធាតុទាំង ៨ សរសៃ អំពីព្រះដ៏មានព្រះភាគ ហើយក៏នាំយកទៅកាន់

នគរនៃខ្លួន, ដល់ហើយក៏រៀបចំ តាក់តែងទីទួលមួយឈ្មោះ **សិទ្ធិត្ថរ** ធ្វើចេតិយបញ្ចុះទុក ធ្វើជាសក្ការបូជា តាមបណ្ដាំព្រះអង្គ ។

កាលពាណិជទាំងឡាយ ប្រារព្ធពិធីបញ្ចុះព្រះកេសធាតុនោះ ព្រះបាទ**ឧបលាបរាជ** បានឧបត្ថម្ភប្រកបដោយសេចក្ដីជ្រះថ្លាដ៏អស្ចារ្យ, ពួកទេវតាមានសក្កទេវរាជជាដើមក៏មកជួយរៀបចំ, ពួកមនុស្សមាន ព្រះបាទឧបលាបរាជជាដើម មកជួយខ្វល់ខ្វាយ ។

ចំណែកឯ ព្រះកេសធាតុសោត ក៏សម្ដែងនូវបាដិហារិយ៍ផ្សេង ៗ ទេវតា និងមនុស្សទាំងឡាយ ក៏ធ្វើសក្ការបូជា ដោយវត្ថុផ្សេង ៗ មានមាសប្រាក់ជាដើម ដោយចិត្តជ្រះថ្លា ចេតិយនោះ មាននាមបញ្ញត្តិថា **សិទ្ធត្ថរចេតិយ** ។ **ទីទួលនោះ ជាទីបញ្ចុះនូវគ្រឿងបរិក្ខារព្រះពុទ្ធទាំង ៤ ព្រះអង្គ ក្នុងភទ្ទកប្បនេះគឺ បញ្ចុះធម្មក្រករបស់ព្រះពុទ្ធកក្កុសន្ធៈ**, វត្ថពន្ធរបស់ **ព្រះកោនាគមនៈ** សាដករបស់ **ព្រះកស្សបៈ** និងកេសធាតុ ៨ សរសៃ របស់**ព្រះគោតម** ។

(ចប់ពោធិសព្វញ្ញុបរិច្ឆេទទី១២)

# ( ព្រហ្មជ្ឈេសនបរិច្ឆេទទី១៣ )

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ក្រោកចាកគល់ ***រាជាយតនៈ*** នោះ ទៅគង់ក្រោមដើម***អជបាលនិគ្រោធ*** ហើយ ព្រះអង្គទ្រង់វិត្តកថា "ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះ ជាគម្ពីរភាពឆ្ងាយទូលាយណាស់ ដែលព្រះពុទ្ធទាំងឡាយ ទ្រង់សំដែងហើយ ដែលជាធម៌គឺសត្វទាំងឡាយ បានឃើញដោយកម្រ ត្រាស់ដឹងដោយកម្រ ធម៌នេះល្អិតសុខុមណាស់ ឧត្តមប្រសើរណាស់ ដល់ពេញដោយមិនសល់គឺបណ្ឌិតជាតិគប្បីសំដែង " ព្រះអង្គបរិវិតក្ក ហើយទ្រង់ក៏ដល់នូវសេចក្តីខ្វល់ខ្វាយតិច មិនមានព្រះទ័យប្រាថ្នាដើម្បីនឹងសំដែងនូវធម៌ ដល់សត្វទាំងឡាយ ទ្រង់ក៏គង់ស្ងៀមព្រងើយ ។

លំដាប់នោះ ***សហម្បតីព្រហ្ម*** ដឹងនូវបរិវិតក្កនៃព្រះអង្គ ក៏បញ្ចេញនូវវាចាអស់វារៈ៣ ដង៏ថា " **បពិត្រព្រះអង្គដ៏ចម្រើន សត្វលោកនឹងវិនាសសាបសូន្យមិនខានឡើយ** " ។ មហាព្រហ្មទាំងឡាយ ដែលនៅក្នុងចក្កវាឡមួយហ្មឺន បានឮហើយក៏មកសួរគ្រប់ប្រការ ។ សហម្បតិព្រហ្មដឹងហេតុហើយទើបនាំគ្នាហោះចុះមក ចូលទៅកាន់សំណាក់-ព្រះសាស្តាដល់ហើយក៏លុតនូវ***ជានុមណ្ឌល*** (ជង្គង់ទាំងមូល)

តម្កល់លើផ្ទៃប្រឹថពី ផ្គងនូវអញ្ជលី ជាទីសមោធាននៃ ***ទសនខា*** (ម្រាមដៃ១០) ដ៏រុងរឿងបីដូចជាផ្កាឈូកក្រពុំនៅលើសិរសា ហើយងើបមុខមើលកន្ត្រា នៃព្រះអង្គដ៏រុងរឿងដោយឆព្វណ្ណរង្សី ក្រាបអារាធនាដោយគាថា **សន្ទីធ-សត្តប្បរជក្ខជាតិក**ដូច្នេះជាដើម..... ។

## សហម្បតិព្រហ្មអារាធនាព្រះអង្គ



សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់មានព្រះទ័យប្រកបដោយ សេចក្តីករុណាបាន**សវនាការ**( ស្តាប់ ) នូវពាក្យនៃព្រហ្មហើយ ទើបព្រះអង្គមានព្រះពុទ្ធដីកាថាៈ

***ម្នាលសហម្បតិព្រហ្ម តថាគតបរិវិតក្កថា ធម៌ជាគម្ភីរភាព តថាគតត្រាស់ដឹងហើយ ពពួកសត្វទាំងឡាយត្រេកអរដោយតណ្ហា មិនអាចធ្វើឲ្យជាក់ច្បាស់នូវទីបំផុតនៃទុក្ខគឺ ព្រះនិព្វានបានឡើយ, បដិច្ចសមុប្បាទធម៌ប្រកបដោយអង្គ ១២ ក៏សត្វឃើញដោយកម្រ កិរិយា រម្ងាប់បង់នូវសង្ខារទាំងពួង និងកាលលះបង់កិលេស និងការផ្តាច់បង់នូវតណ្ហា ហើយដល់នូវព្រះនិព្វាន ក៏សត្វដឹងដោយកម្រ,បើតថាគតសម្តែងនូវធម៌ សត្វទាំងឡាយក៏មិនជឿនូវពាក្យតថាគត, សេចក្តីនឿយណាយ ព្រួយលំបាកទទេ គង់មានដល់តថាគត, ហេតុដូច្នេះ បានជាតថាគត មានសេចក្តីខ្វល់ខ្វាយតិច ក្នុងការសំដែងធម៌ដល់សត្វ ។***

ព្រះដ៏មានព្រះភាគ កាលដែលសហម្បតិព្រហ្ម អារាធនាអស់វារៈ៣ ដង ដូច្នោះហើយ ព្រះអង្គក៏រមិលមើលសត្វដោយទិព្វចក្ខុទ្រង់ឃើញនូវសត្វខ្លះ មានធូលីគឺ ***រាគៈ ទោសៈ មោហៈ*** ក្នុងភ្នែកតិច, សត្វពួកខ្លះ មានធូលីក្នុងភ្នែកច្រើន, ព្រះអង្គទ្រង់ជ្រាបច្បាស់ ហើយទើបមានព្រះពុទ្ធដីការថាៈ

***អបារុតា តេ អមតស្ស ទ្វារា យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ វិហឹសសញ្ញី បគុណំ នភាសឹធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។***

*ម្នាលព្រហ្ម តថាគតមានការសម្គាល់ នូវសេចក្តីនឿយ (កាយ និងវាចា) បានជាមិនទាន់សម្តែង នូវធម៌ដ៏ឧត្តម ដែលតថាគតចេះស្ទាត់ហើយ ដល់ពួកមនុស្ស និងទេវតាទាំងឡាយ ( ប៉ុន្តែឥឡូវនេះ ) ទ្វារនិព្វានបើកហើយ ពួកសត្វណា ដែលមានសោតាបសាទ ពួកសត្វនោះ ចូរបញ្ចេញនូវដៃ គឺសទ្ធាស្តាប់ធម៌ចុះ ។*

សហម្បតីព្រហ្ម បានស្តាប់នូវព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ធ្វើនូវឱកាស ទទួលនឹងសំដែងធម៌ដល់សត្វដូច្នោះហើយ ក៏ធ្វើនូវអញ្ជលីថ្វាយបង្គំលា នាំព្រហ្មបរិវារ ហោះទៅស្ថានព្រហ្មវិញ ។

(ចប់ព្រហ្មជ្ជេបរិច្ឆេទទី១៣)

* * * * *

# ( ធម្មចក្កបរិច្ឆេទទី១៤ )

ព្រះដ៏មានព្រះភាគ ទ្រង់ប្រទាននូវបដិញ្ញា ដល់មហាព្រហ្មយ៉ាងនេះហើយ ក៏ទ្រង់ព្រះចិន្តាថា ***តថាគតគប្បីសម្តែងធម៌ដល់អ្នកណាមុន ?*** បុគ្គលណានឹងបានត្រាស់ដឹងនូវធម៌ជាមុន ? ព្រះអង្គបរិវិតក្កថា ***អាឡារតាបសកាលាមគោត្រ*** នេះជាបណ្ឌិតមានធូលីគឺ កិលេសក្នុងភ្នែកតិច , គួរតថាគតសំដែងធម៌ ឲ្យជាមុនតាបសនេះសោតនឹងត្រាស់ដឹងនូវធម៌ពុំខាន ។

លំដាប់នោះឯង ទេវតាចូលទៅក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ***អាឡារតាបសកាលាមគោត្ត*** ធ្វើមរណកាលទៅចំនួន ៧ ថ្ងៃហើយ " ។ ព្រះបញ្ញាញាណក៏កើតឡើងដល់ព្រះអង្គទ្រង់ជ្រាបថា "***អាឡារតាបសកាលាមគោត្ត*** ធ្វើមរណកាលក្ស័យជីវិតកន្លងទៅ ៧ ថ្ងៃពិតមែន " ។

ក្នុងខណៈនោះ ព្រះដ៏មានព្រះភាគ ទ្រង់បរិវិតក្កថា តថាគតគប្បីសម្តែងធម៌ ដល់អ្នកណា ? ទើបទ្រង់ជ្រាបថា ***ឧទ្ទកតាបសរាមបុត្រ*** ៗ នេះជាបណ្ឌិតមានធូលី ក្នុងភ្នែកតិច គួរនឹងត្រាស់ដឹងនូវធម៌ដោយឆាប់ ។ ក្នុងគ្រានោះទេវតា បានចូលទៅក្រាបទូលដល់ព្រះអង្គថា "***ឧទ្ទកតាបសរាមបុត្រ*** នោះធ្វើមរណកាល ក្នុងវេលាព្រលប់ទៅហើយ " ។

ព្រះអង្គក៏ទ្រង់ជ្រាប ដោយបញ្ញាទៀតថា មែនដូចពាក្យទេវតាទូល ទើបព្រះអង្គទ្រង់បរិវិតក្កថា តាបសទាំងពីរនោះវិនាសធំហើយ, បើតាបសនៅបានស្តាប់ធម៌ ដែលតថាគតសម្តែង ក៏គង់នឹងបានត្រាស់ដឹង នូវធម៌ដោយពិតមិនខាន ។

សម័យនោះ ព្រះអង្គទ្រង់មានបរិវិតក្ក ទៅទៀតថា "***តថាគតគប្បីសម្តែងធម៌ ដល់អ្នកណាជាមុន ?*** អ្នក***ណានឹងបានត្រាស់ដឹងនូវធម៌មុន ?*** ទើបព្រះអង្គទ្រង់បរិវិតក្កនឹកដល់***បញ្ចវគ្គិយ៍*** ថាបញ្ចវគ្គិយ៍***នេះ មានឧបការៈដល់តថាគតច្រើនណាស់ បានធ្វើការបម្រើ តថាគតអស់កាលដ៏យូរ, បើដូច្នោះ គួរតែតថាគតសម្តែងធម៌ ដល់បញ្ចវគ្គិយភិក្ខុជាមុនចុះ*** ។ ហើយព្រះអង្គទ្រង់បរិវិតក្កទៀតថា បញ្ចវគ្គិយភិក្ខុទៅនៅក្នុងទីឯណា ? ទើបទ្រង់ជ្រាបថា "បញ្ចវគ្គិយ៍នៅនា***ព្រៃឥសិបតនមិគទាយវ័ន*** ជិតនគរពារាណសី, គ្រានោះព្រះអង្គគង់ក្នុងឧរុវេលាប្រទេសតាមសប្បាយ ។

លុះដល់គ្រាក្រោយ ទ្រង់យាងទៅជាលំដាប់ ទ្រង់ក៏បានជួប និង***ឧបកាជីវក***, ខណៈនោះ ដៃរឧបការជីវកក៏បានឃើញព្រះសម្មាសម្ពុទ្ធ ក៏ពោលពាក្យសរសើរផ្សេង ៗ ។

សម័យកាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងនូវគាថា ***សព្វាភិភូសព្វវិទូ***......ដូច្នេះជាដើម ។ លុះចប់

# ព្រះអង្គជួបឧបកាជីវក



ហើយឧបកាជីវកសួរថា **សមណទៅកាន់ទីឯណា ?** ព្រះអង្គត្រាស់តបថា **តថាគតទៅដែនកាសី ដើម្បីសម្ដែងនូវធម្មចក្ក ។** ឧបកាជីវកបានស្ដាប់ហើយ ក៏តបទៅថា **"ម្នាលអាវុសោសមណៈ អ្នកពោលប្រពៃហើយ"** ឧបកាជីវកក៏ង៉ក់ក្បាល ហើយដើរចៀសទៅតាមប្រាថ្នារបស់ខ្លួន ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ទៅតាមចារិកតាមលំដាប់ដល់ព្រៃ **ឥសិបតនមិគទាយវ័ន** ជាទីនៅនៃបញ្ចវគ្គីយ៍ ។ រីឯបញ្ចវគ្គីយ៍ បានឃើញព្រះអង្គ អំពីចម្ងាយ ក៏ធ្វើនូវបដិញ្ញានឹងគ្នាថា "ម្នាលគ្នាយើង ព្រះសមណគោតម មកដល់ហើយ, យើងទាំងឡាយកុំថ្វាយបង្គំ កុំក្រោកទទួល កុំទទួលបាត្រ និង ចីវរ , តែជាពួកយើងត្រូវក្រាលអាសនៈ ទុកបើសមណគោតមអង្គុយ ក៏អង្គុយចុះ" ស្រាប់តែពេលនោះ ព្រះអង្គយាងទៅដល់ បញ្ចវគ្គីយ៍អត់មិនបាន ភ្លេចពាក្យបដិញ្ញារបស់ខ្លួនអស់ ក៏ត្រឡប់ជាក្រោកអរ ទៅទទួលបាត្រ និង ចីវរ ហើយធ្វើនូវកិច្ចទាំងពួងរាល់ ៗ គ្នា ហើយហៅព្រះអង្គ ដោយពាក្យដើមខ្លះ ដោយពាក្យថាអាវុសោខ្លះ ។ ព្រះសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីការថា:

*ម្នាលភិក្ខុទាំងឡាយ តថាគតឆ្ងាយចាកកិលេសហើយ ត្រាស់ដឹងនូវធម៌ ដោយប្រពៃហើយ, អ្នកទាំងឡាយចូលតម្កល់ នូវសោតបសាទចាំស្តាប់នូវធម៌ឈ្មោះ**អមតៈ** តថាគតនឹងសម្តែងនូវធម៌ ដែលតថាគតត្រាស់ដឹងហើយ* ។ បន្ទាប់ពីព្រះអង្គពោលដូច្នោះ បញ្ចវគ្គីយ៍ក៏ក្រាបទូលថា *ម្នាលអាវុសោគោតម ខ្លួនអ្នកត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ហើយឬ ?* ព្រះអង្គតបទៅថា *ធម៌ដែលមានឈ្មោះថា* ***អមតៈ*** តថាគត

ត្រាស់ដឹងហើយ តថាគតនឹងសម្តែងធម៌នោះ ដល់អ្នកទាំងឡាយ ។

គ្រានោះព្រះអង្គ ក៏មិនអាចញ៉ាំងបញ្ចវគ្គីយ៍ ឲ្យដឹងច្បាស់អស់វារៈ ជាគម្រប់ ២ ដង ។ តមកទៀតទើបបញ្ចវគ្គីយ៍ទាំងឡាយ ទទួលស្តាប់ព្រះពុទ្ធដីកាជាគម្រប់៣ ដង ។

## ព្រះអង្គទ្រង់ប្រោសបញ្ចវគ្គីយ៍



គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ហៅពួកបញ្ចវគ្គីយ៍ដោយព្រះពុទ្ធដីកាថា **ទ្វេមេ ភិក្ខវេ អាមន្តាបព្វ-**

***ឋិតេន ន សេវិតព្វា*** ម្នាលភិក្ខុទាំងឡាយ ផ្លូវដ៏លាមក ទាំងឡាយពីរនេះគឺ បព្វជិតមិនគប្បីសេព , មគ្គប្រកប ដោយអង្គ ៨ ប្រការ បព្វជិតគប្បីសេព, ព្រះអង្គក៏ទ្រង់ ត្រាស់សម្តែង ***ធម្មចក្កប្បវត្តនសូត្រ ប្រកបដោយអង្គ ៣ ប្រការគឺ:***

- **កាមសុខល្លិកានុយោគ ១**
- **អត្តកិលមថានុយោគ ១**
- **មជ្ឈិមបដិបទា ១**

✵ ***ប្រកបដោយសច្ចៈ ៤ គឺ:***

- **ទុក្ខសច្ចៈ ១**
- **សមុទ្ទយៈ ១**
- **និរោធសច្ចៈ ១**
- **មគ្គសច្ចៈ ១**

✵ ***ប្រកបដោយបរិវត្ត ៣ គឺ***

- **សច្ចញ្ញាណ ១**
- **កិច្ចញ្ញាណ ១**
- **កតញ្ញាណ ១**

ដោយអាការ ១២ គឺសច្ចៈនីមួយ ៗ មានអាការ បី ៗ គ្រប់ ទាំង ៤ ។ ទេវតាទាំងឡាយ បន្លឺនូវសំឡេងត ៗ គ្នា ទៅ លោកធាតុទាំង ១ ហ្មឺន ក៏កម្រើកញាប់ញ័រ ។

លំដាប់នោះ ***កោណ្ឌញ្ញភិក្ខុ*** ក៏បានត្រាស់ដឹងនូវ ***លោកុត្តរធម៌*** គឺ ***សោតាបត្តិផល*** ។ ទេវតាទាំង ១៨ កោដិ ក៏បាន ***ធម្មចក្ខុ*** គឺ ***សោតាបត្តិផល*** ហើយត្រឡប់ទៅកាន់ស្ថានទេវលោកវិញអស់ទៅ ។

***ព្រះអង្គសម្ដែងធម្មចក្ក ក្នុងថ្ងៃបុណ្ណមី ខែអាសាឍ ឆ្នាំរកា***



( ចប់ធម្មចក្កបរិច្ឆេទទី១៩ )

✵✵✵✵✵

# ( យសបព្វជ្ជាបរិច្ឆេទទី១៥ )

សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់ចាំវស្សាក្នុង ***ព្រៃឥសិបតនមិគទាយវ័ន*** ទ្រង់សំដែងធម្មិកថាដល់ភិក្ខុដ៏សេស ទ្រង់ប្រទានធម្មចក្ខុដល់ ***ព្រះវប្បៈ*** ក្នុងថ្ងៃ ១ រោច ,ប្រទានដល់ ***ព្រះភទ្ទិយ*** ក្នុងថ្ងៃ ២ រោច , ដល់ ***ព្រះមហានាម*** ក្នុងថ្ងៃ ៣ រោច, ដល់ ***ព្រះអស្សជិ*** ក្នុងថ្ងៃ ៤ រោច ។

លំដាប់នោះ បញ្ចវគ្គីយ៍ទាំងឡាយ ក៏សូមឧបសម្បទាព្រះដ៏មានព្រះភាគ ទ្រង់ក៏ប្រទាន នូវឧបសម្បទាជា **ឯហិភិក្ខុ** ដល់បញ្ចវគ្គីយ៍ ដោយព្រះពុទ្ធដីកាថា " **ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូលមក អ្នកទាំងឡាយចូលប្រព្រឹត្តិ នូវព្រហ្មចរិយ ដើម្បីធ្វើនូវទីបំផុត នៃសេចក្តីទុក្ខ ។** ឧបសម្បទាក៏សម្រេច ដល់ពួកបញ្ចវគ្គីយភិក្ខុទាំងឡាយ, ព្រះអង្គទ្រង់គង់នៅ ក្នុងសមាបត្តិរងចាំ ដើម្បីជម្រះមន្ទិលនៃបញ្ចវគ្គីយភិក្ខុទាំងឡាយ ។

លុះដល់ថ្ងៃ ៥ រោច ព្រះអង្គឃើញឧបនិស្ស័យព្រះអរហន្ត នៃភិក្ខុទាំង ៥ រូប ដ៏វិសេស ព្រះអង្គក៏ប្រជុំភិក្ខុទាំង ៥ រូប ហើយសំដែងនូវ ***អនត្តលក្ខណសូត្រ*** ដោយព្រះពុទ្ធដីការថា " ***រូបំ ភិក្ខវេ អនត្តា*** " ដូច្នេះជាដើម

ព្រះសាស្តា ទ្រង់ចង្អុលនូវបញ្ហាក្ខន្ធថា ជាសភាវៈ មិនបាន ប្រព្រឹត្តិទៅក្នុង នៃបុគ្គលណា ។ បញ្ចវគ្គីយភិក្ខុ ក៏មានចិត្ត ត្រេកអរ និងភាសិតនៃព្រះអង្គ ចិត្តបញ្ចវគ្គីយ៍សោត ក៏ រួចចាកអាសវៈ បានដល់នូវភាពជាព្រះអរហន្ត ។

ក្នុងគ្រានោះឯង ព្រះអរហន្តកើតឡើង ក្នុងលោក ៦ អង្គ គឺបញ្ចវគ្គីយភិក្ខុ ៥ អង្គ និង ព្រះពុទ្ធជាអង្គម្ចាស់ នៃ យើង ១ ព្រះអង្គទៀត ជាគម្រប់ ៦ អង្គ បានកើតឡើង ក្នុងលោក ។

## ព្រះអង្គទ្រង់ប្រោសយសកុលបុត្ត



ក្នុងសម័យនោះ មានបុត្រ នៃសេដ្ឋីម្នាក់ឈ្មោះ **យស កុលបុត្ត** នៅក្នុងប្រាសាទទាំង ៣ ជាទីសប្បាយតាម

ឧតុកាល មានស្រីស្នំបម្រើជាច្រើន, ក្នុងកាលនោះ យសកុលបុត្តភ្ញាក់ក្រោកឡើងមុនគេ បានឃើញជនទាំងឡាយដេកលក់សំដែងវិការផ្សេង ៗ ក៏មានចិត្តនឿយណាយ ក្នុងឃរាវាស ទើបពាក់ស្បែកជើងមាស ដើរចុះចាកប្រាសាទចូលទៅក្នុង **ព្រៃឥសិបតនមិគទាយវ័ន** ក្នុងរាត្រី ។

គ្រានោះ ព្រះដ៏មានបុណ្យ ទ្រង់យាងចង្រ្កមវេលា **បច្ចូសសម័យ** ទ្រង់ទតឃើញយសកុលបុត្ត ហើយត្រាស់ហៅថា " នែអ្នកដ៏ចម្រើន ទីនេះឥតមានទោស បៀតបៀនទេ " ។ យសកុលបុត្តស្តាប់ហើយ ក៏ដោះទ្រនាប់ជើងមាស ដើរចូលទៅកាន់សំណាក់ ព្រះសាស្តា ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែង**អនុបុព្វីកថា**ចប់ហើយ យសកុលបុត្ត បានសម្រេចសោតាបត្តិផល។ លំដាប់នោះ មាតាយសកុលបុត្ត ឡើងទៅលើប្រាសាទមិនឃើញកូន ក៏ទៅជម្រាបស្វាមី ។ សេដ្ឋីបានស្តាប់ភរិយាហើយ ក៏ប្រើមនុស្សឲ្យទៅរកក្នុងទិសទាំង ៤ ។ គហបតីក៏ដើរទៅរក ក្នុងព្រៃឥសិបតនមិគទាយវ័ន ដោយខ្លួនឯងបានឃើញស្បែកជើងមាស ដែលកូនដោះចោល ក៏ដើរតាមដានទៅ ។ ព្រះពុទ្ធជាអង្គម្ចាស់ ឃើញសេដ្ឋីដើរចូលមក ទ្រង់សម្តែងឫទ្ធិ មិនឲ្យឃើញយសកុលបុត្ត ។

សេដ្ឋីដើរចូលទៅសួរ, ព្រះអង្គមានព្រះពុទ្ធដីកាថា " អ្នកចូលអង្គុយ ក្នុងទីនេះចុះ គង់តែនឹងបានឃើញកូនអ្នកទេ " សេដ្ឋីបានស្តាប់ ហើយក៏ធ្វើតាម ។ ទើបទ្រង់សម្តែងអនុបុព្វីកថាចប់ ហើយសេដ្ឋីបានសម្រេច សោតាបត្តិផល សម្តែងខ្លួនថា ជាឧបាសកដល់នូវ ***តេវាចកសរណាគមន៍*** ។



សេដ្ឋីនោះ ជាឧបាសកដំបូង ក្នុងព្រះពុទ្ធសាសនា ។ ព្រះពុទ្ធជាម្ចាស់ ក៏រំសាយឫទ្ធិឃើញយសកុលបុត្ត ដែលអង្គុយនូវជិតព្រះអង្គ សេដ្ឋីឃើញហើយ ក៏និយាយនឹង

កូនថា " កូនអើយ! មាតាអ្នក មានសេចក្តីសោកខ្លាំងណាស់ , ចូរអ្នកឲ្យនូវជីវិត ដល់មាតាអ្នកផង " ។

លំដាប់នោះ យសកុលបុត្ត ក៏រមិលមើលនូវព្រះពុទ្ធព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកា និងគហបតីថា "ម្នាលគហបតីយសកុលបុត្តក្តី អ្នកក្តី បានដឹងច្បាស់នូវធម៌ហើយ យសកុលបុត្ត មិនគួរត្រឡប់ទៅកាន់ភេទហោកទាបវិញឡើយ " ។ គហបតីក៏ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន យសកុលបុត្ត មិនគួរត្រឡប់ភេទហោកទាបទេ, ម្យ៉ាងទៀតសោត លាភក៏បានដោយងាយ, ប៉ុន្តែថ្ងៃស្អែកនេះ សូមព្រះអង្គ ទ្រង់យាងទៅទទួលភត្ត នៃខ្ញុំព្រះអង្គមួយអន្លើដោយ យសកុលបុត្តនេះផងចុះ " ។

ព្រះដ៏មានបុណ្យ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព គហបតីដឹងនូវហេតុនោះ ក៏ថ្វាយបង្គំលាធ្វើប្រទក្សិណហើយចៀសចេញទៅ ។ យសកុលបុត្ត ក៏សូមបព្វជ្ជាឧបសម្បទា , ព្រះសព្វញ្ញូទ្រង់ប្រទាន បព្វជ្ជាឧបសម្បទាជាឯហិភិក្ខុ ។

***ក្នុងសម័យនោះ មានព្រះអរហន្តចំនួន ៧ រូប គឺ: ព្រះពុទ្ធ ១ អង្គ បញ្ចវគ្គិយ ៥ រូប យសត្ថេរ ១ អង្គ ។***

*លំដាប់នោះ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រៃចីវរ និងបាត្រ ក្នុងបុព្វណ្ហសម័យ ទ្រង់យាងទៅកាន់ផ្ទះរបស់គហបតី មួយអន្លើដោយយសត្ថេរ ដល់ហើយទ្រង់ក៏ឡើងគង់លើអាសនៈ ដែលគហបតីតាក់តែងទុក ។ ចំណែកមាតា និងអតីតភរិយា នៃព្រះយស ក៏ចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធ ហើយអង្គុយក្នុងទីដ៏សមគួរ ព្រះសាស្ដាទ្រង់សម្ដែងនូវអនុបុព្វីកថា ដល់ស្រីទាំងឡាយនោះ លុះចប់ធម៌កាលណា ស្រីទាំងពីរនាក់គឺមាតា និងអតីតភរិយា នៃព្រះយស ក៏បានសម្រេចសោតាបត្តិផល ហើយថ្វាយខ្លួនជាឧបាសិកាក្នុងពេលនេះ ។ ជនទាំងឡាយមានជីតានៃព្រះយសជាដើម ក៏អង្គាសព្រះយស និងព្រះសាស្ដាដោយខាទនីយភោជនីយាហារដ៏ឧត្ដម ដោយផ្ទាល់ដៃខ្លួនហើយបវរណាចំពោះព្រះសាស្ដ ។ ទ្រង់ញ៉ាំងជនទាំងឡាយនោះ ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់យាងត្រឡប់ទៅវិញ ។ គ្រហស្ថទាំងឡាយ ៤ នាក់ ជាសំឡាញ់នៃព្រះយស សុទ្ធសឹងតែជាបុត្រា នៃត្រកូលអនុសេដ្ឋី ក្នុងនគរពារាណសីគឺ* ***វិមល ១ សុពាហុ ១ បុណ្ណជិ ១ គវម្បតិ ១*** *បាន ឮថា យសកុលបុត្ត ចេញសាងបព្វជ្ជា ក៏គិតនឹងទៅបួសតាម ទើបនាំគ្នា ទៅកាន់សំណាក់ ព្រះយសត្ថេរ ។*

ព្រះយសត្ថេរ ក៏នាំអតីតសំឡាញ់ទាំង ៤ នាក់ ចូលទៅកាន់សំណាក់ ព្រះសាស្ដា ក្រាបបង្គំទូលតាមដំណើរ ។ ព្រះអង្គទ្រង់ទូន្មាន ប្រៀនប្រដៅ សម្ដែងអនុបុព្វីកថា ដល់កុលបុត្តទាំង ៤ នាក់ ។ ឪពុកកុលបុត្តទាំងនោះ ក៏សូមឧបសម្បទា ដល់កុលបុត្តទាំង ៤ នាក់ ។

គ្រាក្រោយមកទៀត មានគ្រហស្ថ ៥០ នាក់ នាំគ្នាទៅកាន់ សំណាក់ព្រះយសត្ថេរ ៗ ក៏នាំទៅកាន់ព្រះសាស្ដា ។ ព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានប្រៀនប្រដៅ ហើយសម្ដែងអនុបុព្វីកថា កុលបុត្តទាំង ៥០ នាក់ ក៏សូមបព្វជ្ជា និងឧបសម្បទា ព្រះឈ្មះមារទ្រង់ប្រទានបព្វជ្ជា និងឧបសម្បទា ។ ភិក្ខុទាំងឡាយនោះ មានចិត្តរួចអាសវៈ ទាំងអស់អង្គ ក្នុងកាលនោះ មានព្រះអរហន្តចំនួន ៦១ ព្រះអង្គកើតឡើងក្នុងលោក ។

លំដាប់នោះ ព្រះសាស្ដាមានព្រះពុទ្ធដីកាថា"ម្នាលភិក្ខុទាំងឡាយ, តថាគតរួចហើយចាកអន្ទាក់ទាំងពួង ទេវតា និងមនុស្សទាំងឡាយ ឯណាមានក្នុងលោកនេះ, អ្នកទាំងឡាយ ចូលត្រាច់ទៅកាន់ចារិក ចូលដោះទេវតា និងមនុស្សទាំងឡាយនោះ ឲ្យរួចចាកអន្ទាក់ផងចុះ អ្នកចូលសម្ដែងនូវធម៌ មានពីរោះបទដើម បទកណ្ដាល និង បទ

ខាងចុង ឲ្យដល់ទេវតា និង មនុស្សផងចុះ ដ្បិតថា សត្វទាំងឡាយ ដែលមានធូលីគឺ កិលេសក្នុងភ្នែកតិច បើមិនបានស្តាប់ទេ មុខជាសាបសូន្យចាកព្រះសទ្ធម្ម ដ៏ប្រសើរ, ចំណែកតថាគត នឹងទៅកាន់ប្រទេសឧរុវេលា, អ្នកទាំងឡាយ ចូលទៅកាន់ចារិក ដើម្បីសម្តែងនូវធម៌ ប្រកាសនូវសាសនព្រហ្មចរិយៈ ដល់សត្វទាំងពួងតាម និយាម ដែលតថាគតសម្តែងហើយ តែអ្នកទាំងឡាយ កុំទៅផ្លូវមួយពីរនាក់ឡើយ ។ ភិក្ខុទាំងឡាយ ក៏ទទួលតាម ព្រះពុទ្ធដីកា ក្រាបបង្គំលា ហើយចៀសចេញទៅ ។

ក្នុងសម័យនោះ មារាធិរាជមានចិត្តបាប ក៏ចូលទៅ កាន់សំណាក់ ព្រះសាស្តាក្រាបទូលថា " បពិត្រព្រះអង្គដ៏ ចម្រើន, ព្រះអង្គបានរួចចាកមារពន្ធន៍ទាំងពួង ហើយ ,តែព្រះអង្គ គង់មិនរួចពីដៃខ្ញុំ " ។ ព្រះពុទ្ធជាម្ចាស់ត្រាស់ តបថា "ម្នាលមារអើយ! សេចក្តីប្រាថ្នាក្នុងរូប សំឡេង ក្លិន រស សម្ផស្ស នៃតថាគតមិនមានឡើយ , តថាគតអាច កម្ចាត់បង់ នូវមច្ចុមារបាន" ។ មារស្តាប់ហើយក៏កើតទុក្ខ តូចចិត្ត ត្រឡប់វិលទៅវិញ ។

( ចប់យសបព្វជ្ជាបរិច្ឆេទទី១៥ )

✵✵✵✵✵

# ( ឧរុវេលនិគមនបរិច្ឆេទទី១៦ )

គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងនគរពារាណសី តាមអធ្យាស្រ័យ ហើយទ្រង់យាងសំដៅទៅឧរុវេលាប្រទេស ។ ក្នុងសម័យនោះ មានកុមារ **៣០នាក់** ជាពួកដ៏ច្រើន ជាសំឡាញ់នឹងគ្នាព្រមទាំងភរិយា ដើរត្រាច់ទៅក្នុងព្រៃ ។ ឯកុមារម្នាក់គ្មានភរិយា កុមារទាំងឡាយជាសំឡាញ់ នាំស្រីពេស្យាម្នាក់មកឲ្យ ហើយស្រីពេស្យានោះកាលបើកុមារទាំងពួង ធ្វេសប្រហែសដើរលេង ក្នុងព្រៃ, ក៏លួចយក នូវបង្វេចគ្រឿងប្រដាប់ រត់ចូលទៅក្នុងព្រៃ ។ចំណែកកុមារជាសំឡាញ់ ក៏ខ្វល់ខ្វាយជួយដើររក ស្រាប់តែជួប និងព្រះពុទ្ធជាម្ចាស់ ដែលកំពុងគង់នៅទៀបគល់ឈើ ហើយសាកសួររកស្រីនោះ ។ ព្រះអង្គទ្រង់សួរថា " ស្រីនោះ តើមានប្រយោជន៍ ដូចម្តេចដល់អ្នក ? " កុមារទាំងពួងក្រាបទូលសព្វគ្រប់ប្រការ ។ ព្រះអង្គទ្រង់សម្តែងអនុបុព្វីកថា កុមារទាំងឡាយស្តាប់ហើយ មាននូវសេចក្តីជ្រះថ្លាសូមបព្វជ្ជា និងឧបសម្បទា ។

ព្រះសាស្តា ជាអង្គម្ចាស់ ទ្រង់ក៏ប្រទានជា ឯហិភិក្ខុឧបសម្បទា ដល់កុមារទាំង **៣០ នាក់** ក្នុង**ព្រៃកប្បាសិក** ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់

ចារិក ស្តេចយាងទៅដល់ ប្រទេសឧរុវេលាសេនានិគមន៍ គង់នៅក្នុងទីនោះ ។ សម័យនោះមាន**ជដិល ៣** នាក់បងប្អូន និងគ្នាគឺ***ឧរុវេលកស្សបៈ១ នទីកស្សបៈ ១ គយាកស្សបៈ ១*** ។

## *ព្រះអង្គប្រោសជដិល ៣ នាក់បងប្អូន និងបរិវារ*



***ឧរុវេលកស្សបៈ*** មានបរិវារ ៥០០ នាក់ ***នទីកស្សបៈ*** មានបរិវារ ៣០០នាក់ ***គយាកស្សបៈ*** មានបរិវារ ២០០ នាក់ ។ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់សំណាក់ **ឧរុវេលា-កស្សបៈ** សូមនៅក្នុងរោងភ្លើង កស្សបៈទូលហេតុទាំងពួងថា មាននាគនៅ ព្រះអង្គក៏ចេះតែយាងទៅ នៅក្នុងរាត្រីនោះ

ស្តេចនាគបណ្តាលជាភ្លើង ឲ្យត្រូវកាយព្រះអង្គ ក៏មិនអាចបៀតបៀនព្រះអង្គបានឡើយ ។ ព្រះអង្គក៏ចាប់នាគដាក់ក្នុងបាត្រ យកទៅបង្ហាញជដិល***ឧរុវេលកស្សបៈ*** ឃើញហើយក៏កោតក្រែងដែរ តែនៅមិនប្រកាន់ថាវិសេសទេ ។



គ្រានោះឧរុវេលកស្សបៈ និមន្តដោយភត្តាហារ ដោយឃើញបាដិហារយ៍ ។ ព្រះអង្គយាងទៅគង់ នៅនាដងព្រៃ ស្តេចចតុលោកបាលទាំងបួន ចុះមកគាល់ព្រះអង្គក្នុង**បឋមយាម** ។ **ស្តេចសហស្សនេត្រ** ចុះមកគាល់ក្នុង**មជ្ឈិមយាម** មហាព្រហ្ម ចុះមកគាល់ក្នុង**បច្ឆិមយាម** បណ្តាល

ឲ្យព្រៃទាំងអស់ រុងរឿងដោយរស្មីផ្សេង ៗ គ្នា ។ លុះដល់ព្រឹកឡើងឱរុវេកស្សបៈ ទៅនិមន្តព្រះអង្គ ៗ ក៏ទូលលសួរ-



អំពីរឿង ក្នុងរាត្រីកន្លងមក, ព្រះអង្គត្រាស់តបទៅថា“ កស្សបៈអើយ! ស្ដេចចតុលោកបាលទាំងបួន មកក្នុងបឋមយាម, ព្រះឥន្ទមកក្នុងមជ្ឈិមយាម, មហាព្រហ្មជាគ្រូអ្នកមកក្នុងបច្ឆិមយាម ដើម្បីបម្រើតថាគត”, កស្សបស្ដាប់ហើយក៏យាងព្រះអង្គ ទៅសោយកត្តាហារ ។

លុះដល់ថ្ងៃក្រោយមកទៀត មហាយញ្ញក៏កើតឡើង ដល់ឧរុវេលកស្សបៈ គឺជនដែលនៅក្នុង**ដែនមគធៈ** នាំខាទនីយមក ។ ឧរុវេលកស្សបៈ គិតមិនចង់ឲ្យព្រះអង្គយាងមកក្នុងថ្ងៃនោះ, ព្រះអង្គជ្រាបបរិវិតក្ក នៃកស្សបៈទាំងអស់ ។

លុះព្រឹកឡើង ព្រះអង្គទ្រង់យាងទៅខ្ញុំព្រះឱស្ឋ ឯស្រះ***អនោតត្ត*** ហើយទ្រង់យាងទៅបិណ្ឌបាត្រ ***ឯឧត្តរកុរុទ្វីប*** បានហើយ ទ្រង់យាងមកសោយ ទៀបស្រះអនោតត្ត ទើបយាងមកគង់ ក្នុងដងព្រៃនោះវិញ ។

លុះដល់វេលាថ្ងៃរសៀល ឧរុវេលកស្សបៈ ទៅកាន់សំណាក់ព្រះអង្គ ហើយទូលថា ហេតុអ្វីបានជាសមណៈមិនទៅក្នុងវេលាព្រឹកមិញនេះ ? ព្រះអង្គក៏សម្ដែងហេតុទាំងពួងប្រាប់កស្សបៈ ។ កស្សបៈក៏គិតថា សមណនេះ គ្រាន់តែដឹងបរិវិតក្កប៉ុណ្ណោះ មិនមែនជាវិសេសដូចអញទេ ។

ក្នុងសម័យកាលនោះ សំពត់បង្សុកូលកើតឡើងដល់ព្រះតថាគត ។ ព្រះអង្គយាងទៅយកសំពត់ ដែលជនរុំអសុភនាងបុណ្ណាទាសី យកទៅចោលក្នុង ***អាមកសុសាន*** ព្រះអង្គបរិវិតក្កគិត នឹងលាងសំពត់ ខណៈនោះ ព្រះឥន្ទចុះមក ជីកស្រះបោក្ខរណី ថ្វាយព្រះសុគត ហើយទ្រង់បរិវិតក្កថា តថាគតនឹងឈ្វីក្នុងទីណា ។ ព្រះឥន្ទនាំផែនថ្មធំ

មកថ្វាយ ព្រះអង្គឈ្វីហើយ ទ្រង់បរិវិតក្កថា តថាគត នឹងពាក់ក្នុងទីឯណា ទេវតាបង្អោនមែកថ្វាន់ មកថ្វាយ ព្រះអង្គ ៗ ក៏ពាក់ ។ ទើបទ្រង់បរិវិតក្កថា តថាគតនឹងហាល ក្នុងទីឯណា ព្រះឥន្ទក៏លើកផែនថ្មធំ បង្អោនទៅថ្វាយ បានឃើញសម្ភារៈ មានថ្មជាដើម ក៏ទូលសួរព្រះអង្គ ៗ ប្រាប់ហេតុសព្វគ្រប់ប្រការ កស្សបៈក៏បរិវិតក្កថា មិនមែន អរហន្តវិសេសដូចអញទេ ។

លំដាប់អំពីនោះ មកទៀត ព្រះសាស្តា ទ្រង់ធ្វើនូវ បាដិហារិយ៍ ៤ ប្រការ គឺ ព្រះអង្គបញ្ជូនកស្សបៈ មកទ្រង់ ហោះទៅនាំផ្លែស្វាយ ពីព្រៃហេមវន្ត នាំផ្លែកន្ទួតព្រៃ និងនាំ ផ្លែស្រម៉ ទ្រង់យាងទៅកាន់ឋានតាវត្តឹង្ស នាំយកនូវផ្កា ***ពារិច្ឆត្តកព្រឹក្ស*** ជាទិព្វបានមក ទ្រង់មកគង់ក្នុងរោងភ្លើង មុន កស្សបៈអស់វារៈ ៤ ដង កស្សបៈក៏បរិវិតក្កដូចមុន ។ ក្នុង ថ្ងៃមួយជដិលទាំងឡាយ ប្រាថ្នានឹងបង្កាត់ភ្លើង ពុះឧសមិន បែកទើបគិតថា ហេតុដែលមានយ៉ាងនេះ ? ព្រោះឫទ្ធិ មហាសមណៈពិត ។ ព្រះសព្វញ្ញូទ្រង់តបទៅថា អ្នកចូរ ពុះឧសតាមប្រាថ្នាចុះ ។

ខណៈនោះ ជដិលក៏ពុះឧសបែកទាំងអស់ ថ្ងៃមួយ ជដិលប្រាថ្នា និងបង្កាត់ភ្លើង ៗ មិនឆេះ ក៏គិតដូចមុន ។

ព្រះអង្គទ្រង់ជ្រាប ក៏ត្រាស់អនុញ្ញាត ឲ្យភ្លើងឆេះឡើង ជដិលបូជាភ្លើងស្រេច ហើយរំលត់ភ្លើង មិនរលត់ក៏គិត ដូចមុន, ព្រះអង្គអនុញ្ញាត ឲ្យភ្លើងរលត់ទៅ កស្សបៈបរិវិតក្ក ដូចមុន ។ ក្នុងរដូវដែលរងា ដោយទឹកសន្សើម ធ្លាក់ចុះច្រើននោះ ជដិលទាំងឡាយ ចុះងូតទឹកក្នុង**ស្ទឹងនេរញ្ជរា** ឡើងមកមានកិរិយារងាខ្លាំង ។



ខណៈនោះ សម្ដេចព្រះអរហន្ត ទ្រង់និម្មិតបង្រ្គាន ៥០០ នាក់ ឲ្យជដិលទាំងនោះអាំង, ម្ញឹងដែរពួកជដិលទាំងនោះ ក៏នៅមានបរិវិតក្កដូចមុនទៀត ។

ថ្ងៃមួយមហាមេឃ តាំងឡើង ក្នុងកាលមិនគួរបណ្ដាលឲ្យជន់លិចគ្រប់អន្លើ ។ ចំណែកព្រះមហាករុណាទ្រង់គង់នៅក្នុងទីឯណា ទឹកមិនលិចក្នុងទីនោះ បែរជាមានសុទ្ធតែធូលីហុយទៅវិញ ។ ចំណែកឧរុវេលកស្សបៈគិតថា "ព្រះមហាសមណៈ ប្រហែលជាលេច ក្នុងទឹកស្ទឹងហើយ" ទើបជិះទូក ជាមួយនឹងកូនសិស្ស ទៅមើលឃើញព្រះអង្គ គង់ក្នុងទីមានទឹកជា កំផែងជុំវិញ ក៏ប្រាប់ឲ្យព្រះអង្គ ទ្រង់ឡើងគង់លើទូក ។



ព្រះអង្គមិនព្រមឡើង ហើយក៏ហោះ ទៅលើអាកាសវិញ ចុះពីអាកាសមក ទើបស្ថិតលើទូកឧរុវេលកស្សបៈ ៗ ក៏នៅតែមានបរិវិតក្កដូចមុនទៀត ។ ចាប់ផ្ដើមពីព្រះអង្គយាង ចាក**ព្រៃឥសិបតនៈ** ក្នុងរនោច ខែកត្តិកមកគង់ឯប្រទេសឧរុវេលា រាប់ជាខែមកបានពីរខែ ដរាបដល់ថ្ងៃពេញបូណ៌មី ខែបុស្ស ។ ក្នុងរវាងនេះ ព្រះអង្គទ្រង់សំដែងបាដិហារិយ៍ផ្សេង ៗ ចំនួន ១៥០០ បែប, ក៏ឧរុវេលកស្សបៈនៅតែរឹងរូសដដែល ព្រះសាស្ដាទ្រង់បរិវិតក្កថា "តថាគតញុំាំងជដិលនេះ ឲ្យតក់ស្លុត " ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកា នឹងកស្សបៈថា ម្នាលជដិល អ្នកមិនមែនជាអរហន្តវិសេសទេ ម្ដេចក៏ប្រកាន់ថា ជាអរហន្តវិសេសយ៉ាងនេះ ? កស្សបៈបាន ឮព្រះពុទ្ធដីកា ក៏ខ្ទាចក្រាបទៀបព្រះបាទា ហើយទូលសូមបព្វជ្ជា និង ឧបសម្បទា, ព្រះសាស្ដា ទ្រង់បង្គាប់ឲ្យទៅលាជដិល ជាសិស្សទាំង ៥០០ នាក់, កស្សបៈទទួលតាម ។ ពួកកូនសិស្ស ក៏ព្រមចូលបួសផង ហើយយកគ្រឿងបរិក្ខារ បណ្ដែតទឹកចោលទាំងអស់ ។

ព្រះសាស្ដាជាម្ចាស់ ទ្រង់មានព្រះទ័យករុណា ប្រទានបព្វជ្ជា និង ឧបសម្បទាជាឯហិភិក្ខុ ។ ចំណែក**នទីកស្សបៈក្ដី គយាកស្សបៈក្ដី** បានឃើញគ្រឿងបរិក្ខារ អណ្ដែតទឹកទៅ



សម័យនោះ **នទីកស្សបៈ** ក៏នាំបរិវារ ៣០០ នាក់ **គយាកស្សបៈ** នាំបរិវារ ២០០ នាក់ មកកាន់សំណាក់ **ឧរុវេលកស្សបៈ** ហើយសាកសួរ ដឹងហេតុទាំងពួង ក៏បណ្តែតគ្រឿងបរិក្ខារ ក្នុងទឹកទាំងអស់ ហើយសូមបព្វជ្ជា និង ឧបសម្បទា ។

ព្រះសាស្តា ទ្រង់ប្រទាន ឧបសម្បទាជាឯហិភិក្ខុ ស្រេចហើយ ទើបទ្រង់សំដែង **អាទិត្តបរិយាយសូត្រ** លុះចប់ក៏ជដិលទាំង ១០០០ នាក់ បានសម្រេចព្រះអរហត្ត ។



វីឯព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវឧបនិស្ស័យ ក្នុងបុរេជាតិ នៃជដិលទាំងនោះ ប្រទានធម៌ទេសនា ឲ្យឋិតនៅក្នុងមគ្គ និង ផល , ព្រះអង្គមានព្រះខីណាស្រព ជាបរិវារ យាងទៅកាន់ **លដ្ឋិវនុយ្យាន** (១) ជាឧបចារនៃនគរ **រាជគហៈ** ដើម្បីដោះបដិញ្ញា នៃព្រះបាទពិម្ពិសារ ។

១.**លដ្ឋិវនុយ្យាន:** *( ឧទ្យាន ព្រៃត្នោតក្រមុំ)*

# ព្រះអង្គទ្រង់យាងទៅដោះបដិញ្ញានៃព្រះបាទពិម្ពិសារ



ក្នុងសម័យកាលនោះ ព្រះសាស្ដា ទ្រង់យាងដល់ឧទ្យាន, នាយឧទ្យាន បានឃើញព្រះអង្គ ក៏ក្រាបបង្គំទូលព្រះរាជា, ព្រះមហាក្សត្រ ទ្រង់ជ្រាបហើយ ស្ដេចក៏យាងចេញពីនគរ មួយអន្លើដោយព្រាហ្មណ៍ និង គហបតី ១២ ម៉ឺន ទៅកាន់ឧទ្យាន ដល់ហើយថ្វាយបង្គំ ព្រះដ៏មានព្រះភាគស្រេចហើយ ស្ដេចគង់ក្នុងទីដ៏សមគួរ ។ ចំណែកព្រាហ្មណ៍ និង គហបតី ពួកខ្លះ ថ្វាយបង្គំ ហើយអង្គុយនៅ ពួកខ្លះ ថ្វាយបង្គំហើយ ក៏ពោលនូវ **សម្មោទនីយក**ថា[១] ផ្សេងៗ ពួកខ្លះក៏ស្ងៀម ពួកខ្លះ ក៏មានបរិវិតក្កថា -

*សម្មោទនីយកៈ សម្ដីគួររីករាយ ,គួរត្រេកអរ, សម្ដីរាក់ទាក់*

មហាសមណៈ ប្រព្រឹត្តិព្រហ្មចរិយៈ ក្នុងសំណាក់ឧរុវេលកស្សបៈ ឬ ឧរុវេលកស្សបៈ ប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមហាសមណៈ, អ្នកណា ប្រសើរជាងអ្នកណា?

លំដាប់នោះ ព្រះអង្គទ្រង់ជ្រាបវារៈចិត្ត ដោយញាណព្រះអង្គ ទើបមានព្រះពុទ្ធដីកា និង ឧរុវេលកស្សបៈ ឲ្យកាត់សេចក្តីសង្ស័យ នៃពួកព្រាហ្មណ៍ និង គហបតី ។ ឧរុវេលកស្សបៈ បានដឹងពុទ្ធាធិប្បាយ ក៏ហោះឡើងកាន់អាកាស កម្ពស់មួយដូរត្នោត ក៏បញ្ចេញវាចាថា " ***ព្រះពុទ្ធជាម្ចាស់ ជាគ្រូនៃខ្ញុំ ៗ ជាសាវ័ក នៃព្រះពុទ្ធជាម្ចាស់*** " គ្រប់វារៈទាំង ៧ ដង ។ មហាជនមានចិត្តជ្រះថ្លា ហើយក៏ពោលសរសើរព្រះគុណគ្រប់ ៗ គ្នា ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងនូវ ***មហានារទជាតក*** ដោយពិស្តារ លុះចប់ព្រាហ្មណ៍ និង គហបតី ១១ ម៉ឺន មានព្រះរាជា ជាប្រធាន ក៏ស្ថិតនៅក្នុងសោតាបត្តិផល ព្រាហ្មណ៍ និង គហបតី ១ ម៉ឺនទៀត បានស្ថិតនៅក្នុង ព្រះត្រៃសរណគមន៍ ។

## (ចប់ឧរុវេលនិគមនបរិច្ឆេទទី១៦)

# (អគ្គសាវ័កបព្វជ្ជាបរិច្ឆេទទី១៧)

ក្នុងសម័យនោះឯង ជនទាំងឡាយ អ្នកក្រុងរាជគ្រឹះ មានចំនួន ១៨ កោដិ ទោះបីអ្នក ដែលបានឃើញ ព្រះសាស្តាហើយក្តី អ្នកដែលពុំបានឃើញក្តី ទាំងប្រុស ទាំងស្រី សុទ្ធតែមានសេចក្តីប្រាថ្នា ចង់ទស្សនាការ នូវ សម្តេចព្រះ**ភគវន្តអនន្តញាណ** ក៏បានប្រប្រៀតគ្នា ចូល ទៅកាន់ **លដ្ឋិវនុយ្យាន** ជាទីឋានដែលព្រះអង្គគង់នៅ ។ ទីឧទ្យាន ឥតមានកន្លែងសល់ចន្លោះ ពាសពេញដេរដាស សព្វទីទាំងអស់ ដោយប្រជាជននិករទាំងឡាយ ។



ក្នុងសម័យនោះ ស្ដេចសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ ប្លែងភេទជាមាណពម្នាក់ ចូលមកក្នុងទីចំពោះព្រះភក្ត្រ នៃព្រះបរមសាស្ដា ធ្វើទីបង្អៀតឲ្យប្រាសចាកដល់មហាជនដោយទេវានុភាព, កាលដែលព្រះសាស្ដាស្ដេចទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះ, មាណពនោះ ក៏បែកផ្លូវនាំមុខព្រះសាស្ដាទៅ ហើយច្រៀងសរសើរពុទ្ធគុណបណ្ដើរ ។ បណ្ដាជនទាំងឡាយឃើញ ហើយសួរគ្នាថា យីអើហ្ន៎! មាណពនេះមានរូបល្អអ្វីម្ល៉េះ! គួរឲ្យពិតពិលរមិលមើល គួរជាទីជ្រះថ្លា ជាកូនចៅនរណា ? មាណពនោះ ក៏ឆ្លើយឡើងជាបទព្រះគាថាៈ

***យោ ធីរោ សព្វធិ ទន្តោ សុទ្ធោ អប្បដិបុគ្គលោ***
***អរហំ សុគតោ លោកេ តស្សាហំ បរិចារកោ***

សេចក្ដីថាៈ ***អ្នកប្រាជ្ញណាទូន្មានឥន្ទ្រីយបាន ទាំងអស់ហើយមានព្រះហឫទ័យស្អាត រកបុគ្គលប្រៀបមិនបាន ឆ្ងាយចាកសត្រូវពោលគឺកិលេស មានដំណើរល្អក្នុងលោក ខ្ញុំជាអ្នកបម្រើអ្នកប្រាជ្ញនោះ ។***

ព្រះដ៏មានព្រះភាគ មួយអន្លើដោយ ព្រះភិក្ខុសង្ឃទ្រង់យាងចូលទៅកាន់ ព្រះរាជនិវេសន៍ នៃ**ព្រះបាទមាគធសេនិយពិម្ពិសារ** ។ ព្រះរាជា ទ្រង់អង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនី

យាហារ ទើបទ្រង់ព្រះចិន្តាថា “**វេឡុវ័នឧទ្យាន** មិនឆ្ងាយពេកមិនជិតពេក ជាទីល្មមទៅមកបានដោយងាយ គួរអាត្មាអញថ្វាយឧទ្យាននេះ ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន” ហើយទ្រង់ក្រាបទូល ព្រះដ៏មានព្រះភាគថាៈ



***ខ្ញុំព្រះអង្គ សូមថ្វាយ នូវឧទ្យានវេឡុវ័ន ចំពោះព្រះអង្គ និងព្រះភិក្ខុសង្ឃ*** ។ ព្រះសាស្តាក៏ទ្រង់ទទួល គង់នៅក្នុងឧទ្យានវេឡុវ័ននោះ ហើយទ្រង់អនុញ្ញាតអារាម ដល់ព្រះភិក្ខុសង្ឃ ក្នុងព្រះសាសនា ។

សម័យនោះ សញ្ជ័យបរិព្វាជក នៅអាស្រ័យក្នុងក្រុងរាជគ្រឹះ មួយអន្លើដោយបរិព្វាជកបរិស័ទ ច្រើនចំនួន ៥០០ រូប ។ ព្រះសារីបុត្ត និង ព្រះមោគ្គល្លាន ក៏ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់សញ្ជ័យបរិព្វាជកនោះដែរ ។ លោកទាំងពីររូបនោះ បានប្ដេជ្ញានឹងគ្នាថា អ្នកណាបានដឹងនូវអមតធម៌មុន, អ្នកនោះគប្បីប្រាប់ដល់ម្នាក់ទៀត ។

នាកាលនោះ **ព្រះអស្សជិត្ថេរ** ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹក ប្រកបដោយឥរិយាបថរម្យទមគួរ ជាទីជ្រះថ្លា ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ បរិព្វាជកឈ្មោះ**សារីបុត្ត** បានឃើញព្រះអស្សជិ ដ៏មានអាយុក៏គិតថា "ឱហ្ន៎! ជនទាំងឡាយឯណាជាអរហន្តក្ដី បានដល់ហើយ នូវអរហត្តមគ្គក្ដីនៅក្នុងលោក, ភិក្ខុនោះ ប្រហែលជាពួក នៃជនទាំងនោះដែរ, គួរតែអាត្មាអញ ចូលទៅរកភិក្ខុនោះ ។ ប៉ុន្ដែកាលនេះជាកាលមិនគួរ ដើម្បីសួរនូវភិក្ខុនេះឡើយ ព្រោះលោកកំពុងត្រាច់ទៅបិណ្ឌបាត្រ " គិតដូច្នេះហើយ ក៏ដើរតាមជាប់ពីក្រោយទៅ, កាលបើព្រះអស្សជិត្ថេរ លោកទទួលបិណ្ឌបាត ហើយត្រឡប់មកវិញ, បរិព្វាជកឈ្មោះសារីបុត្ត ក៏ចូលទៅជិត ហើយពោលនូវពាក្យ ជាទីត្រេកអរល្មម

ឲ្យកើតសេចក្តីស្និតស្នាលបាន ក៏សួរព្រះអស្សជិថា "បពិត្រលោកម្ចាស់ដ៏មានអាយុ, ឥន្ទ្រីយរបស់លោក ក៏ស្រស់បស់សម្បុររបស់លោក ក៏ល្អស្អាតផូរផង់, តើលោកបួសចំពោះនរណា ? អ្នកណាជាគ្រូរបស់លោក ? ព្រះអស្សជិឆ្លើយថា "**ម្នាលអាវុសោ មានមហាសមណៈមួយព្រះអង្គ ជាសក្យបុត្ត** បេញចាកសក្យត្រកូល ហើយទ្រង់ព្រះផ្នួស, ខ្ញុំឯងក៏បួសតាម ព្រះមហាសមណៈនោះ ព្រះដ៏មានព្រះភាគនោះឯងជាគ្រូរបស់ខ្ញុំ" ។

បរិព្វាជកឈ្មោះ សារីបុត្តសួរថា "ចុះគ្រូរបស់លោកម្ចាស់ ពោលពាក្យដូចម្តេច ? សំដែងធម៌ដូចម្តេច ? ព្រះអស្សជិឆ្លើយថា " ម្នាលអ្នកដ៏មានអាយុ , អាត្មាជាភិក្ខុបួសថ្មី ទើបនឹងចូលមកកាន់ធម៌វិន័យថ្មី ៗ អាត្មាមិនអាចសំដែងធម៌ ដោយពិស្តារបានទេ, តែថាអាត្មា និងពោលនូវសេចក្តីយ៉ាងខ្លី ឲ្យអ្នកស្តាប់ "។ បរិព្វាជកឈ្មោះ**សារីបុត្ត**ទូលថា "សូមលោកម្ចាស់សំដែង ទោះបីតិចក្តី ច្រើនក្តី ឲ្យឃើញតែជា ទំនងលំអានមក ចុះមិនបាច់ពោលព្យញ្ជនៈ ឲ្យច្រើនឡើយ " ។ គ្រានោះឯង ព្រះអស្សជិត្ថេរ ដ៏មានអាយុ បានពោល នូវធម្មបរិយាយនេះថា:

***យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ***
***តេសញ្ច យោ និរោធោ ច ឯវំវាទី មហាសមណោ ។***

*សេចក្តីថា: ធម៌ទាំងឡាយណា តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុ នៃធម៌ទាំងឡាយនោះផង, មួយទៀត ទ្រង់ពោលនូវសេចក្តីរលត់ និងឧបាយជាគ្រឿងរលត់ នូវធម៌ទាំងឡាយនោះផង, ព្រះមហាសមណៈ មានវាទយ៉ាងនេះ ជាប្រក្រតី ។*

ក្នុងខណៈនោះឯង បរិព្វាជកឈ្មោះ **សារីបុត្ត** បានស្តាប់ធម្មបរិយាយនោះ ហើយក៏មានធម្មចក្ខុគឺ **សោតាបត្តិមគ្គញ្ញាណ** ប្រាសចាកនូវធូលី ប្រាសចាកនូវមន្ទិល ហើយចូលទៅរកបរិព្វាជកឈ្មោះ **មោគ្គល្លាន ៗ** បានឃើញ ពីចម្ងាយក៏សួរថា " ឥន្ទ្រីយរបស់អ្នក ស្រស់បស់អ្វីម៉្លេះ, ប្រហែលជាអ្នកបានដឹង នូវអមតធម៌ហើយឬ ? បរិព្វាជកឈ្មោះសារីបុត្ត ក៏ប្រាប់តាមដំណើរ ។ បរិព្វាជកឈ្មោះមោគ្គល្លានបានស្តាប់ ហើយក៏មានធម្មចក្ខុ ប្រាសចាកធូលី ទើបបបួលគ្នាថា "យើងនឹងទៅកាន់សំណាក់ ព្រះដ៏មានព្រះភាគអង្គនោះ ជាគ្រូរបស់យើង" ។ បរិព្វាជកឈ្មោះសារីបុត្ត ឆ្លើយថា "បរិព្វាជកចំនួន ២៥០ នាក់ អាស្រ័យនឹងយើង បានឃើញយើង ទើបនៅក្នុងទីនេះបាន , យើងត្រូវលាបរិព្វាជកទាំងនោះសិន " ។ ទើបសារីបុត្ត និង មោគ្គល្លាន ក៏ចូលទៅរកបរិព្វាជកទាំងនោះ ដល់ហើយ និយាយប្រាប់ថា " យើងទាំងឡាយ នឹងទៅកាន់សំណាក់ព្រះដ៏មាន -

ព្រះភាគ ” ។ បរិព្វាជកទាំងឡាយនោះ ឆ្លើយថា “បើលោកទាំងឡាយ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈ ,យើងទាំងអស់គ្នា នឹងជាបុគ្គលដូច្នេះដែរ “ ។ សារីបុត្ត និង មោគ្គល្លាន ក៏បបួលគ្នាចូលទៅកាន់សំណាក់ សញ្ជ័យបរិព្វាជក ពិតទូលតាមបំណងរបស់ខ្លួន ។ សញ្ជ័យបរិព្វាជកឆ្លើយថា“ មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ, យើងទាំង ៣ នាក់ នឹងគ្រប់គ្រងគណៈនេះ ” ។

សារីបុត្ត និង មោគ្គល្លាន ទទូចអង្វរករអស់វារៈ ពីរដងបីដង ក៏សញ្ជ័យបរិព្វាជក មិនព្រមយល់តាម ទើបសារីបុត្ត និង មោគ្គល្លាន ក៏នាំពួកបរិព្វាជកទាំង ២៥០ នាក់នោះ ចូលទៅកាន់វត្តវេឡុវ័នទៅ ។ ចំណែកខាងសញ្ជ័យបរិព្វាជក ក៏មានសេចក្ដីទោមនស្ស ដុះឡើង បណ្ដាលឲ្យក្ដៅក្រហាយ រហូតដល់ក្អួតឈាមចេញពីមាត់ ។

ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញសារីបុត្ត និង មោគ្គល្លាន កំពុងដើរមក ពីចម្ងាយលឹម ៗ ក៏ទ្រង់ត្រាស់ហៅ ភិក្ខុទាំងឡាយមកថា “ **ម្នាលភិក្ខុទាំងឡាយ ជនជាសំឡាញ់ និង គ្នាទាំង ២ នាក់ នោះឈ្មោះ *កោលិត* ១ *ឧបតិស្ស* ១ នឹងមកដល់ឥឡូវនេះហើយ, ហ្នឹងហើយជា-**

# អគ្គសាវ័កទាំងពីររូបបព្វជ្ជា



គូសាវ័ក របស់តថាគត ដែលជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ។

សម័យគ្រានោះ ព្រះសារីបុត្ត និង ព្រះមោគ្គល្លាន ចូលទៅកាន់សំណាក់ ព្រះដ៏មានព្រះភាគ សូមបព្វជ្ជា និង ឧបសម្បទាថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ គប្បីបាននូវបព្វជ្ជា និង ឧបសម្បទា ក្នុងសំណាក់ ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកចុះ, ធម៌ដែលតថាគត សម្តែងហើយដោយប្រពៃ អ្នកទាំងឡាយ ចូរប្រព្រឹត្ត នូវព្រហ្មចរិយធម៌នោះ ដើម្បីធ្វើនូវព្រះនិព្វាន

ជាទីបំផុត នៃទុក្ខដោយប្រពៃចុះ ។ ព្រះពុទ្ធដីកានេះឯង ជាឧបសម្បទារបស់លោក ដ៏មានអាយុទាំងនោះ ។

សម័យនោះឯង កុលបុត្រទាំងឡាយ អ្នកដែនមគធៈ ដែលមានឈ្មោះ ល្បីល្បាញ ៗ ក៏ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ ព្រះដ៏មានព្រះភាគដែរ ។ មនុស្សទាំងឡាយ ក៏ថ្កោលទោសឡើងថា សមណគោតមប្រតិបត្តិ ដើម្បីធ្វើមនុស្ស មិនឲ្យមានកូន ដើម្បីធ្វើឲ្យពួកស្រី ៗ ទៅជាមេម៉ាយ ដើម្បីផ្ដាច់វង្សត្រកូល ឥឡូវនេះបបួលជដិល ចំនួន ១.០០០ នាក់ ហើយបបួលទាំងជដិលចំនួន ២៥០ នាក់ ជាពួកសញ្ជ័យទៅទៀតផង បបួលកុលបុត្រដែលមានឈ្មោះល្បីល្បាញ ៗ ទៀតផង, តើតទៅទៀតនឹងនាំអ្នកណាទៅទៀត ។ ភិក្ខុទាំងឡាយបាន ឮ ហើយក៏ទៅក្រាបបង្គំទូល ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំដីនេះ នឹងមិននៅអស់កាលយូរប៉ុន្មានទេ យ៉ាងយូរណាស់ត្រឹម ៧ ថ្ងៃ កន្លងហួស ៧ ថ្ងៃ ទៅនឹងបាត់ទៅឯង, ម្នាលភិក្ខុទាំងឡាយ បើគេចោទដូច្នោះទៀត, អ្នកទាំងឡាយ ចូរចោទគេវិញថា ព្រះតថាគតទាំងឡាយ មានសេចក្ដីព្យាយាមមាំណែនាំសត្វ ដោយព្រះសទ្ធម្មដោយប្រពៃពិត,ហេតុដូចម្ដេច ក៏មានសេចក្ដីប្រណែនជាមួយពួក-



អ្នកប្រាជ្ញដែលជាអ្នកណែនាំដោយធម៌ ។

ក្នុងគ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅអាស្រ័យនៅស្រុក**កល្លវាឡគ្រាម** ក្នុងដែនមគធៈ ក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃ ដែលបួសមក លោកបានស្តាប់នូវ **ធាតុកម្មដ្ឋាន** បានសម្រេចនូវប្រជុំបី នៃមគ្គខាងលើ ហើយដល់នូវ**សាវកបារមីញាណ** ។

រីឯព្រះសារីបុត្ត កន្លងទៅកន្លះខែ រាប់ពីថ្ងៃដែលបួស-



មក លោកគង់នៅក្នុងគុហារឈ្មោះ ***សូករខាតា*** បានស្តាប់-
នូវ ***វេទនាបរិគ្គហសូត្រ*** ដែលព្រះសាស្តាកំពុងសម្តែង



ដល់ **ទីឃនខ** បរិព្វាជក ជាក្មួយរបស់ខ្លួនលោក ក៏បាន សម្រេច នូវសាវកបារមីញាណ ដូចជាបុគ្គលបរិភោគភត្ត ដែលដួសមកដើម្បីបុគ្គលដទៃ ។

# ចតុរង្គសន្និបាត



ក្នុងថ្ងៃនោះឯង សម្តេចព្រះបរមសាស្តា ទ្រង់ធ្វើនូវសាវកសន្និបាតក្នុង**វត្តវេឡុវ័ន** ទ្រង់ប្រទាន នូវនាទីជាអគ្គសាវក ដល់ព្រះថេរៈ ទាំងពីរនោះ គឺ **ព្រះសារីបុត្ត និង ព្រះមហាមោគ្គលាន** ទ្រង់សម្តែងនូវ **ឱវាទបាតិមោក្ខ** ក្នុងថ្ងៃ **១៥ កើត ពេញបូណ៌មី ខែ** មាឃ **ឆ្នាំ** រកា ។

( ចប់អគ្គសាវកបព្វជាបរិច្ឆេទទី១៧ )

✻✻✻✻✻

# (កបិលវត្ថុគមនបរិច្ឆេទទី១៨)

កាលដែល ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុង**វត្តវេឡុវ័ន** មួយអន្លើ ដោយភិក្ខុសង្ឃជាច្រើន មានអគ្គសាវ័កទាំងពីរ ជាប្រធានក្នុងកាលនោះ ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ជ្រាបដំណឹងថា ព្រះអង្គគង់ក្នុងទីនោះ ទើបត្រាស់ព្រះរាជបញ្ជាឲ្យអាមាត្យម្នាក់នាំបរិវារ ១ ពាន់ទៅនិមន្ត ។ អាមាត្យក៏ទទួលរាជឱង្ការនាំបរិវារ ទៅកាន់នគររាជគហៈ ចម្ងាយផ្លូវ ៦០ យោជន៍ ដល់ហើយ ក៏ចូលទៅស្តាប់ធម៌ទេសនា លុះចប់ធម៌ទេសនា បានសម្រេចអរហត្តផល ទាំងអស់គ្នា ហើយសូមបព្វជ្ជា និង ឧបសម្បទា ។ ព្រះអង្គទ្រង់ប្រទានជាឯហិភិក្ខុឧបសម្បទា អាមាត្យទាំងអស់ភ្លេច មិនបានទូលតាម ព្រះរាជបណ្តាំ ទើបព្រះបាទសុទ្ធោទនៈ បញ្ជូនអាមាត្យ ទៅទៀតតាមទំនងនេះ តាំងពីអាមាត្យម្នាក់ បរិវារ ១ ពាន់ ដរាបដល់អាមាត្យ ៩ នាក់ និង បរិវារ ៩ ពាន់ អស់វារៈ ៩ ដង ។

អាមាត្យទាំងអម្បាលនោះ សម្រេចកិច្ច របស់ខ្លួនហើយ ស្ងៀមនៅទាំងអស់ ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា " អាមាត្យដែលទៅ មិនបានក្រាបទូលដល់ព្រះអង្គ " ទើបប្រើ ***កាឡុទាយីអាមាត្យ*** ទៅនិមន្តព្រះអង្គ

ទៀត ។ កាឡុទាយីអាមាត្យ ក៏ទទួលតាម ព្រះរាជឱង្ការ ហើយសូមឲ្យ ព្រះអង្គអនុញ្ញាតឲ្យបួស , កាលបើ ព្រះរាជាទ្រង់ព្រម ទើបនាំបរិវារ ១.០០០ នាក់ ទៅដល់ វត្តវេឡុវ័ន បានស្តាប់ធម៌ ក៏បានសម្រេចព្រះអរហន្ត មួយអន្លើដោយបរិវារ ហើយសូមបព្វជ្ជា និង ឧបសម្បទា ព្រះអង្គទ្រង់ បំបួសជា ឯហិភិក្ខុទាំងអស់ ។ កាឡុទាយិត្ថេរ ក៏គិតថា " អាត្មាអញបាន សម្រេចមគ្គផល ហើយកាលនេះ គួរព្រះសាស្តា ទ្រង់យាងទៅកាន់ **នគរកបិលភ័ស្តុ** ក្នុងថ្ងៃ បុណ្ណមី ខែផល្គុន " ទើបចូលទៅក្រាបថ្វាយបង្គំ ព្រះអង្គ ពោលសរសើរ នូវផ្លូវទៅកាន់នគរកបិលភ័ស្តុ ដោយគាថា ៦០ ហើយទូលហេតុគ្រប់ប្រការថា បពិត្រព្រះអង្គ ដ៏ចម្រើន ព្រះបាទសិរីសុទ្ធោទនជា ព្រះពុទ្ធបិតានិរាសចាក ព្រះអង្គ យូរហើយ ទ្រង់មាន ព្រះរាជហឫទ័យ ចង់ឃើញព្រះអង្គ ទ្រង់ប្រើខ្ញុំព្រះអង្គ មកយាងសូមព្រះអង្គ ធ្វើនូវសេចក្តី អនុគ្រោះ ដល់ព្រះញាតិវង្ស ។

ព្រះដ៏មានព្រះភាគ ទ្រង់ទទួលថា ម្នាលឧទាយិប្រពៃ ហើយ, តថាគតនឹងធ្វើសេចក្តីសង្គ្រោះ ដល់ញាតិ, អ្នក ចូលប្រាប់ដល់ភិក្ខុសង្ឃចុះ ព្រះថេរៈក៏ប្រាប់ដល់ភិក្ខុសង្ឃ ។ ព្រះដ៏មានបុណ្យ មានភិក្ខុសង្ឃ ២ ម៉ឺនអង្គ ជាបរិវារ

យាងចាក **នគររាជគហៈ** ចំណែកស្តេចសក្យរាជ មានពុទ្ធបិតា ជាប្រធានបាន ឮដំណឹងថា ព្រះអង្គយាងមក មានសេចក្តីសោមនស្សណាស់ ក៏ប្រជុំគ្នាតាក់តែងផ្លូវលើកទង់ រោយរាយផ្កា ចាំទទួលព្រះអង្គ ហើយទៅដល់កបិលវត្ថុបុរី ចម្ងាយ ៦០ យោជន៍ ។



បញ្ជូនរាជកុមារកុមារី មានវ័យក្មេងជាង ព្រះអង្គឲ្យទៅទទួលមុន ។ លំដាប់នោះ ព្រះសាស្តា យាងឡើងកាន់ទូកធ្វង ទៅដល់ត្រើយនាយ ឡើងចាកទូក ទ្រង់សម្តែង

រូបសិរីផ្សាយ ទៅនូវឆព្វណ្ណរង្សី យាងចូលទៅកាន់ **និគ្រោធារាម** មួយអន្លើដោយព្រះខីណាស្រព២ម៉ឺនអង្គ ដល់ហើយគង់លើ**ពុទ្ធាសនៈ**ដ៏ប្រសើរ ស្ដេចសក្យរាជទាំងពួង មានព្រះបាទសិរីសុទ្ធោទនៈ ជាប្រធានប្រកាន់ខ្លួនថា ចាស់ជាងព្រះអង្គ ហើយក៏មិនថ្វាយបង្គំ ។



គ្រានោះ ព្រះសាស្ដា ជ្រាបអជ្ឈាស្រ័យ នៃព្រះញាតិ ទ្រង់ក៏សម្ដែង**យមកប្បដិហារិយ៍** និម្មិតទីចង្រ្កមកែវយាងចង្រ្កមឰដ៏អាកាស ហើយនិម្មិតជា ព្រះពុទ្ធមួយព្រះអង្គទៀតឲ្យដោះស្រាយបញ្ហា ។ ទ្រង់ត្រាស់សួរបញ្ហា ព្រះបាទ

សិរីសុទ្ធោទនៈ ឃើញបាដិហារិយ៍ មានបីតិសោមនស្ស មិនអាចទប់បាន ក៏លើកអញ្ជលីថ្វាយបង្គំ ដើម្បីឲ្យព្រះអង្គអត់ទោស ។ ព្រះរាជាថ្វាយបង្គំ ក្នុងកាលនោះឈ្មោះ **តតិយវន្ទនា** ។ ស្តេចសក្យរាជទាំងអស់ ឃើញព្រះពុទ្ធបិតាថ្វាយបង្គំព្រះអង្គ ហើយទើបយាង ចុះចាកអាកាសមកព្រះអង្គ ទ្រង់លើពុទ្ធាសនៈ ខណៈនោះ ភ្លៀង**បោក្ខរព័ស្ស**[១] ក៏ធ្លាក់ ចុះព្រះអង្គប្រារព្ធ ភ្លៀងបោក្ខរព័ស្ស សម្តែងនូវ **មហាវេស្សន្តរជាតក** ។ លុះចប់ទេសនា ស្តេចសក្យរាជក៏ក្រោកចាកអាសនា ថ្វាយបង្គំចៀសចេញទៅ និងមានអ្នកណាមួយ យាងព្រះអង្គឲ្យសោយ ក្នុងវេលាស្អែកទៀតក៏ទេ ។ លុះដល់ថ្ងៃស្អែកឡើង ព្រះដ៏មានព្រះភាគ ទ្រង់មានភិក្ខុសង្ឃ ២ ម៉ឺនអង្គ ជាបរិវារ យាងទៅកាន់នគរ ក្នុងភិក្ខាចារ វេលាត្រាច់ទៅ ដើម្បីបិណ្ឌបាត ផ្សាយទៅនូវរស្មី ៦ ពណ៌ ព្រះអង្គឈរ ទៀបគោលថ្ម**ឥន្ទខីល**[២] ពិចារណាថា ព្រះពុទ្ធពីបុរាណ ចូលទៅកាន់នគរ ដើម្បីទទួលភិក្ខារបស់រាជត្រកូលមុនឬដូចម្តេច ? ព្រះអង្គជ្រាបថា ព្រះពុទ្ធពីដើម រមែងត្រាច់ទៅ តាមលំដាប់ត្រកូល ទទួលភិក្ខា-

១.**ភ្លៀងបោក្ខរព័ស្ស ឬ ភ្លៀងបោក្ខព័ស់:** ភ្លៀងមានអាការៈដូចជា ធ្លាក់លើស្លឹកឈូក,បើអ្នកណាចង់ ទទឹកក៏ទទឹក បើអ្នកណាមិនចង់ទទឹក ក៏មិនទទឹក, ២.**គោលថ្មឥន្ទខីល:** សសរខឿនថ្មយ៉ាងមាំ.

បំពេញបិណ្ឌបាតចារិកវត្ត ជ្រាបហើយ ក៏ចូលតាមលំដាប់ផ្ទះ ដើម្បីបិណ្ឌបាត ។

មហាជនក្នុងនគរ ឃើញព្រះអង្គ ក៏ផ្អើលបើកបង្អួចទៅមើលគ្រប់ ៗ គ្នា ពោលថា ព្រះសិទ្ធត្ថរាជកុមារ ត្រាច់ចូលបិណ្ឌបាត ចំណែករាហុលមាតា ឮសំឡេងកោលាហល ក៏សួរស្រីបម្រើ ៗ ស្រីទាំងឡាយទូលថា ព្រះភស្តាព្រះនាង មកដល់នគរ ហើយកាន់បាត្រ ត្រាច់សូមភិក្ខា នាងពិម្ពាបានស្ដាប់ ក៏គិតថា ព្រះអយ្យបុត្ត កោសក់កោពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាវពស្ត្រ កាន់បាត្រដើរបិណ្ឌបាត ដូចម្ដេចទៅ ទើបនាងក្រោក យ៉ាងប្រញាប់បើក**សីហបញ្ជរ** (បង្អួចរាជដំណាក់) ទតឃើញព្រះអង្គ -



មានព្រះកាយរុងរឿង ដោយ**អសីត្យានុព្យញ្ជនៈ** ( អនុព្យញ្ជន៨០ ) ជាដើម ។ ព្រះនាងក៏ស្ទុត ព្រះរាជហឫទ័យទួញយំ ស្ទុះប្រញាប់ ទៅក្រាបបង្គំទូល ព្រះសិរីសុទ្ធោទនៈថា បពិត្រព្រះសម្មតិទេព ព្រះអយ្យបុត្តព្រះអង្គ ត្រាច់បិណ្ឌបាត ព្រះរាជាទ្រង់ព្រះសណ្ដាប់ ហើយក៏កើតសង្វេគទ្រង់ម្ចីម្នា ចុះចាកប្រាសាទ ចូលទៅកាន់សំណាក់ ព្រះពុទ្ធជាម្ចាស់ទូលថា មិនគួរអយ្យបុត្ត ដើរបិណ្ឌបាតដូច្នេះសោះ! ខ្ញុំនេះជាមនុស្សកម្សត់ទុគ៌ត មិនអាចថ្វាយភត្តាហារ ដល់ភិក្ខុសង្ឃទាំងអស់ ឬ ?



ព្រះសាស្តា ត្រាស់តបថា មហារាជ បិណ្ឌបាតចារិកវត្តនេះ ជាវង្សនៃតថាគត ពុំមែនជាវង្ស នៃខត្តិយជាតិទាំងពួងទេ ,ដ្បិតថា ជម្មតាព្រះពុទ្ធទាំងឡាយ រមែងចិញ្ចឹមជីវិត ដោយភិក្ខាចារិកវត្តនេះ ទើបព្រះពុទ្ធអង្គទ្រង់សម្តែងធម៌មានបទថា ***ឧត្តិដ្ឋេនប្បមជ្ជេយ្យ***......ច្នេះជាដើម ដល់ព្រះវររាជបិតា , លុះចប់គាថា ព្រះវរបិតាឋិតនៅក្នុងសោតាបត្តិផល ។

( ចប់កបិលវត្ថុគមនបរិច្ឆេទទី១៨ )

✵✵✵✵✵

# ( ពិម្ពាពិលាបបរិច្ឆេទទី១៩ )

លុះដល់ ថ្ងៃជាគម្រប់ពីរ សម្តេចព្រះភគវន្តមុនី ជាទីពឹងនៃលោក ទ្រង់សម្តែងធម៌ ដល់ព្រះនាងបជាបតិគោតមី កាលបើចប់ទេសនា ព្រះមាតុច្ឆាក៏ឋិតនៅក្នុងសោតាបត្តិផល ព្រះពុទ្ធបិតាបាន ឋិតនៅក្នុសកទាគាមិផល ។

លុះដល់ថ្ងៃទីបី ព្រះជិនស្រី ទ្រង់យាងទៅកាន់រាជនិវេសន៍ ព្រះពុទ្ធបិតាក៏ថ្វាយយាគូ និង ភត្តាហារ ដល់ភិក្ខុសង្ឃ និងព្រះពុទ្ធជាម្ចាស់ ហើយក្រាបទូលថា:



"បពិត្រព្រះសាស្តា កាលព្រះពុទ្ធអង្គ ធ្វើទុក្ករកិរិយាមាន ទេវតា ១ អង្គ ស្ថិតក្នុងអាកាសប្រាប់ខ្ញុំថា ព្រះរាជបុត្ត ព្រះអង្គ មិនសោយអាហារអស់ ៦ វស្សា មានព្រះកាយ ស្គាំងស្គម ដួលដេកធ្វើមរណកាល ក្នុងទីបំផុតនៃទីចង្រ្កម ទៅហើយកាល ដែលខ្ញុំ ឮ ពាក្យទេវតា , ខ្ញុំក៏តបទៅវិញថា យើងមិនជឿពាក្យអ្នកទេ , ឯព្រះរាជបុត្តយើង បើមិនបាន ត្រាស់ដឹងដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ, ទេវតា ក៏ប្រាប់ទៀតថា ព្រះរាជបុត្ត ដែលខំធ្វើទុក្ករកិរិយានោះ អស់ព្រះជន្មទៅហើយ, ខ្ញុំក៏នៅតែមិនជឿពាក្យទេវតានោះ ទៀត ។ ព្រះសាស្តាទ្រង់ ព្រះសណ្តាប់ ហើយក៏មាន ព្រះពុទ្ធដីកា តបទៅវិញថា បពិត្រមហារាជ កាលពីដើម តថាគតជាពោធិសត្វ, អាចារ្យទិសាបាមោក្ខ នាំឆ្អឹងពពែមក បង្ហាញព្រះអង្គប្រាប់ថា បុត្រនៃអ្នក ធ្វើកាលកិរិយាទៅ ហើយ ព្រះអង្គមិនជឿ ដូចកាលឥឡូវនេះដែរ ។

កាលបើសម្រេចភត្តកិច្ចរួចហើយ ព្រះសាស្តាទ្រង់ សម្តែង**ធម្មបាលជាតក**, លុះចប់ធម៌ទេសនា ព្រះពុទ្ធបិតា បានសម្រេចអនាគាមិផល ។ ទើបព្រះសាស្តា ធ្វើកិច្ចភត្តា អនុមោទនា និងធម៌ទេសនា ចំណែកព្រះនាងបជាបតិ-គោតមី និងស្រីបម្រើក៏អង្គុយស្តាប់ធម៌ទេសនាក្នុងទីនោះ ។



ព្រះបាទសុទ្ធោទនៈ មហារាជទ្រង់ទតព្រះនេត្រទៅពពួកនាងនារី មិនបានឃើញព្រះនាងពិម្ពាទេវី ទើបត្រាស់សួរថា ថ្ងៃនេះនាងយសោធរាពិម្ពាទេវី ទៅណាក៏មិនមក ? ទើបព្រះរាជាទ្រង់ប្រើស្រីបម្រើឲ្យទៅយាងមក ។ នាងបេសកាទៅដល់ ប្រាសាទព្រះនាង ស្រាប់តែឃើញព្រះនាងទ្រង់សំពត់កាសាវពស្ត្រ គង់នៅនាងបេសកា ឥតឱកាសនិង ទូលក៏អង្គុយស្ងៀម ។ នាងយសោធរាឃើញ នាងបេសកា ក៏មានព្រះសុវណ្ណីថា ព្រះពុទ្ធជាម្ចាស់ ដែលអាចសម្រេចប្រយោជន៍ ទាំងពួងអស់សេចក្តីករុណា ដល់ពិម្ពា

ហើយឬ ? បានជាទ្រង់កាត់អាល័យ អស់សេចក្ដីស្នេហា ឲ្យតែពិម្ពាខ្ញុំ នៅកំព្រាជាមួយ និងកូន ? តាំងពីព្រះអង្គ ចេញចោលពិម្ពា ទៅសាងបព្វជ្ជា ពិម្ពាមាន តែសេចក្ដី ទោមនស្ស ក្ដៅក្រហាយ ក្នុងចិត្តដរាបដល់សព្វថ្ងៃ, ពិម្ពា ស៊ីថ្នាំពិសឲ្យក្សយ ទៅជាជាងរស់នៅនាងបេសកា ទូលតប ទៅថា បពិត្រព្រះនាង ឥឡូវនេះ ព្រះវរបិតាឲ្យខ្ញុំម្ចាស់ មក យាងព្រះនាង ដ្បិតថាព្រះពុទ្ធជាម្ចាស់ ទ្រង់យាងមក ធ្វើភត្តកិច្ច គង់នៅក្នុងរាជនិវេសន៍ កំពុងសម្ដែងធម៌ ។

នាងពិម្ពាទ្រង់ព្រះសណ្ដាប់ ពាក្យនាងបេសកាក៏លើក ព្រះហស្ដគក់ឱរា ទ្រង់**ពិលាប** ( ព្រះកន្សែងថ្ងៃងរៀបរាប់ ) ហើយទើបតបទៅថា ព្រះវរបិតាឲ្យមកហៅយើង ឲ្យឡើង ទៅមើលព្រះសាស្ដា ឬ ប្រការដូចម្ដេច ? នាងបេសកា ទូលថា ព្រះវរបិតា ឲ្យយាងព្រះនាងទៅ ។ នាងពិម្ពា តបទៅថា ម្នាលនាងបេសកា ខ្លួនយើងជាស្រីកាឡកណ្ណី មានឥន្ទ្រីយវិកល គ្រប់ប្រការ នឹងឡើងទៅគាល់ ក្រែងអាប់ ព្រះចេស្ដា, កាលគ្រាមុន ៗ ព្រះភស្ដាធ្លាប់ចេញចូល កាន់ទីលំនៅជានិច្ច ចុះហេតុអ្វីឥឡូវនេះ ក៏ឲ្យពិម្ពា ទៅ គាល់ឯទីដទៃវិញ ? ចូលនាងទៅក្រាបទូល ព្រះវរបិតា តាមពាក្យយើងថា នាងពិម្ពាជា ស្រីកាឡកណ្ណី បានជា

ព្រះរាជបុត្រ ចេញចោល ទៅសាងបព្វជ្ជា,ហេតុយើងមិន ទៅគាល់ទេ, មួយទៀត ចូលនាងទៅក្រាបទូលថា ពិម្ពា សូមថ្វាយបង្គំ លាទៅស្លាប់ ក្នុងថ្ងៃនេះ ហើយនាង បេសកា ក៏ក្រាបបង្គំទូល តាមគ្រប់ប្រការ ។

ព្រះមហាក្សត្រ ទ្រង់សណ្តាប់សេចក្តី ដែលនាងក្រាប បង្គំទូលដូច្នោះហើយ ស្តេចទ្រង់ទូល ព្រះសម្ពុទ្ធឲ្យជ្រាប គុណ របស់ព្រះនាងពិម្ពា សព្វគ្រប់ប្រការ ស្តេចទ្រង់ អារាធនានិមន្ត ព្រះអង្គឲ្យយាងទៅ ។ ព្រះសាស្តាទ្រង់ ព្រះសណ្តាប់ សេចក្តីអារាធនា ព្រះពុទ្ធបិតា ទ្រង់ក៏មាន ព្រះពុទ្ធដីកាថា គួរណាស់បិតា បើតថាគតមិនទៅកាន់ និវេសន៍នាងពិម្ពា ក្នុងថ្ងៃនេះទេ ព្រះនាងនឹងបែកហឬ ទ័យក្ស័យពិត, មួយទៀត រាហុលមាតានេះ មានគុណ ដល់តថាគតជាច្រើន អំពីអតីតកាលមក ទើបព្រះអង្គ ក្រោកចាកអាសនា ប្រទានបាត្រថ្វាយព្រះបិតា ឲ្យស្តេច តាមទៅផង ទ្រង់ឲ្យភិក្ខុសង្ឃ គង់ចាំក្នុងរាជនិវេសន៍ ព្រះអង្គយាងទៅជា មួយអគ្គសាវកទាំងពីរអង្គ ទ្រង់មាន ព្រះពុទ្ធដីកា និងសាវកថា រាហុលមាតានេះ មានគុណ ដល់តថាគត ជាច្រើន, បើនាងមកទ្របាទាតថាគត អ្នក កុំឃាត់ឡើយ ទើបព្រះអង្គផ្សាយ រស្មីចេញពី ព្រះវរកាយ

ស្តេចយាងទៅកាន់ប្រាសាទ ព្រះនាងពិម្ពាដល់ហើយ ទ្រង់គង់លើអាសនៈ បង្គាប់នាងទាសី ឲ្យទៅទូលព្រះនាង ។ ព្រះនាងពិម្ពា ទ្រង់ព្រះសណ្តាប់ហើយ ក្រោកចេញមកឃើញព្រះអង្គ ក៏ពិលាបរៀបរាប់ ចូលទៅទ្រព្រះបាទាព្រះពុទ្ធ ហើយសម្តែងហេតុទាំងពួងទូល ព្រះសាស្តាយកព្រះកេសាទ្រព្រះបាទាសោកាយ៉ាងខ្លាំង ។



ព្រះសាស្តា មានព្រះពុទ្ធដីកា និងព្រះវរបិតាថា បពិត្រមហារាជ ព្រះនាងយសោធរា ដែលមានចិត្តស្នេហាចំពោះតថាគត ក្នុងកាលឥឡូវនេះមិនជា-



អស្ចារ្យ ដូចកាលពីមុនឡើយ, កាលនាងកើតជាសត្វតិរច្ឆាននោះ មានចិត្តស្នេហាក្រៃលែង ជាងនេះទៅទៀត ទើបទ្រង់សម្ដែង **ចន្ទកិន្នរីជាតក** ដោយពិស្ដារ បន្ទោបង់សេចក្ដីសោក ព្រះនាងពិម្ពា, លុះចប់ទេសនា ព្រះនាងសម្រេចសោតាបត្តិផល ហើយព្រះសាស្ដា ទ្រង់យាងទៅកាន់វិហារវិញ ។

( ចប់ពិម្ពាពិលាបបរិច្ឆេទទី១៩ )

# ( សក្យបព្វជ្ជាបរិច្ឆេទទី២០ )

ក្នុងថ្ងៃជាគម្រប់បួន ព្រះសាស្ដា ទ្រង់យាងទៅកាន់និវេសន៍ ***ព្រះនន្ទកុមារ*** ដើម្បីទទួលបិណ្ឌបាត ក្នុងពេលដែលទ្រង់កំពុងធ្វើ **វិវាហមង្គល** ទ្រង់ធ្វើភត្តកិច្ចស្រេច ហើយទើបទ្រង់ប្រទានបាត្រ ឲ្យព្រះនន្ទកុមារ ហើយសម្ដែង**មង្គលកថា** ស្រេចហើយ ក៏យាងចេញមក, ព្រះអង្គមិនទទួលបាត្រ ពីនន្ទកុមារវិញទេ ។



ព្រះនន្ទកុមារ មិនហានថ្វាយបាត្រ ចំពោះព្រះអង្គវិញ ក៏កាន់បាត្រ យាងទៅតាមក្រោយទៅ ។ ស្រីបម្រើឃើញព្រះនន្ទ យាងតាមក្រោយព្រះសម្ពុទ្ធទៅ ក៏ចូលទៅទូលព្រះនាង**ជនបទកល្យាណី** ។ ព្រះនាងជ្រាបហេតុនោះ ក៏ចេញមកផ្តាំឲ្យ ព្រះនន្ទត្រឡប់មកវិញឆាប់ ៗ ។ ព្រះនន្ទស្តាប់ហើយចាំជាប់រហូត ។ លំដាប់នោះ ព្រះនន្ទក៏យាងតាមព្រះអង្គរហូតដល់ **និគ្រោធារាម** ។ *ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់សួរព្រះនន្ទថា អ្នកបួស ឬ ? ព្រះនន្ទមិនហ៊ានប្រកែក ក៏ទទួលព្រមបួស តាមព្រះអង្គ ក្នុងគ្រានោះឯង ។*



ព្រះដ៏មានព្រះភាគ ទ្រង់ក៏បំបួសព្រះនន្ទ ក្នុងថ្ងៃនោះ លុះដល់ថ្ងៃ ជាគម្រប់ ៧ ព្រះនាងពិម្ពា តាក់តែងរាហុលកុមារ ហើយបញ្ជូនឲ្យមក សូមកំណាប់ទ្រព្យ ក្នុងវេលា ដែលព្រះអង្គ ទ្រង់យាងបិណ្ឌបាត រាហុលកុមារទៅតាម ព្រះអង្គដល់វិហារ , ព្រះអង្គទ្រង់ក៏ប្រទាន **លោកុត្តរសម្បត្តិ** ទើបទ្រង់បង្គាប់ ព្រះសារីបុត្តបំបួស ។ ចំណែក **អនាថបិណ្ឌិកសេដ្ឋី** កាលដែលជួប និង ព្រះអង្គ កាលទ្រង់គង់នៅក្នុង **នគររាជគហៈ** បានថ្វាយទានដល់ព្រះអង្គ និងភិក្ខុសង្ឃ ហើយអារាធនាព្រះអង្គឲ្យនិមន្តទៅ-



**នគរសាវត្ថី** គហបតីត្រឡប់ទៅវិញក៏ធ្វើ **ជេតវនវិហារ** ទុកថ្វាយ ។



គ្រានោះព្រះសាស្តា យាងចេញចាក នគរកបិលវត្ថុ ទៅកាន់នគរសាវត្ថី កាលដែលព្រះអង្គគង់ ក្នុងជេតពនវិហារ ព្រះនន្ទកើតអផ្សុកចង់សឹក ព្រះអង្គបានជ្រាប ក៏លួងលោមឲ្យព្រះនន្ទ ប្រព្រឹត្តព្រហ្មចរិយធម៌ ហើយនឹងជានាឲ្យស្រីអប្សរ ។

# ព្រះអង្គនាំព្រះនន្ទទៅទស្សនាឋានសួគ៌



ព្រះនន្ទត្ថេរ ខំប្រព្រឹត្តិព្រហ្មចរិយធម៌ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត ទើបទៅដោះប្តេជ្ញា និងព្រះសាស្តា ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកជនបទ ទ្រង់គង់នៅក្នុង **អនុបិយម្ពវ័ន** ជិតស្រុក **អនុបិយ** ។ គ្រានោះ រាជត្រកូល ដែលបានប្តេជ្ញាថា នឹងថ្វាយព្រះរាជបុត្រ ១ អង្គ ៗ ជាបរិវារនោះ បានចេញទ្រង់បព្វជ្ជាតាមជាច្រើន ។

# (ក្សត្រ ៦ អង្គចេញសាងបព្វជ្ជា)



ចំណែកក្សត្រ ៦ ព្រះអង្គគឺ **ភទ្ទិយ ១ អនុរុទ្ធ ១ ភគុ ១ កិម្ពិល ១អានន្ទ ១ ទេវទត្ត ១** ទ្រង់មិនទាន់ចេញបព្វជ្ជានៅឡើយ ទើបសក្យទាំងពួងពោលថា "យើងរាល់គ្នា ឲ្យកូនទៅបួសអស់ ហើយឯក្សត្រ ៦ ព្រះអង្គនេះ មិនមែនជា ព្រះញាតិទេដឹង បានជាមិនទៅបួស" ។

លុះដាប់នោះ មហានាមសក្យ ជាបុត្ររបស់ព្រះ-**អមិតោទន:** មានព្រះបន្ទូល និង ព្រះ**អនុរុទ្ធ** ជាព្រះអនុជថា "ខ្លួនអ្នកក្តី ខ្លួនខ្ញុំក្តី គួរតែទៅបួស" ។ ព្រះអនុរុទ្ធតបទៅថា ទូលបង្គំពុំទៅទេ មហានាមថា បើអ្នកមិនទៅបួសគួររៀនធ្វើការងារចុះ , ខ្ញុំនឹងទៅបួសអនុរុទ្ធ សួរ

រឿងការងារ ។ មហានាម ក៏សម្តែងប្រាប់ ការងារទាំងពួង មានកសិកម្ម ជាដើម.. អនុរុទ្ធឃើញថា លំបាកណាស់ ។

ព្រះអនុរុទ្ធនេះ ជាក្សត្រប្រកបដោយ **សុខុមាលជាតិ** ពុំដែលស្គាល់លំបាក, សូម្បីតែពាក្យថា គ្មានក៏ពុំដែល ឮ ផង, បានជាមានរឿងតមកថា ថ្ងៃមួយក្សត្រទាំង ៦ ព្រះអង្គ ទ្រង់ក្រសាលអង្គាញ់ ជាមួយគ្នាភ្នាល់ដាក់នំថា " បើអ្នកណាចាញ់ ត្រូវយកនំមកសង " ។ អនុរុទ្ធចេះតែចាញ់ រាល់គ្នា ក៏បញ្ជូនមនុស្សឲ្យទៅយកនំ ពីព្រះមាតាដរាប ដល់ ព្រះមាតាប្រាប់ថា នំគ្មានទេ ។

កាលអ្នកបម្រើ ទៅក្រាបទូល តាមសេចក្តីនោះ ព្រះអនុរុទ្ធ ក៏ប្រើឲ្យទៅយកនំគ្មាននោះ មកព្រោះពាក្យថា គ្មាន ព្រះអនុរុទ្ធមិនដែលឮ ។ មាតាក៏ឲ្យយកភាជន៍ទទេមកថ្វាយ ទេវតាលបដាក់នំទិព្វ ក្នុងភាជន៍នោះ ។ អ្នកបម្រើនាំយកទៅ ស្រាប់តែឃើញនំ មានក្លិនប្លែក ក្សត្រទាំង ៦ អង្គ ក៏នាំគ្នាសោយ ។ ព្រះអនុរុទ្ធសួរព្រះមាតាថា ហេតុអ្វីក៏ពីដើមមក ទ្រង់ពុំរាជប្រទាននំគ្មាន ដល់ទូលព្រះបង្គំ ? តាំងពីថ្ងៃនេះទៅ ទូលបង្គំមិនទទួលព្រះរាជទាននំដទៃទេ ។ ព្រះមាតាទ្រង់ ព្រះសណ្តាប់ ហើយក៏សួរអ្នកបម្រើ ។ អ្នកបម្រើក្រាបទូលថា ភាជន៍ដែល

យកពីទីនេះ ទៅជាភាជន៍ទទេ លុះដល់ទៅទីក្រសាល អង្គុញ ក៏ស្រាប់តែឃើញនំពេញភាជន៍នោះ ។ ព្រះមាតា ទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ព្រះចិន្ដាថា កូនអញបិតនៅ ជាយរាវាសដរាបណា ទេវតាក៏នឹងដាក់នំទិព្វ ឲ្យដរាប នោះមិនខាន ” ។ ថ្ងៃមួយខាងក្រោយមក ក្សត្រទាំង ៣ ព្រះអង្គ សួរគ្នាថា ភោជនាហារកើតក្នុងទីឯណា ? ចំណែក **កិម្ពិល** ឆ្លើយថា ភោជនាហារកើតក្នុងជង្រុក , **ភទ្ទិយ** ឆ្លើយ ថា កើតក្នុងឆ្នាំង ព្រោះឃើញគេ ដួសបាយអំពីឆ្នាំង ។ **អនុរុទ្ធ** ឆ្លើយថា “ កើតក្នុងភាជន៍ ” លុះដល់គ្រាខាងក្រោយ ទើបជ្រាបថា“កើតពីស្រែ” ក៏មានសេចក្ដីនឿយណាយ ក្នុង ឃរាវាស ទើបបបួលគ្នាទាំង ៦ អង្គ សោយសម្បត្តិអស់ ៧ ថ្ងៃ ហើយក៏ចេញចាក **នគរកបិលវត្ថុ** ទៅជាមួយ និង បរិវារ , លុះដល់ទីបំផុតដែន ក៏ឲ្យបរិវារត្រឡប់មកវិញ ។

ក្សត្រទាំង ៦ អង្គ និង **ឧបាលិកប្បកៈ** ទៅដល់ដែន **មល្លរដ្ឋ** ក៏ដោះគ្រឿងអម្ពរឲ្យ**ឧបាលិកប្បកៈ** យកទៅលក់ ចិញ្ចឹមជីវិត ហើយយាងទៅ ។ ឧបាលិកប្បកៈទទួលបង្វេច ដើរមកគិតថា ***ធម្មតាសក្យរាជ កាចណាស់ កាលឃើញ អញ បានគ្រឿងអម្ពរ មុខជាគិតថា ឧបាលិកប្បកៈនេះ សម្លាប់រាជឱរស យកគ្រឿងអាភរណៈ ហើយនឹងធ្វើ រាជទណ្ឌ ដល់អញពុំខាន*** ។ ឧបាលិគិតដូច្នោះហើយ

ក៏យក បង្វេចព្យួរលើមែកឈើ ហើយទៅតាមក្សត្រទាំង ៦ អង្គ វិញ ។ ក្សត្រទាំង ៦ អង្គ ឃើញ**ឧបាលិ** មកដល់ ក៏សួរ សព្វគ្រប់ប្រការ, កាលបើឧបាលិ ក្រាបទូលតាមដំណើរហើយ, ក៏នាំគ្នាទៅកាន់សំណាក់ ព្រះសាស្តា ហើយទូលសូមព្រះអង្គ ឲ្យបំបួស **ឧបាលិកប្បក** ជាមុន ហើយទើបបំបួសក្សត្រ ៦ អង្គ ជាខាងក្រោយ ។ ចំណែក ***ភទ្ទិយ*** បានសម្រេចវិជ្ជា ៣ ក្នុងវស្សា នោះ ព្រះ***អនុរុទ្ធ*** បានសម្រេចទិព្វចក្ខុញ្ញាណ , គ្រាក្រោយកាលព្រះសាស្តា ទេសនា ***មហាបុរិសវិតក្កសូត្រ*** ក៏បានសម្រេចអរហត្តផល ***ព្រះអានន្ទ*** បានសម្រេចសោតាបត្តិផល ។ ***ព្រះភគុ*** និង ***កម្ពិល*** ចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត***ព្រះទេវទត្ត*** បានឫទ្ធិជាបុថុជ្ជន ។



លំដាប់នោះ ព្រះពុទ្ធជាម្ចាស់ ទ្រង់យាងទៅកាន់ **នគរកោសម្ពី** មហាជននាំគ្រឿងសក្ការៈទៅថ្វាយ ក៏សួររក ត្រឹមតែព្រះសាស្តា និងអសីតិសាវ័ក ត្រង់ទេវទត្តឥតមាន នរណាសួររកសោះ ។ ទេវទត្តអន់ចិត្ត ក៏ស្វែងរកពួកបាន ហើយព្យាយាម ធ្វើកម្មអាក្រក់ដរាបដល់ព្រះធរណីស្រូប យកទៅក្នុងនរក ។



( ចប់សក្យបព្វជ្ជាបរិច្ឆេទទី២០ )

✵✵✵✵✵

# ( មេត្តេយ្យព្យាករណបរិច្ឆេទទី២១ )

ក្នុងកាលពុទ្ធុប្បាទ នៃព្រះសព្វញ្ញុពុទ្ធជាម្ចាស់ នៃយើងនេះ***ព្រះមេត្តេយ្យបរមពោធិសត្វ*** មកកើតក្នុងផ្ទៃ នៃព្រះនាង***កញ្ចនាទេវី*** ជាអគ្គមហេសីនៃ***ព្រះបាទអជាតសត្រូ*** ។

លុះដល់គ្រប់មួយទសមាសកាលណា ក៏ប្រសូតចាកឧទរព្រះមាតាបាននាមថា " ***អជិតកុមារ*** " មានវ័យចំរើនដោយលំដាប់មក ទើបមានព្រះរាជហឫទ័យជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ។

## ព្រះអជិតឧបសម្បទានិងបរិវារ១ពាន់រូប



អជិតកុមារ បានឃើញព្រះពុទ្ធដ៏មានសិរី, បានស្តាប់ទេសនាក៏គិតថា " បុគ្គលដែលមិនបានឲ្យទាន រក្សាសីលជាដើម មិនអាចត្រាស់ដឹងសព្វញ្ញុតញ្ញាណ បានឡើយ " ទើបទ្រង់ទៅលា ព្រះបិតាសាងបព្វជ្ជា បានឧបសម្បទាមួយអន្លើដោយពួកបរិវារ ១ ពាន់ ហើយបានរៀននូវព្រះពុទ្ធវចនៈ ចេះចាំច្រើន បង្ហាត់បង្រៀនព្រះត្រៃបិដកដល់ភិក្ខុជាច្រើន ។

## ព្រះនាងមហាបជាបតិគោតមីប្រគេនសំពត់ព្រះសាស្តា



ក្នុងកាលដែល ព្រះសាស្តា ទ្រង់ត្រឡប់មកកាន់នគរ-**កបិលវត្ថុ** ក្នុងលើកទី ២ ទ្រង់គង់នៅ ក្នុងវត្តនិគ្រោធារាម, ព្រះនាង **បជាបតិគោតមី** ទ្រង់ព្រះចិន្តាថា អត្មាអញគ្មាន

វត្ថុអ្វី ? ថ្វាយចំពោះព្រះពុទ្ធជាម្ចាស់ទេ គួរតែអញ នឹងថ្វាយចីវរ , បើនឹងទិញសំពត់ មានតម្លៃច្រើន ក៏ពេញជាគួរហើយ , តែបើអត្មាអញ ត្បាញសំពត់ដោយដៃខ្លួនវិញ ទើបប្រសើរជាង " ហើយព្រះនាង ឲ្យដាំងធ្វើផើងមាស ៧ យកមកដាក់ដី ដាំគ្រាប់កប្បាស ស្រោចដោយទឹកដោះគោ, លុះដល់កប្បាសដុសឡើង មានផ្កាផ្លែព្រះនាងក៏បេះដោយព្រះហស្ត ព្រះនាងយកមកធ្វើជាសំឡីរវៃជាអំបោះ ដរាបដល់ត្បាញ ជាសំពត់ពីរផ្ទាំងមួយផ្ទាំង ៗ បណ្តោយ **១៤ ហត្ថ** ទទឹង **៥ ហត្ថ** ដូចគ្នាទាំងពីរផ្ទាំង ទើបនាងបត់សាដកនោះ ដាក់ក្នុងប្រអប់មាស ព្រមទាំងសំពត់ដទៃផង ហើយឲ្យស្រីបរិវារ កាន់ដើរតាមក្រោយ ទៅកាន់ **និគ្រោធារាម** ដល់ហើយថ្វាយបង្គំប្រកបដោយ **បញ្ចង្គប្រតិស្ឋាន** (ថ្វាយបង្គំប្រកបដោយអង្គប្រាំ ) ទៀបបាទាព្រះសម្ពុទ្ធ ព្រះនាងលើកសំពត់ថ្វាយក្រាបទូល តាមដំណើរ ដើម្បីឲ្យព្រះអង្គទទួលអនុគ្រោះដល់ព្រះនាង ។ ព្រះសាស្តាទ្រង់ព្រះ**សវនាការ** (ស្តាប់) ហើយតបថា " បពិត្រព្រះនាងបជាបតិគោតមី ចូលព្រះនាងថ្វាយសំពត់នេះ ដល់សង្ឃ នឹងមានផលច្រើន " ។ ព្រះនាងបជាបតិគោតមី អង្វរអស់វារៈ ២ ដង, ៣ ដង ក៏ព្រះ

សាស្តា នៅតែបង្គាប់ឲ្យថ្វាយដល់សង្ឃ ។ ចំណែកពុទ្ធាធិប្បាយ ដែលឲ្យនាងថ្វាយ ដល់សង្ឃដូច្នោះ ព្រោះព្រះអង្គប្រាថ្នា ដើម្បីសម្តែងគុណព្រះសង្ឃ ដែលមានជាតំណាមកខាងក្រោយ ព្រះនាងបជាបតិគោតមី តូចព្រះរាជហឫទ័យ ក៏ទៅរកព្រះអានន្ទឲ្យជួយអង្វរ ។ ព្រះអង្គក៏នៅតែមិនព្រមទទួល ទើបទ្រង់សម្តែង***បាដិបុគ្គលិកទាន*** និង ***សង្ឃទាន*** ។

ព្រះនាងទ្រង់ព្រះសណ្តាប់ ធម៌ទេសនា មានសេចក្តីជ្រះថ្លា ទើបលើកសំពត់ថ្វាយ ដល់ព្រះសង្ឃតម្កល់ទុកទៀប ទីជិតព្រះសារីបុត្រ ។ ព្រះសារីបុត្ត ក៏មិនព្រមទទួលព្រះនាងយក ទៅប្រគេនព្រះថេរ ជាលំដាប់ ៗ មិនមានអង្គណាមួយទទួលឡើយ ។ នាងនាំទៅតម្កល់ទុកក្នុងទីជិត ***អជិតភិក្ខុ*** ទើបបួសថ្មី គង់ចុងអាសនៈបំផុត ។ អជិតភិក្ខុ ទើបទទួលយកសំពត់នោះ ព្រះនាងក៏កើត សេចក្តីទោមនស្ស ព្រះសាស្តាជ្រាបហើយ ទ្រង់ឲ្យព្រះអានន្ទយកបាត្រមកថ្វាយ កាលព្រះអានន្ទ នាំបាត្រមក ទ្រង់អធិដ្ឋានថា សាវ័កទាំងពួង កុំឲ្យបានបាត្រនេះ សូមឲ្យអជិតភិក្ខុបានបាត្រនេះចុះ ទើបព្រះអង្គ បោះបាត្រទៅក្នុងអាកាស ។ ព្រះសារីបុត្តទូលថា ខ្ញុំព្រះអង្គហ្នឹងទៅរកបាត្រមកថ្វាយ,

ព្រះអង្គក៏អនុញ្ញាត ឲ្យព្រះថេរៈទៅរក មិនឃើញ ព្រះថេរៈទាំងអស់ទៅរក ក៏មិនឃើញទៀត ។ លំដាប់នោះ ព្រះអង្គទ្រង់ ត្រាស់បង្គាប់ឲ្យ **អជិតភិក្ខុ** ទៅរកបាត្រ, ព្រះអជិតក៏គិតថា ព្រះថេរៈទាំងពួង ប្រកបដោយឫទ្ធិ ក៏រកបាត្រមិនឃើញ , អាត្មាអញជាបុថុជ្ជនក៏មិនអាច នឹងរកឃើញឡើយ គិតហើយក៏ទទួលថា " ខ្ញុំព្រះអង្គ នឹងរកបាត្រ ក្នុងវេលានេះ " ។

ខណៈនោះ ទើបព្រះអជិតភិក្ខុ រមិលមើលអាកាស ហើយអធិដ្ឋានថា អាត្មាអញបួស មិនប្រាថ្នាលាភ , ប្រាថ្នាតែ ប្រព្រឹត្តិព្រហ្មចរិយធម៌ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង និង ចម្លងសត្វលោក សូមឲ្យបាត្រព្រះអង្គមកឋិតនៅ ក្នុងដៃយើងដោយឆាប់ ។ គ្រានោះ បាត្រ ក៏ធ្លាក់ចាកអាកាសមកប្រតិស្ឋាន លើព្រះហស្ត អជិតភិក្ខុ ដោយហេតុជាអស្ចារ្យ ព្រះមាតុច្ឆាឃើញ ហើយមាន ព្រះរាជហឫទ័យ សោមនស្ស ថ្វាយបង្គំចូលទៅកាន់និវេសន៍វិញ ។ ព្រះសាស្ដាក៏សម្ដែងបុព្វហេតុទាំងពួង នៃអជិតភិក្ខុ ហើយទ្រង់ព្យាករណ៍ ***អជិតភិក្ខុ*** នេះ ហ្នឹងបានត្រាស់ជា ព្រះពុទ្ធមួយអង្គនាមថា ***ព្រះអរិយមេត្តេយ្យ*** ។

*( ចប់មេត្តេយ្យព្យាករណ៍បរិច្ឆេទទី២១ )*

✵✵✵✵✵

# (ពុទ្ធបិតានិព្វានបរិច្ឆេទទី២២)

លំដាប់នោះ ព្រះដ៏មានព្រះភាគ ចេញចាកវត្ត **និគ្រោធារាម** ទៅកាន់ **រាជគហនគរ** គង់នៅក្នុងវេឡុវនវិហារ មួយអន្លើដោយភិក្ខុសង្ឃ គង់ចាំវស្សា ជាគម្រប់ ៤ ដរាបដល់អស់វស្សា លុះដល់វស្សាជាគម្រប់ ៤ ព្រះអង្គទ្រង់យាងទៅគង់ ក្នុង**កូដាគារសាលានាមហាវ័ន** ក្នុង**នគរវេសាលី** ដើម្បីអនុគ្រោះដល់ **វេនេយ្យសត្វ** ។

## *ព្រះបាទសិរីសុទ្ធោទនៈទ្រង់ប្រឈួនធ្ងន់*



គ្រានោះ ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ប្រឈួនធ្ងន់ សក្យរាជទាំងពួង មានព្រះនាងបជាបតិគោតមី ជាដើម ខំរក្សាព្រះរោគនោះ ក៏មិនអាចឲ្យរម្ងាប់ទៅបាន ។ ព្រះពុទ្ធ

បិតា ក៏ផ្ទំបម្រះននៀល លើព្រះសយនា ទ្រង់រលឹកដល់ព្រះសាស្តាហើយ មានបរិវិតក្កថា បើព្រះសាស្តា យាងមកស្ទាបព្រះសិរសា, ព្រះអានន្ទមកស្ទាបសិរីរកាយ គឺផ្ទឹងជំនីរសងខាង , ព្រះរាហុមកបរាមាស **ព្រះបិដ្ឋិ**កាយឯណាទុក្ខវេទនារោគាអាពាធ នៃអាត្មាអញ ក៏រម្ងាប់ទៅក្នុងកាលនោះ ។ ក្នុងបច្ចូសម័យថ្ងៃនោះ ព្រះសាស្តាទ្រង់រមិលមើលនូវឧបនិស្ស័យ វេនេយ្យសត្វ បានជ្រាបថា ព្រះពុទ្ធបិតាទ្រង់ប្រឈួន ទ្រង់បរិវិតក្កថាកាលនេះគួរតថាគតទៅប្រោសព្រះបិតាដែលកំពុង នឹកដល់តថាគត ទើបព្រះអង្គ ហៅព្រះអានន្ទមក ប្រាប់ហេតុគ្រប់ប្រការ ហើយបង្គាប់អានន្ទឲ្យប្រាប់ភិក្ខុទាំងពួង ។ អានន្ទទទួលព្រះពុទ្ធដីការ កាលបើភិក្ខុសង្ឃមកដល់ ព្រះអង្គប្រាប់ហេតុស្រេចហើយ ទ្រង់នាំភិក្ខុសង្ឃ ៥០០ អង្គ ទៅកាន់នគរកបិលភ័ស្តុ តាមអាកាសដល់ហើយ ទ្រង់យាងចូលទៅកាន់ព្រះរាជមន្ទីរ ទតឃើញព្រះវរាជបិតា មានព្រះកាយទុព្វលភាព ក៏ត្រាស់សួរព្រះរោគ ។ ព្រះពុទ្ធបិតាកាលទ្រង់ព្រះសណ្តាប់ ព្រះពុទ្ធដីកា ហើយក៏ស្រក់ព្រះនេត្រទូលថា ទុក្ខវេទនា នៃខ្ញុំករុណាមានកម្លាំងណាស់ ស្មើរនឹងដាច់ជីវិត ។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់ហើយ ក៏លើកព្រះហស្តស្តាំ ធ្វើសត្យាធិដ្ឋាន

ថា "តថាគតខំបំពេញ **អភិនីហារ** សាងបារមីអស់ ៤ អសង្ខេយ្យ និង មួយសែនកប្បនេះ ដើម្បីប្រយោជន៍សត្វលោក " ទើបព្រះអង្គទ្រង់**បរាមាស**(១) ព្រះសិរព្រះបិតា ដោយព្រះហស្តខាងស្តាំ ។ ទុក្ខវេទនាព្រះសិរៈ ក៏វិនាសបាត់ទៅ ។ លំដាប់នោះ ព្រះអានន្ទថ្វាយបង្គំ ព្រះសម្មាសម្ពុទ្ធ ហើយលើកព្រះហស្ត ខាងស្តាំ ស្ទាបព្រះហស្ត ព្រះរាជាខាងស្តាំ ។ ទុក្ខវេទនាក៏វិនាសទៅ, លំដាប់នោះ ព្រះអានន្ទ តាំងសត្យាធិដ្ឋាន ហើយលើកព្រះហស្តបរាមាស ព្រះហស្តព្រះរាជា ខាងឆ្វេងទៀត ។ ព្រះរោគក៏វិនាសទៅព្រះរាហុល ធ្វើសត្យាធិដ្ឋាន ហើយស្ទាប់ ព្រះបិដ្ឋិព្រះរាជអយ្យកោ ដោយព្រះហស្តខាងស្តាំ ក្នុងកាលនោះ ព្រះពុទ្ធបិតា មានព្រះរោគាពាធ ប្រាស់ទៅហើយ ស្តេចក្រោកចាកសិរីសយនា មានបីតិសោមនស្ស លើកព្រះហស្តធ្វើអញ្ជលី ចំពោះព្រះសាស្តា ។ សម្តេចព្រះភគវា ទ្រង់ពិចារណាអាយុសង្ខារ នៃពុទ្ធបិតាក៏ជ្រាបថា នៅតែ៧ថ្ងៃទៀតទ្រង់ នឹងយាងទិវង្គត ។

ព្រះរាជា ក៏អារាធនាឲ្យព្រះអង្គសម្តែងធម៌ ព្រះសាស្តាទ្រង់សម្តែង ***អនិច្ចតាទិបដិសំយុត្ត*** គឺ ព្រះត្រៃលក្ខណ៍ លុះចប់កាលណា ព្រះពុទ្ធបិតា បានសម្រេចអរហត្តផល ។

***១.បរមាសៈ*** *ស្ទាប, អង្អែ*

# ព្រះបាទសិរីសុទ្ធោទនៈទ្រង់បរិនិព្វាន



ដល់ថ្ងៃជាគម្រប់ ៧ ថ្ងៃ ព្រះពុទ្ធបិតា ក្រាបទូលព្រះសាស្តាថា អាយុសង្ខារ ខ្ញុំព្រះអង្គនេះ តិចណាស់ ខ្ញុំព្រះអង្គ សូមថ្វាយបង្គំលា ព្រះសាស្តាបរិនិព្វានហើយ សូមទ្រង់អនុញ្ញាត ។ ចំណែកខត្តិយវង្ស បានទ្រង់ព្រះសណ្តាប់ហើយ បរិទេវនាការទួញយំ ។ ព្រះបិតាសូមស្មាលាទោស និង ព្រះសាស្តា ស្រេចហើយ ក៏បរិនិព្វានក្នុងកាលនោះ ។

ព្រះមុនិន្ទពិនលោកនាថ ទ្រង់សម្តែងធម៌ បន្ទោបង់សេចក្តីសោក នៃពួកសក្យរាជទាំងឡាយ ហើយមាន

ព្រះពុទ្ធដីកា បង្គាប់ព្រះមហាកស្សបត្ថេរ ឲ្យមើលទីបូជាព្រះភ្លើង, ព្រះមហាកស្សបត្ថេរ ក៏ទទួលតាមព្រះពុទ្ធដីកា ។ ក្នុងកាលនោះ ពពួកទេវតា ក្នុងម៉ឺនលោកធាតុ មកប្រជុំគ្នាកាល ***ព្រះមហាកស្សបត្ថេរ*** បង្គាប់ឲ្យតាក់តែង ជើងថ្កល់ស្រេចហើយ ក៏ទៅក្រាបទូលព្រះបរមគ្រូ ។ ព្រះសាស្តាទ្រង់លើកព្រះសិរសា ព្រះពុទ្ធបិតា ដោយព្រះហស្ត ទ្រង់ស្រោចដោយ ***សុគន្ធវារី*** ( ទឹកក្រអូប ) ស្រេចហើយលើកព្រះបរមសព ដាក់ក្នុងមឈូសរតន៍, ទើបព្រះសាស្តាលើកមឈូស ដោយព្រះអង្គឯង នាំទៅកាន់ទីបូជា, ព្រះអង្គទ្រង់ឃាត់សក្កទេវរាជ មិនឲ្យថ្វាយព្រះភ្លើងមុន ,ទ្រង់ថ្វាយព្រះភ្លើង ដោយព្រះអង្គឯង ។ ឯព្រះញាតិព្រះសាស្តាទាំង ៦ នគរ គឺ ***នគរកបិលវត្ថុ ១ ទេវទហៈ ១ កោលិយ ១ សក្ករ ១ សុប្បវាសា ១ វេរនគរ ១*** ក៏សោកសៅបរិវេទនាការ ក្នុងគ្រាដែល ព្រះពុទ្ធបិតា ទ្រង់ចូលនិព្វានទើបបបួលគ្នា មកប្រជុំព្រមក្នុងនគរកបិលវត្ថុ ទាំងអស់ដើម្បីថ្វាយភត្តាហារ ដល់ព្រះសាស្តា និងភិក្ខុសង្ឃ ។ ព្រះសព្វញ្ញូ ទ្រង់ទទួលភត្តស្រេចហើយ ទ្រង់ធ្វើអនុមោទនាសម្តែងធម៌ ប្រោសព្រះញាតិហើយ ទ្រង់យាងទៅគង់ក្នុង ***និគ្រោធារាម*** ។

# ព្រះនាងបជាបតិគោតមីសូមបព្វជ្ជា



គ្រានោះ ព្រះនាងបជាបតិគោតមី ទៅសូមបព្វជ្ជា ព្រះអង្គមិនអនុញ្ញាត ទើបព្រះអង្គយាងទៅគង់ក្នុង**កូដាគារសាលា** ។ លំដាប់នោះ ព្រះនាងបជាបតិគោតមី តាមទៅសូម បព្វជ្ជាទៀតមិន ព្រះនាងក៏បាននិមន្តឲ្យ ព្រះអានន្ទ ជួយអង្វរព្រះអង្គ ៗ ក៏នៅតែមិនអនុញ្ញាត, គ្រានោះ ព្រះសាស្តា ទ្រង់យាងទៅគង់ក្នុងនគរសាវត្ថី ។ ព្រះនាងបជាបតិគោតមី ក៏នាំខត្តិយកញ្ញា ៥០០ អង្គ ជាបរិវារ តាមទៅសូមបព្វជ្ជា ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់ករុណា ក៏ប្រទានបព្វជ្ជា និង ឧបសម្បទា ដោយ**គរុធម៌ ៨ ប្រការ** ។

## (ចប់ពុទ្ធបិតានិព្វានបរិច្ឆេទទី២២)

# ( បរិនិព្វានបរិច្ឆេទទី២៣ )

## ( ពុទ្ធាធិវាសនដ្ឋាន )

*សម្តេចព្រះភគវន្តអនន្តញ្ញាណ* តាំងពីទ្រង់បានត្រាស់ ជាព្រះពុទ្ធស្រេចមក ទ្រង់ត្រាច់ប្រកាសសាសនាព្រហ្មចរិយៈ ដឹកនាំវេនេយ្យជន ជាច្រើនតំបន់ ឲ្យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តាមលំអាននោះ ។ ទីឋានដែលព្រះអង្គធ្លាប់ គង់ប្រកាសធម្មវិន័យនោះ មាន ១៨ កន្លែងគឺៈ

-វស្សាទី ១ព្រះអង្គទ្រង់គង់ចាំវស្សានៅទី ***ព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី*** ។

-វស្សាទី ២ ទី ៣ ទី ៤ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុង ***វត្តវេឡុវនារាមជិតក្រុងរាជគ្រឹះ***

-វស្សាទី៥ ទ្រង់គង់ចាំវស្សាក្នុង ***កូដាគារសាលាព្រៃមហាវ័នជិតក្រុងវេសាលី*** ។

-វស្សាទី ៦ ព្រះអង្គ ទ្រង់គង់ចាំវស្សាលើ ***មកុឡបព៌តក្នុងដែនមគធៈ*** ។

## ចុងវស្សាទី ៦ ព្រះអង្គទ្រង់សម្ដែងយមកបដិហារិយ៍



- វស្សាទី ៧ ព្រះអង្គ ទ្រង់ឡើងទៅគង់ចាំវស្សា ក្នុងឋានតាវត្តឹង្សលើ ***ថ្មបណ្ឌុកម្ពលសិលាអាសនៈ*** ត្រាស់ប្រទាន ***ព្រះសត្តប្បករណាអភិធម្ម៧គម្ពីរ*** ប្រោសពុទ្ធមាតា ។

## ព្រះអង្គប្រោសពុទ្ធមាតា





ព្រះអង្គយាងចុះចាកឋានតាវត្តឹង្សក្នុងថ្ងៃ ១៥កើត ខែអស្សុជ



-វស្សាទី៨ ព្រះអង្គ ទ្រង់គង់ចាំវស្សាក្នុង***ភេសកលាវ័នក្នុង ភគ្គរាជជនបទ*** ។

-វស្សាទី៩ ព្រះអង្គ ទ្រង់គង់ចាំវស្សាក្នុង***ព្រៃបាលិលេយ្យកៈ***



-វស្សាទី១០ និងទី ១១ ព្រះអង្គ ទ្រង់គង់ចាំវស្សាក្នុងដងព្រៃជិតស្រុកព្រាហ្មណ៍ឈ្មោះ ***សាលេយ្យកគ្រាម*** ។

-វស្សាទី ១២ ព្រះអង្គ ទ្រង់គង់ចាំវស្សានៅក្រោមដើមស្តៅ ដែល***នឡេរុយក្សរក្សា*** ។

-វស្សាទី១៣ ព្រះអង្គ ទ្រង់គង់ចាំវស្សានៅ ***ភ្នំបាលិលេយ្យកបព៌ត*** ។

-វស្សាទី ១៤ ព្រះអង្គ ទ្រង់គង់ចាំវស្សាក្នុង***ជេតវនារាមមហាវិហារ ជិតក្រុងសាវត្ថី***។

-វស្សាទី១៥ ព្រះអង្គ ទ្រង់គង់ចាំវស្សាក្នុង***វត្តនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ*** ដើម្បីប្រោសពួកព្រះញាតិ។

-វស្សាទី១៦ ព្រះអង្គ ទ្រង់ គង់ចាំវស្សា ក្នុងដែន***អាឡវី*** ដើម្បីប្រោស ***អាឡវកយក្ស*** ។

-វស្សាទី ១៧ ទី ១៨ ទី ១៩ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុង***វេឡុវនារាម*** ជិត ***ក្រុងរាជគ្រឹះ*** ។

-វស្សាទី ២០ ដល់ ២៩ ព្រះអង្គ ទ្រង់គង់ចាំវស្សាក្នុង***វត្តជេតពននាមហាវិហារ ជិតក្រុងសាវត្ថី*** ។

-វស្សាទី ៣០ ដល់វស្សាទី ៣៥ ព្រះអង្គគង់ចាំវស្សាក្នុង***វត្តបុព្វារាម***។

-វស្សាទី ៣៦ ដល់វស្សាទី ៤៤ ព្រះទ្រង់គង់ចាំវស្សាក្នុង***វត្តជេតពនមហាវិហារ ជិតក្រុងសាវត្ថី*** ។

-វស្សាទី៤៥ ព្រះអង្គទ្រង់គង់ចាំវស្សាក្នុង***ស្រុកវេឡុវគ្រាម***រួមទីកន្លែង ដែលព្រះអង្គធ្លាប់គង់ ត្រូវជា ១៨ កន្លែង រួមវស្សាទាំងអស់ មានចំនួន **៤៥ ព្រះវស្សា** ។ ក្នុងរវាង ៤៥ វស្សានេះ ព្រះអង្គទ្រង់បំពេញ ***ពុទ្ធកិច្ចទាំង ៥ ប្រការ***

ជាកិច្ច ដែលព្រះពុទ្ធទាំងឡាយ តែងធ្វើក្នុងការប្រកាសសាសនាគឺ:

**បុព្វណ្ហេ បិណ្ឌបាតញ្ច** ក្នុងពេលព្រឹក ទ្រង់ត្រាច់ទៅដើម្បីបិណ្ឌបាត ១

**សាយណ្ហេ ធម្មទេសនំ** ក្នុងពេលរសៀល ទ្រង់សម្តែងធម្មទេសនា ដល់ពុទ្ធបរិស័ទាំងឡាយ១

**បទោសេ ភិក្ខុឱវាទំ** ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទ ចំពោះពួកភិក្ខុទាំងឡាយ ១

**អឌ្ឍរត្តេ ទេវបញ្ហានំ** ក្នុងវេលាកណ្តាលអធ្រាត្រ ទ្រង់ដោះស្រាយប្រស្នា នៃពួកទេវតា ១

**បច្ចូសេ វ គតេ កាលេ ភព្វាភព្វេ វិលោកនំ** ដល់វេលាបែកបច្ចូស ទ្រង់ប្រមើលមើលនូវសត្វ ដែល**មានភព្វ និង ឥតភព្វ** ១ ។ បើទ្រង់ឃើញសត្វណា មានភព្វហើយជា ***ពុទ្ធវេនេយ្យ*** នោះព្រះអង្គ ទ្រង់និមន្តទៅប្រោស ដោយព្រះអង្គឯង បើសត្វណាជា ***សាវកវេនេយ្យ*** មាននិស្ស័យត្រូវសាវកអង្គណា ប្រោសបាននោះ ព្រះទ្រង់ញាណទ្រង់ចាត់សាវកអង្គនោះ ឲ្យទៅប្រោស ។

ព្រះដ៏មានព្រះភាគ ជាម្ចាស់ ទ្រង់ប្រព្រឹត្តធ្វើពុទ្ធកិច្ចទាំង ៥ ប្រការនេះអស់ ៤៥ វស្សា ។ ដល់ចេញវស្សាទី ៤៥

ព្រះអង្គ ទ្រង់និមន្តចេញអំពីស្រុក **វេឡុវៈ** ត្រាច់ទៅកាន់ចារិក តាមលំដាប់ ដល់ថ្ងៃ**ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់បញ្ចស័ក** ព្រះអង្គគង់នៅ **បាវាលចេតិយ** ព្រះជិនស្រីទ្រង់ដាក់អាយុសង្ខារដោយ ព្រះពុទ្ធដីកាចំពោះមារថា "**ម្នាលមារមានចិត្តបាប អ្នកចូរមាន សេចក្ដីខ្វល់ខ្វាយតិចចុះ កាលបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង បី ខែ អំពីថ្ងៃនេះទៅ តថាគត នឹងបរិនិព្វានហើយ**"

លុះព្រះដ៏មានព្រះភាគ ទ្រង់ដាក់អាយុសង្ខារ ដូច្នេះហើយ ក៏កក្រើកផែនដីយ៉ាងធំ គួរឲ្យភ្លូក ភ្លឹក ព្រឺព្រួចរោមទាំងផ្គរក៏លាន់ ឮ ឡើង ។



ពួកសាវ័កទាំងឡាយ មានព្រះអានន្ទជាដើម ក៏កើតសង្វេគ សោយសោកជាទុក្ខ ក្ដុកក្ដួលគ្រប់ៗ គ្នា ។

# ព្រះអង្គទ្រង់ក្រឡេកមើលក្រុងវេសាលី



តមកសម្តេចព្រះភគវា ទ្រង់ចូលទៅបិណ្ឌបាត ក្នុង **ក្រុងវេសាលី** ត្រឡប់ពីបិណ្ឌបាត ទ្រង់ក្រឡេកទតក្រុង-**វេសាលី** ហើយមាន**ព្រះពុទ្ធដីកា** និង ព្រះអានន្ទថា " ម្នាលអានន្ទ តថាគតឃើញក្រុងវេសាលីម្តងនេះ ជាទីបំផុតហើយ " ហើយធ្វើពុទ្ធដំណើរ ទៅដល់**ភណ្ឌគ្រាម** ទ្រង់ត្រាច់ទៅចារិក តាមលំដាប់ដរាបដល់ **នគរភុសិនារា**

ទ្រង់ចូលទៅកាន់សាលវ័ន របស់មលក្សត្រ ដែលជាទីចូលទៅ ក្នុង**ក្រុងកុសិនារា** ទ្រង់ត្រាស់ និង ព្រះអានន្ទ ថា " ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែ ឲ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះ **សាលព្រឹក្សទាំងគូ** ឲ្យតថាគតផាប់ " ព្រះអានន្ទក៏ទទួល ធ្វើតាមព្រះពុទ្ធដីកា ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះ**សតិសម្បជញ្ញៈ** ទ្រង់សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្តាំយកព្រះបាទឆ្វេង តម្រួតលើព្រះបាទស្តាំ ។

ក្នុងគ្រាដែល ព្រះបរមសម្ពុទ្ធ ទ្រង់ផ្ទំលើ**អនុដ្ឋានសយនា** ជាទីចូលបរិនិព្វាននេះ ព្រះមហាអានន្ទ បានក្រាបបង្គំសួរ នូវវត្តប្រតិបត្តិផ្សេង ៗ ជាច្រើនដែលត្រូវប្រព្រឹត្តធ្វើ ក្នុងកាលជា ខាងក្រោយមកទៀត ព្រះអានន្ទបានស្តាប់ ព្រះពុទ្ធតម្រាស់ត្រាស់ ប្រាប់គ្រប់ប្រការ ហើយចូលទៅកាន់វិហារ ឈរតោងត្រដោកទ្វារ យំរៀបរាប់ជាអនេកប្បការ ។

សម្តេចព្រះបរមសាស្តា ទ្រង់ឲ្យភិក្ខុទៅហៅ ព្រះអានន្ទមក ទ្រង់មានព្រះពុទ្ធដីកា សសើរគុណសម្បត្តិរបស់ព្រះអានន្ទ ដោយប្រការជាច្រើន ហើយទ្រង់ឲ្យ



ព្រះអានន្ទ ទៅថ្វាយដំណឹង ដល់ពួកមល្លក្សត្រ ។ ពួកមល្លក្សត្រ និង ព្រះរាជបុត្រ ព្រះរាជសុណិសា ព្រមទាំងព្រះជាយារបស់ មល្លក្សត្របានជ្រាប ហើយក៏កើតទុក្ខតូច ព្រះទ័យពោរពេញ ដោយសេចក្តី អាល័យ នាំគ្នាចូលទៅសាលវ័ន ដើម្បីឲ្យទាន់ ព្រះសាស្តាទាំងពពួកទេវតា ក៏ចូលមកណែនណាន់តាន់តាប់ ។ ដល់បច្ឆិមយាម សម្តេចព្រះជិនស្រី ទ្រង់ត្រាស់ និងភិក្ខុទាំងឡាយថា **ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ** ដូច្នេះហើយទ្រង់ចូល-កាន់បឋមជ្ឈាន ,ចេញចាកបឋមជ្ឈាន ចូលកាន់ទុតិយជ្ឈាន, តតិយជ្ឈាន, ចតុត្ថជ្ឈាន, អាកាសានញ្ចាយតនសមាបត្តិ, វិញ្ញាណញ្ចាយតនសមាបត្តិ , អាកិញ្ចញ្ញាយតនសមាបត្តិ

,នេវសញ្ញាយតនសមាត្តិ, សញ្ញាវេទយិតនិរោធ, ទ្រង់ចេញចាក សញ្ញាវេទយិតនិរោធ ថយមកកាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ជាបដិលោមប្រាសរហូតដល់បឋមជ្ឈាន ទើបចូលជាអនុលោម បណ្តោយដល់ត្រឹមចតុត្ថជ្ឈាន ហើយក៏ទ្រង់បរិនិព្វាន ក្នុងចន្លោះនោះព្រះសម្មាសម្ពុទ្ធ ទ្រង់បរិនិព្វានៅថ្ងៃអង្គារ ១៥ កើត ខែ ពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ។

## ព្រះអង្គបរិនិព្វាន



ពុទ្ធបរិស័ទទាំងឡាយ មានពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ជាប្រធានបានចាត់ចែង ដើម្បីបូជាព្រះសរីរៈព្រះដ៏មានព្រះភាគ មនុស្សព្រមទាំងទេវតា ធ្វើសក្ការបូជាដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបអស់វេលា ៧ ថ្ងៃ, ដល់ថ្ងៃជាគម្រប់ ៧ ក៏រំកិលព្រះសរីរៈដើម្បីហែចេញទៅទិសខាងត្បូង ហើយនឹងបូជាខាងត្បូងព្រះរាជវាំង គ្រានោះ ក៏រំកិលព្រះសរីរៈ ពុំកម្រើកសោះ ។ មល្លក្សត្រ ៨ ព្រះអង្គ ដែលជាប្រធាន បានទទួលសួរព្រះអនុរុទ្ធ ៗ ថ្វាយព្រះពរថា ព្រោះតែខុសនឹងបំណងទេវតា ” ទើបព្រមព្រៀងគ្នា រំកិលព្រះបរមសរីរៈ ដង្ហែចេញទៅទិសខាងជើង ហើយចូលទៅ កាន់ក្រុងតាមទ្វារខាងជើង កាត់ពាក់កណ្តាលក្រុង ចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើង ព្រះបរមសរីរៈ ព្រះដ៏មានព្រះភាគក្នុង **មកុដពន្ធនចេតិយ** របស់ពួកមល្លក្សត្រដ៏ខាងកើតទីក្រុង ។

ក្នុងកាលដែល ពួកមល្លក្សត្រថ្វាយ ព្រះភ្លើងព្រះមហាកស្សបៈ កំពុងនិមន្តមកពី**ដែនបាវា** ពុំទាន់បានមកដល់នៅឡើយ ភ្លើងក៏ពុំឆេះ ។ លុះព្រះមហាកស្សបៈនិមន្តមកដល់ ព្រះបាទាទាំងគូ នៃព្រះទសពល ក៏លៀន

ចេញពីមឈូសមាស ។ ព្រះមហាកស្សប និង ភិក្ខុទាំង ៥០០ ជាបរិវារ ថ្វាយបង្គំព្រះបាទា រួចស្រេចជើងថ្កល់ក៏ឆេះឯង ។ ព្រះសរីររបស់ព្រះដ៏មានព្រះភាគ សុសអស់គ្មានកំញម ដូចជាប្រេង ដែលភ្លើងឆេះ នៅសល់តែព្រះអដ្ឋិធាតុសុទ្ធ ។ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ដែលមាន ពួកអ្នកកាន់លំពែង ពួកទាហានដំរី ទាហានសេះ ទាហានរថ និង ពួកយោធា គ្រប់តំណែងចោមរោមជាបរិវារ បានរើសព្រះអដ្ឋិធាតុ ទៅធ្វើសក្ការបូជា ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រង និងគ្រឿងក្រអូប



ទាំងឡាយអស់ ៧ ថ្ងៃទៀត ក្នុងសណ្ឋាគារ ។ គ្រានោះ ព្រះបាទមាគធរាជ **អជាតសត្តុវេទេហិបុត្ត** ព្រះចៅក្រុងរាជគ្រឹះ , ពួកក្សត្រ***លិច្ឆវី*** អ្នកក្រុងវេសាលី, ពួកក្សត្រសក្យ អ្នក ***ក្រុងកបិលវត្ថុ***, ***ពួកក្សត្រថូលិ*** អ្នក***ក្រុងអល្លកប្ប*** , ***ពួកក្សត្រកោឡិយៈ*** អ្នក***ក្រុងរាមគ្រាម***,ព្រាហ្មណ៍ដែលនៅក្នុង***ដែនវេដ្ឋទីបៈ*** និង***ពួកក្សត្រអ្នកក្រុងបាវា*** បានឮដំណឹងថាព្រះដ៏មានព្រះភាគ-

# ពិធីចែកព្រះសារីរិកធាតុ



ទ្រង់បរិនិព្វានហើយ ក្នុង***ក្រុងកុសិនារា*** ក៏បញ្ជូនទូតមក ដើម្បីសុំចែកព្រះសារីរិកធាតុ ។ ពួកមល្លក្សត្រ ពុំព្រមចែកឲ្យ

ក៏ជជែកគ្នា ស្ទើរតែនឹងកើតសង្គ្រាមមួយ ក្នុងរឿងនេះ ។ ទើប **ទោណព្រាហ្មណ៍** និយាយឡើងថា "គួរតែស្រុសស្រួលព្រមព្រៀងនិយាយរកគ្នា" ហើយចែកព្រះសារីរិកធាតុឲ្យជា ៨ ចំណែកស្មើគ្នា, ឯទោណព្រាហ្មណ៍ ជាអាចារ្យដែលជាមេចំណែក បានត្រឹមតែ**តុម្ព** មួយ គឺ ជារង្វាល់ដែលវាល់ព្រះធាតុនោះប៉ុណ្ណោះ ។

ឯពួក**ក្សត្រមោរិយៈ** អ្នក**ក្រុងបិប្ផលិវ័ន** ក៏បញ្ជូនទូតទៅដើម្បីសុំចែកព្រះសារីរិកធាតុដែរ ។ ពួកមល្លក្សត្រថា ព្រះសារីរិកធាតុ យើងចែកគ្នាអស់ទៅហើយ, ចូរអ្នកទាំងឡាយនាំយក**ព្រះអង្គារ** (ធ្យូង) អំពីកន្លែង ដែលថ្វាយព្រះភ្លើងនេះទៅ ។ **ពួកក្សត្រមោរិយៈ** ទាំងនោះ ក៏នាំយកព្រះអង្គារអំពីកន្លែង ដែលថ្វាយព្រះភ្លើងនោះទៅ ។

គ្រានោះ ព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត ក៏ធ្វើព្រះស្តូប ធ្វើការបូជាព្រះសារីរិកធាតុ ព្រះដ៏មានព្រះភាគក្នុងក្រុងរាជគ្រឹះ , ពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលីធ្វើក្នុងក្រុងវេសាលី ។ ពួកក្សត្រសក្យ អ្នកក្រុងកបិលវត្ថុធ្វើក្នុងក្រុងកបិលវត្ថុ , ពួកក្សត្រថូលិអ្នកក្រុងអល្លកប្បៈ ធ្វើក្នុងក្រុងអល្លកប្បៈ ។ ពួកក្សត្រកោឡិយៈ អ្នករាមគ្រាមធ្វើក្នុងរាមគ្រាម ព្រាហ្មណ៍អ្នកវេដ្ឋទីបៈ ធ្វើក្នុងដែន

វេដ្ឋទីបៈ ។ ពួកមល្លក្សត្រ អ្នកក្រុងបាវា ធ្វើក្នុងក្រុងបាវា, ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ធ្វើក្នុងក្រុងកុសិនារា ។ ទោណព្រាហ្មណ៍ ក៏ធ្វើក្នុងក្រុងកុសិនារាដែរ ។ ពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ធ្វើក្នុងក្រុងបិប្ផលិវ័ន ។ រួមព្រះស្តូបតម្កល់ព្រះសារីរិកធាតុ ទាំងអស់មាន ៨ ជាគម្រប់ ៩ និង ស្តូប ដែលតម្កល់ព្រះតុម្ព ជាគម្រប់ ១០ និង ព្រះស្តូបដែលតម្កល់ព្រះអង្គារ ។

**( ព្រះបរមធាតុត្រូវបានបែងចែកជា១៦នាឡិ )**

១-ព្រះបាទអជាសត្តុ បាននាំទៅកាន់ក្រុងរាជគ្រឹះចំនួន ២ នាឡិ ។

២-ពួកក្សត្រលិច្ឆវី បាននាំទៅកាន់ក្រុងវេសាលីចំនួន ២ នាឡិ ។

៣-ពួកក្សត្រក្រុងកបិលវត្ថុ បាននាំទៅចំនួន ២ នាឡិ

៤-ពួកក្សត្រថូលិ បាននាំទៅកាន់ក្រុងអល្លកប្បចំនួន ២ នាឡិ ។

៥-ពួកក្សត្រកោឡិយ បាននាំទៅកាន់រាមគ្រាមចំនួន ២ នាឡិ ។

៦-ព្រាហ្មណ៍វេដ្ឋទីបកៈ បាននាំទៅកាន់ដែនវេដ្ឋទីបកៈ ចំនួន ២ នាឡិ ។

៧-ពួកមល្លក្សត្រ បាននាំទៅកាន់ក្រុងបាវាចំនួន ២ នាឡិ ។

៨-ពួកមល្លក្សត្រ បាននាំទៅកាន់ក្រុងកុសិនារាចំនួន ២ នាឡិ ។

## ( ព្រះធាតុទាំងអស់មាន ៣ ខ្នាត )

១-ខ្នាតធំ ប៉ុនគ្រាប់សណ្តែកបាយ ពណ៌មាសមានចំនួន ៥ នាឡិ ។

២-ខ្នាតកណ្តាល ប៉ុនគ្រាប់អង្ករបាក់ ពណ៌កែវមុក្តាមានចំនួន ៥ នាឡិ ។

៣-ខ្នាតតូច ប៉ុនគ្រប់ស្ពៃ ពណ៌ផ្កាម្លិះក្រពុំមានចំនួន ៦ នាឡិ ។

## ( ព្រះធាតុដែលមិនបែកមាន ៧ )

☞ ***ឆ្អឹងថ្ងាស ១ ឆ្អឹងដងកាំបិត ២ ចង្កូមកែវ ៤ គឺ:***

១-ព្រះចង្កូមកែវស្តាំខាងលើ នៅឋានតាវត្តឹង្ស

២-ព្រះចង្កូមកែវស្តាំខាងក្រោម នៅប្រទេសសិរីលង្កា

៣-ព្រះចង្កូមកែវឆ្វេងខាងលើ នៅប្រទេសចិន

៤-ព្រះចង្កូមកែវឆ្វេងខាងក្រោម នៅពិភពនាគ

៥-ឆ្អឹងដងកាំបិតស្តាំ នៅប្រទេសសិរីលង្កា

៦-ធ្មេញកំពិតខ្វេង នៅព្រហ្មលោក

៧-ធ្មេញថ្វាស នៅប្រទេសសិរីលង្ការ ខ្លះថានៅទុស្សចេតិយនាព្រហ្មលោក ។

៨-ព្រះទន្ត(ធ្មេញ) ដ៏សេសសក់ និងរោម ទេវតានាំទៅកាន់ចក្រវាឡនីមួយ ៗ ។

ព្រះធាតុសរុបទាំងអស់មានចំនួន ៨ ទោណៈ ១ ទោណៈ ត្រូវជា ១៦ នាឡិតូច ។ ព្រះធាតុទាំងអស់ស្មើ និង ២៥៦ នាឡិតូច ។ (បិដកលេខ ១៦ / ៣៤៩)

## (ចប់បរិនិព្វានបរិច្ឆេទទី២៣)

# ចប់ពុទ្ធប្បវត្តិកថាសង្ខេប

# ពុទ្ធប្រវត្តិសង្ខេប

*******

១.**ព្រះអង្គបដិសន្ធិ:** *ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអាសាឍ ឆ្នាំរកា វេលាជិតភ្លឺ*

២.**ព្រះអង្គប្រសូត:** *ថ្ងៃសុក្រ ១៥ កើត ខែវិសាខ ឆ្នាំចរ វេលាថ្ងៃជិតត្រង់ ក្នុង**ឧទ្យានលុម្ពិនី** ព្រមទាំងមានហេតុអស្ចារ្យគឺ:*

*១.មានទឹកក្តៅ ទឹកត្រជាក់ហូរធ្លាក់ ពីអាកាសមកលាង មន្ទិលថ្វាយ*

*២.សទ្ធាវាសមហាព្រហ្ម ៤ រូប កាន់បណ្តាញមាសមក ទទួលព្រះបរមពោធិសត្វ*

*៣.មហារាជទាំង ៤ រូប ទទួលព្រះអង្គ*

*៤.ស្រីស្នំទទួលពីមហារាជទាំង ៤*

*៥.មហាព្រហ្មយកស្វេតច្ឆ័ត្រ មកបាំងថ្វាយសុយាម ទេវរាជយកវាលវិជនីមកបក់ថ្វាយ, ទេវបុត្រ ១ អង្គ កាន់កែវ ៧ ប្រការ និងសុវណ្ណបាទុកា, ទេវបុត្រ ១ អង្គទៀត កាន់គ្រឿងសម្រាប់រាជ្យមាន ៥ ប្រការ គឺ: មកុដ ១ ព្រះខ័ន ១ ស្វេតច្ឆ័ត្រ ១ សុវណ្ណបាទុកា ១ វាលវិជនី ១ ។*

# ៣.សហជាតិវត្ថុ ៧ ប្រការគឺ:

១.ព្រះនាងពិម្ពា ២.ព្រះអានន្ទ ,

៣.ឆន្នអាមាត្យ ៤.កាឡុទាយីអាមាត្យ

៥.សេះកណ្ឋកៈ ៦.ដើមពោធិព្រឹក្ស,

៧.កំណប់ទ្រព្យទាំង ៤ គឺ:

- កំណប់ទ្រព្យមួយឈ្មោះ **សង្ខនិធិ** មានសំណុំមាត់ មូលជុំវិញ ១ គាវុត ។

-កំណប់ទ្រព្យមួយឈ្មោះ **ឯលនិធិ** មានសំណុំមាត់ មូលជុំវិញ កន្លះយោជន៍ ។

-កំណប់ទ្រព្យមួយឈ្មោះ **ឧបលនិធិ** មានសំណុំមាត់ មូលជុំវិញ ៣ គាវុត ។

-កំណប់ទ្រព្យមួយឈ្មោះ **បុណ្ឌរិកនិធិ** មានសំណុំមាត មូលជុំវិញ ១ យោជន៍ ជម្រៅរហូតដល់ទីបំផុតនៃ ផែនដីដូចគ្នាទាំង ៤ ។

ក្នុងកាលនោះ ពួកខត្តិយទាំងពីនគរ ក៏កើតបីតិ សោមនស្ស ហើយយាងព្រះមហាបុរស ព្រមទាំង**ព្រះមាតា**

ត្រឡប់ចូលទៅ ក្នុងក្រុងកបិលវត្ថុវិញ ។

៤.ត្រេកពេជ:ថ្ងៃអាទិត្យ ១៥ កើត ខែ អាសាឍ ឆ្នាំ ឆ្លូវ ក្នុង ជន្មាយុ ១៦ វស្សា

៥.បួស: ក្នុងជន្មាយុ ២៩ វស្សា ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែ អាសាឍ ឆ្នាំ ថោះ វេលាអាធ្រាត្រ ។

៦.ត្រាស់ដឹង: ថ្ងៃពុធ ១៥ កើត ខែវិសាខ ឆ្នាំរកា ក្នុងជន្មាយុ ៣៥ វស្សា ក្នុងឧរុវេលាសេនានិគមន៍ ជិត**ស្ទឹងនេរញ្ជរា** វេលាជិតភ្លឺ លើរតនបល្ល័ង្កមានកំពស់ ១៤ ហត្ថ(៧ម) ក្រោមដើមពោធិ៍មានកម្ពស់ ៥០ហត្ថ (២៥ម)។

៧.ចតុរង្គសន្និបាត: *(វិ.មហា.១/១/៣៤៥.៣៤៦)*

១. ១៥ កើត ខែមាឃ

២.ភិក្ខុ ១២៥០ រូប មកប្រជុំគ្នា មិនបានណាត់គ្នាជាមុន

៣.ភិក្ខុដែលមកប្រជុំគ្នា សុទ្ធតែជាព្រះខីណាស្រព

៤.ភិក្ខុទាំងអស់ សុទ្ធតែជា ឯហិភិក្ខុសម្បទា ។

៨.ជាត់ជន្មាយុ: ថ្ងៃ ១៥ កើត ខែ មាឃ ឆ្នាំម្សាញ់

(បិដក ១៦/២២៥)

៩.បរិនិព្វាន: ថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់

(បិដក ១៦/៣២៥)

១០.ព្រះសារិកាធាតុ: ព្រះធាតុបែកមាន ១៦ នាឡិ បាន នាំទៅកាន់នគររបស់ខ្លួនគឺ:

១-ព្រះបាទអជាសត្តុ បាននាំទៅកាន់ក្រុងរាជគ្រឹះ ចំនួន ២ នាឡិ

២-ពួកក្សត្រលិច្ឆវី បាននាំទៅកាន់ក្រុងវេសាលី ចំនួន ២ នាឡិ

៣-ពួកក្សត្រក្រុងកបិលវត្ថុ បាននាំទៅចំនួន ២ នាឡិ

៤-ពួកក្សត្រថូលិ បាននាំទៅកាន់ ក្រុងអល្លកប្បៈ ចំនួន ២ នាឡិ

៥-ពួកក្សត្រកោឡិយ បាននាំទៅកាន់រាមគ្រាម ចំនួន ២ នាឡិ

៦-ព្រាហ្មណ៍វេដ្ឋទីបក បាននាំទៅកាន់ ដែនវេដ្ឋទីបក ចំនួន២ នាឡិ

៧-ពួកមល្លក្សត្រ បាននាំទៅកាន់ ក្រុងបាវាចំនួន ២ នាឡិ

៨-ពួកមល្លក្សត្រ បាននាំទៅកាន់ ក្រុងកុសិនារា ចំនួន២ នាឡិ ។ (បិដក ១៦/៣២៧ )

## ព្រះធាតុទាំងអស់មាន ៣ ខ្នាតគឺៈ

១-ខ្នាតធំប៉ុន គ្រាប់សណ្តែកបាយ ពណ៌មាសមាន ចំនួន ៥ នាឡិ

២-ខ្នាតកណ្តាលប៉ុនគ្រាប់អង្ករបាក់ ពណ៌កែវមុក្តាមាន ចំនួន ៥ នាឡិ

៣-ខ្នាតតូចប៉ុនគ្រាប់ស្ពៃ ពណ៌ផ្កាម្លិះ ក្រពុំមានចំនួន ៦ នាឡិ

## .ព្រះធាតុដែលមិនបែកមាន ៧ គឺៈ

☞ **ឆ្អឹងថ្ងាស ១ ឆ្អឹងដងកាំបិត ២ ចង្កូមកែវ ៤ គឺ**

១-ព្រះចង្កូមកែវស្តាំខាងលើ នៅឋានតាវត្តឹង្ស

២-ព្រះចង្កូមកែវស្តាំខាងក្រោម នៅប្រទេសសិរីលង្កា

៣-ព្រះចង្កូមកែវឆ្វេងខាងលើ នៅប្រទេសចិន

៤-ព្រះចង្កូមកែវធ្មេញខាងក្រោម នៅពិភពនាគ

៥-ឆ្អឹងដងកាំបិតស្តាំ នៅប្រទេសសិរីលង្កា

៦-ឆ្អឹងដងកាំបិតឆ្វេងនៅ ព្រហ្មលោក

៧-ឆ្អឹងថ្ងាសនៅប្រទេសសិរីលង្កា ខ្លះថានៅទុស្ស

ចេតិយនាព្រហ្មលោក

៨-ព្រះទន្ត(ធ្មេញ) ដ៏សេសសក់ និងរោមទេវតានាំទៅ

កាន់ចក្រវាឡនីមួយៗ ។

☞ព្រះធាតុសរុបទាំងអស់ចំនួន៨ទោណៈ=២៥៦នាឡិតូច ។

(បិដក ១៦/៣៥០)

# ( ចប់ពុទ្ធប្រវត្តិសង្ខេប )

# ពុទ្ធប្រវត្តិ

-អហំវីខ្ញុំសូមថ្លែងរៀបរាប់ ពុទ្ធប្បវត្តិសង្ខេបខ្លី ៗ
ស្រួលងាយសិក្សាដោយប្រពៃ ដូចមានសេចក្ដីតទៅនេះ ។
-ពួកយើងអ្នកកាន់ពុទ្ធសាសនា ត្រូវតែសិក្សាឲ្យចេះស្ទាត់
នូវរឿងព្រះពុទ្ធដែលជាម្ចាស់ គ្រប់គ្នាត្រូវដឹងឲ្យបានច្បាស់ ។
-ទ្រង់ចុះកាន់គភ៌នៃមាតា អាសាឍមាសាថ្ងៃព្រហស្បតិ៍
ក្នុងឆ្នាំរកាយ៉ាងច្បងច្បាស់ ព្រមដោយនិមិត្តប្រាជកហោង។
-រីឯប្រសូតនៅថ្ងៃសុក្រ ចរពិសាខពិតដើមរដូវ
នៅក្នុងឧទ្យានាជងផ្លូវ ទេវតាមនុស្សទៅជុំត្រៀបត្រា ។
-ព្រះអង្គអភិសេកថ្ងៃអាទិត្យ សោយរាជ្យកក្តិកនាឆ្នាំឆ្លូវ
សុខក្នុងប្រាសាទគ្រប់រដូវ គង់នៅជំក្សេម និង មហេសី ។
-ទ្រង់សាងបព្វជ្ជាថ្ងៃព្រហស្បតិ៍ ចេញចាកឱរសក្នុងរាត្រី
ជាមួយអាមាត្យ និង អាជនេយ្យ ឆ្លងនគរបីដើម្បីបព្វជ្ជា ។
-ត្រាស់ដឹងនៅក្នុងឆ្នាំរកា ថ្ងៃពុធពិសាខប្រាកដជាក់
ព្រះអង្គចាកផុះនូវសច្ចៈ អស់នូវអាសាវៈកិលេសហោង។
-បូណ៌មីអាសាឍសំដែងធម្មចក្ក ប្រោសបញ្ចវគ្គីយ៍ព្រៃមិគទាយី
ទេវតាព្រហ្មផងជួបជុំមូលមី ចូលគាល់ព្រះមុនីស្ដាប់ទេសនា។
-ព្រះបរិនិព្វានថ្ងៃអង្គារ បរិស័ទគ្រប់គ្នាកើតសោកា
ពិសាខឆ្នាំម្សាញ់ព្រះសាស្ដា ទ្រង់យាងយាត្រាចូលនិព្វាន ។
-និព្វានព្រះពុទ្ធនូវព្រះធម៌ ឱវាទបវរជាព្រះសាស្ដា
ទូន្មានប្រដៅរពល់សត្តា ឆ្លងវដ្តសង្សារដល់និព្វានហោង។

# ទង់ព្រះពុទ្ធសាសនា

-ទង់ពុទ្ធសាសនាមានប្រាំមួយពណ៌ ខៀវលឿងក្រហមស ហង្សបាទផង
ធព្វណ្ណរង្សីភ្លឺល្អមង្គម៉ង ស្រស់ល្អផូរផង់ឥតមានខ្ចោះ ។

-ពណ៌ខៀវតំណាងការជឿជាក់ ពីរលឿងខ្ចីនេះតំណាងសន្តិភាព
បីពណ៌ក្រហមឆ្អៅមិនរមៀត ពណ៌នេះជាក់តាងបញ្ញាបារមី ។

-ពណ៌សតំណាងភាពបរិសុទ្ធ ប្រាំហង្សបាទពិតជាគ្មានតណ្ហា
ប្រាំមួយពណ៌ផ្ទេកចម្រុះភ្លឺថ្លា ពណ៌នេះអស្ចារ្យតាងគុណទាំងអស់ ។

-ទង់ពុទ្ធសាសនាមានពណ៌ ៦ ជំនួយឲ្យចិត្តបរិស័ទជ្រះថ្លា
ទង់បក់រវិច រំលេចអស្ចារ្យ ហាក់ដូចសាស្តាបញ្ចេញរស្មី ។

-ហេតុនេះយើងកាន់ពុទ្ធសាសនា ត្រូវតែជ្រះថ្លាឲ្យក្រៃលែងនៃ
ឲ្យទានភាវនាសីល ៥ ប្រាំបី ប្រតិបត្តិយប់ថ្ងៃកុំបីឃ្លាងឃ្លាត ។

-ព្រះធម៌វិន័យថ្ងៃថ្លាអស្ចារ្យ ឱវាទសាស្តាទ្រង់ត្រាស់ទូន្មាន
អានុសាសនីនៃព្រះទ្រង់ញាណ ត្រូវប្រឹងសូត្ររៀនស្តាប់កុំខ្ជិល ។

-សិក្សាប្រតិបត្តិតាមច្បាប់ឱវាទ រស់នៅមិនខាតពិតមានតម្លៃ
ពិតរួចផុតទុក្ខផុតភពត្រៃ ដល់និព្វាននៃប្រព្រៃពេកហោង ។

***ភិក្ខុបិតប្បញ្ញោ*** *គង់សុភាព*

# ពុទ្ធប្បវត្តិកថាសង្ខេប

## នាមអ្នកត្រីមុខដែលមានឧបការៈក្នុងការទទួលឧបត្ថម្ភបោះពុម្ព

| | |
|---|---|
| ព្រះតេជគុណសិទ្ធិ ប៉ោ | (វត្តប្រាសាទត្រាំនាគ) |
| ភិក្ខុខេមភិរតោ ស៊ាន ជាសែន | (វត្តប្រាសាទត្រាំនាគ) |
| ភិក្ខុអគ្គញ្ញាណោ មុត សំបូរ | (វត្តពោធិ៍លង្ការ៍) |
| ភិក្ខុមតិវរោ ឃឹម សាមុត | (វត្តស្រះឈូក.ប.ម.ជ.) |
| លោកម្ចាស់ ផល្លី | (វត្តព្រះដាក់) |
| ភិក្ខុ ឃន ខន | (វត្តកោះទឹមសទ្ធា .ប.ប.) |
| ឧបាសិកា អ៊ុំ ឈីវ ហ៊ុន | ឧបាសិកា សោម ផាន |
| ឧបាសិកា សំរិទ្ធិ ថូ | ឧបាសក ម៉ម ហ៊ិត |
| ឧបាសក ឃុត សេង | ឧបាសក រស ជា |
| ឧបាសិកា សូ វីឡា | ឧបាសិកា កែវ លាត |
| ឧបាសិកា លឹម ចន្ថនៈ | ឧបាសិកា ឱម សារ៉ូន (រលួស) |
| ឧបាសិកា ទីវ សារុន | ឧបាសិកា ឈឹម ឡាង (កំពុងក្តី) |
| ឧបាសិកា ពឹង វណ្ណា (កំពុងក្តី) | ឧបាសិកា ស៊ិន គឹមសាត |
| ឧបាសិកា គង់ ពៅ (ខ្នាចាស់) | ឧបាសិកា ម៉យ |
| ឧបាសក វ៉ាន់ វុន (ស្រុកស្មោង) | ឧបាសិកា ញ៉ែម រដ្ឋា |
| ឧបាសក ភួង ផែន (ស្វាយធំ) | ឧបាសិកា លឹម សារឹម |
| ឧបាសិកា វណ្ណ ភាព | ឧបាសិកា សូត្រ គឹម សាយ |
| ឧបាសក វ៉េន ហម (ស្វាយធំ) | ឧបាសិកា តាំង គឹមព្រម(ដំដែក) |

ស្ថានីយវិទ្យុផ្សាយសំឡេងព្រះពុទ្ធសាសនាកម្ពុជៈរដ្ឋ FM 106.25 MHz

## នាមសប្បុរសជនឧបត្ថម្ភបោះពុម្ពសៀវភៅ

| | |
|---|---|
| ភិក្ខុខេមភិរតោ ស៊ាន ជាសែន | ២០ ក្បាល |
| ភិក្ខុរស បុណ្ណា គង់ គឹមលូត | ១០ក្បាល |
| ឧបាសិកា ហោ ម៉ារី ព្រមទាំងបុត្រ និងចៅ | ៥០០ដុល្លារ |
| ឧបាសិកា គី ហ៊ួយ ព្រមទាំងបុត្រ និងចៅ | ៣០០ដុល្លារ |
| តាមរយៈឧបាសក វ៉ាន់ វ៉ូន ( ស្រុកស្មោង) | ៣០០០រៀល ២៨០ដុល្លារ |
| លោកម្ចាស់ ឃន ខន ពុទ្ធបរិស័ទវត្តកោះទឹមសទ្ធា | ២៥០ដុល្លារ |
| លោក តោ ហុង និងឧ.ស.លីវ គឹម អេង ព្រមទាំងបុត្រ(៥០ក) | ២០០ ដុល្លារ |
| ព្រហ្មបញ្ញោ អង្គគ្រូ ឡាយ ជឿន ឧបាសិកា ទ្រស៊ុ រើន កូនចៅ | ២០០ដុល្លារ |
| ឧបាសិកា ភឿន យ៉ាន | ១០០ដុល្លារ |
| ឯកឧត្តម គង់ ប៊ុនលី និងលោកជំទាវ ធិម គឹមលីព្រមទាំងបុត្រ | ១០០ដុល្លារ |
| ឧបាសិកា អ៊ុំ ឈីវហ៊ុន ព្រមទាំងបុត្រ | ១០០ដុល្លារ |
| ឧបាសិកា អ៊ែ ចន្ទូ និងស្វាមី ព្រមទាំងបុត្រ | ១០០ដុល្លារ |
| ឧបាសិកា វ៉ាន់ វី | ១០០ដុល្លារ |
| ឧបាសិកាអាំង កែវ រឿម | ១០០ដុល្លារ |
| ឧបាសក រស ជា និងភរិយាព្រមទាំងបុត្រ | ១០០ ដុល្លារ |
| លោកស្រីលី អ៊ុំស៊ន់ និងស្វាមីព្រមទាំងបុត្រ(ហាងប៉ៃលិន បោកអ៊ុត) | ១០០ដុល្លារ |
| ទាយក ជឹម សំអុល និងឧបាសិកា ទ្រីសោ ភ័ណ | ១០០ដុល្លារ |
| ឧបាសិកា វ៉ាន់រី (លក់ផ្លែឈើ) | ១០០ដុល្លារ |
| ឧបាសករស់ ជា និងឧបាសិកា អ៊ុកសុខ ព្រមទាំងបុត្រ | ១០០ដុល្លារ |
| ឧបាសិកា សំ រិទ្ធថូ ព្រមទាំង បុត្រ | ៧០ដុល្លារ |
| ឧបាសិកា សូរី ឡា និងញាតិមិត្តធម៌ កូនចៅ | ១៣៥០០០៛ + ៦០ ដុល្លារ |
| ឧបាសិកា ទីវ សារុន | ៥០ ដុល្លារ |
| ឧបាសិកា ស៊ុន គឹម សាត ព្រមទាំងបុត្រ និង ចៅ | ៥០ ដុល្លារ |
| ឧបាសិកា ដូពីរ ផង់ ចុល | ៥០ ដុល្លារ |
| ឧបាសិកា ផូពី | ៥០ ដុល្លារ |
| ឧបាសិកា ឈិង ឡាង | ៥០០០៛ + ៥០ ដុល្លារ |
| លោក ជា វណ្ណៈ និងឧបាសិកា ជ គឹមនីវ | ៥០ ដុល្លារ |

***ភិក្ខុបិតប្បញ្ញោ*** *គង់សុភាព ថ្ងៃ១៥កើត ខែ ស្រាពណ៍ ឆ្នាំម្សាញ់ បញ្ចស័ក . ព.ស. ២៥៥៧*

# ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ឧបសិកា គឹម កូយ និងឧបាសក សេង ហូ បុត្រ | | ៥០ ដុល្លារ |
| លោក អ៊ាមជា និងឧបាសិកា ពឹង វណ្ណា | | ៥០០០០៛ + ៥០ ដុល្លារ |
| សមាគមន៍ធម្មទានដើម្បីព្រះពុទ្ធសាសនា | | ៥០ ដុល្លារ |
| ឧបាសិកា មាន ម៉ារី | | ៥០ ដុល្លារ |
| ឧបាសិកា សោម ផាន | | ៤០ ដុល្លារ |
| ឧបាសិកា សូត្រ គឹម សាយ | ព្រមទាំងបុត្រ | ៤០ ដុល្លារ |
| តាមរយៈឧបាសិកា អ៊ុំ ឈីវ ហ៊ុន | ៧៥០០០៛ | ៣៥ដុល្លារ |
| ឧបាសិកា គឹម ដាង | | ៣០ ដុល្លារ |
| លោក ឈឿង ជ និងភរិយា | ព្រមទាំងបុត្រ | ២៥ដុល្លារ |
| ឧបាសក ម៉ម ហ៊ត និងឧបាសិកា សូ ហុង | | ២៥ ដុល្លារ |
| ឧបាសក គូប៉ូ និង ឧបាសិកា តឹក អេងស៊ីម | | ២៥ ដុល្លារ |
| ឧបាសិកា នាយ សុជាតិ | ព្រមទាំងបុត្រ១១០០០៛+២០ ដុល្លារ | |
| ញោម តាំង លេង ស៊ីម | | ២០ ដុល្លារ |
| កុងលី គាន និងឧ.សិ.គី ហ៊ូ | | ២០ ដុល្លារ |
| ឧបាសិកា គង់ អឿម | | ២០ ដុល្លារ |
| ឧបាសិកា  មុំ ម៉ារី | ព្រមទាំងបុត្រ | ២០ ដុល្លា |
| ឧបាសិកា កែវ លាត និង ស្វាមី | | ២០ ដុល្លារ |
| អ្នកស្រី  គឹម សូ | ព្រមទាំងបុត្រ | ២០ដុល្លារ |
| ឧបាសិកា យស សារុំ | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧបាសក ឈុន ចិ និងឧបាសិកា ហែម ប៊ិច | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| លោក ឈ កុក ហ៊្សរ និងកូនចៅ លោក ឡោ ពរ៉េន | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧបាសក ទីវ ប៊ុន ស៊ាន និង ឧបាសិកា ម៉ម លុន | ព្រមទាំងបុត្រ | ២០ដុល្លារ |
| ឧបាសក លឹម សម្បត្តិ និងឧបាសិកា គីម ឡុង | ព្រមទាំងបុត្រ | ២០ដុល្លារ |
| ទាយក ឈ្មះ សុផល និង ឧបាសិកា ងួន ច័ន្ទ ឌី | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧបាសិកា គឹម ដាង | | ២០ ដុល្លារ |
| ឧបាសិកា លិម ចុងឈីវ | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧបាសិកា គាន ណន និង ឧបាសកឡៃ ស៊ុយ ហ៊ន | | ២០ ដុល្លារ |
| ឧបាសិកា គឹម ហាប និង ម៉ា ស៊ីវ | | ២០ ដុល្លារ |

# ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ឧបាសិកា ប៉ូ ចាន់ណា | | ២០ ដុល្លារ |
| ទាយក ឈុនថិ | | ២០ ដុល្លារ |
| ឧបាសក ស៊ីមរ៉ា និងឧបាសិកា គង់ ម៉ាស់ | | ២០ ដុល្លារ |
| ឧបាសិកា សរ អៀងចូ និង ស្វាមី | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| .ឧបាសក គង់ រឿន និងឧ.សិ ប៉ូ យុន | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧបាសិកា ជា ស្ងួន | ព្រមទាំងកូនចៅ | ២០ ដុល្លារ |
| ឧបាសិកា ស ម្លិះ | ព្រមទាំងកូនចៅ | ២០ ដុល្លារ |
| លោក ឈឿង ជ និងភរិយា | ព្រមទាំងបុត្រ | ២៥ ដុល្លារ |
| ឧបាសិកា សៀង លាង សេង | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧ.សិ អឿន ពេន និងឧ.សិ បានស្រី ឧ.ស ភេមភិមព្រមទាំងកូន | | ២០ ដុល្លារ |
| ឧបាសិកា ប៉េង មួយព្រមទាំងបុត្រ និងចៅ | | ៥០០០៛&២៥ ដុល្លារ |
| ឧបាសិកា សូរ៍ លា | និងកូនចៅ | ២០ ដុល្លារ |
| ឧបាសិកា ម៉ាលាន | | ២០ ដុល្លារ |
| ឧបាសិកា ទីវ លាន និងឧបាសិកា សៅ រិទ្ធ | | ២០ ដុល្លារ |
| ទាយិកា តាំង គីម ហេង និងស្វាមី | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ឧបាសិកា គឹម ណៃ ព្រមទាំងកូនចៅ | | ២០ ដុល្លារ |
| ឧបាសិកា គឹម ដាង | ព្រមទាំងបុត្រ | ២០ ដុល្លារ |
| ភិក្ខុ កង យ៉ុន | | ១៥ ដុល្លារ |
| លោក អ៊ុត ចន្ថា និងអ្នកស្រីផុន ឆៃរិត | ព្រមទាំងបុត្រ | ១៥ ដុល្លារ |
| ឧបាសិកា ដួង អ៊ាន | | ១៥ ដុល្លារ |
| ញោម កែវ សុផល | | ១៥ ដុល្លារ |
| ឧបាសិកា គង់ អ៊ុន | ព្រមទាំងកូនចៅ | ១០ ដុល្លារ |
| ឧបាសិកា ហួត ផល | | ១០ ក្បាល |
| អ្នកស្រី គឹម វាសនា និង ស្វាមី | ព្រមទាំង បុត្រ | ១០ ដុល្លារ |
| ឧបាសិកា សុខ នាង | | ១០ ដុល្លារ |
| លោក លឹម អាក់ នឹង ភរិយា | ព្រមទាំងបុត្រ | ១០ដុល្លារ |
| ឧបាសិកា ហង គុងហោ និង កូនចៅ | | ១០ ដុល្លារ |
| ឧបាសិកា អាន វណ្ណនី និងឧបាសិកា ពៅគឹមសួ ព្រមទាំងនុត្រ | | ១០ ដុល្លារ |

# ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ទន់សម័យ ស រប៉ុនឆាយ | | ១០ ដុល្លារ |
| ឧបាសិកា ញាញ ម៉ាឡៃ និងឧបាសិកា អែម ផាន់ស៊ី | | ១០ ដុល្លារ |
| ឧបាសក វណ្ណ ឈន់ និងភរិយា | ព្រមទាំងកូនចៅ | ១០ ដុល្លារ |
| ឧបាសិកា ឡៅ ម៉េងហួត | | ១០ ដុល្លារ |
| ពុទ្ធរិស័ទដំដែកថ្មី | | ៩០០០០៛ & ១០ ដុល្លារ |
| ញោម ទីវ សុម៉ាលី និងស្វាមី | | ១០ ដុល្លារ |
| ឧបាសិកា ទីវ សុម៉ាលី និងស្វាមី | | ១០ ដុល្លារ |
| ឧបាសិកា សូត្រ សាយ | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| លោក ហេង តូហ៊ា | | ១០ ដុល្លារ |
| ឧបាសក សេង ផ្លង់ និងឧបាសិកា ជាគិមលាភ | | ១០ ដុល្លារ |
| យុវជន អ៊ឹង ឡៃហ៊ត់ | | ១០ ដុល្លារ |
| យុវតី អ៊ឹង ឡៃស៊ីម | | ១០ ដុល្លារ |
| កុមារា អ៊ឹង ឡៃម៉េង | | ១០ ដុល្លារ |
| ឧបាសក អ៊ឹង កុក ហេង និងឧបាសិកា គង់ | | ១០ ដុល្លារ |
| ឧបាសក រស់ សូរ និងឧបាសិកា សារ៉េត | | ១០ ដុល្លារ |
| ឧបាសិកា គឹម សូនី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| អ្នកស្រី គឹម សំណាង និង ស្វាមី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| អ្នកស្រី គឹម សានិត និង ស្វាមី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសក យី សារី និង ភរិយា | | ១០ ដុល្លារ |
| ឧបាសិកា សុខ គិន និងស្វាមី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា អ៊ឹង ឆប | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា យន់ស្រី ម៉ៃ | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ដួង អ៊ាន | | ១០ ដុល្លារ |
| ទាយិកា ស្រ៊ី និងស្វាមី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ជ្រុន នាង | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសក ហោ និងឧបាសិកា វើន | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ហ៊ឹម គិម ព | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ខ្យង ប៉ុណ | ព្រមទាំងបុត្រ | ១០ ដុល្លារ |

# ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ឧបាសិកា មួង សុខុន | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ពេជ្រ សុផារី | | ១០ ដុល្លារ |
| ឧបាសិកា ស៊ិន លំអង | | ១០ ដុល្លារ |
| ឧបាសិកា ទាវ សម្បត្តិ និងស្វាមី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| លោក សង សុវឌ្ឍនា ស្រីសត វិជ្ជរី និង កូនប្រុស សួគ៌ | | ១០ ដុល្លារ |
| លោកម៉ម សុផន និង អ្នកស្រីសងសុធួន | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ញ៉ែម រដ្ឋា | | ១០ ដុល្លារ |
| ឧបាសិកា អ៊ិត សាឡាត់ | | ១០ ដុល្លារ |
| ឧបាសិកា យស សារុំ | | ១០ ដុល្លារ |
| ឧបាកសិកា នប គឹម ហ៊ួន | | ១០ ដុល្លារ |
| អ្នកស្រី លី អ៊ុំស៊ន់ | | ១០ ដុល្លារ |
| ឧបាសិកា ឡាយ ចាន់ ថារី | | ១០ ដុល្លារ |
| ឧបាសកប៊ូ សំបាន | | ១០ ដុល្លារ |
| ឧបាសិកា កែវ យ៉ុន | | ១០ ដុល្លារ |
| ភិក្ខុសិទ្ធិ ប៉ោ | | ១០ ដុល្លារ |
| ឧបាសិកា អ៊ុំ អ៊ី និង អ៊ុំអាំង | | ១០ ដុល្លារ |
| ឧបាសក យឿន ប៉ូ និងឧបាសិកា ជា ឈរ | | ១០ ដុល្លារ |
| ឧបាសិកា ស៊ិន សុផាត | | ១០ ដុល្លារ |
| ឧបាសិកា ឌង ឡុត | | ១០ ដុល្លារ |
| ឧបាសិកា ឡុញ វ៉ាន់ | | ១០ ដុល្លារ |
| ឧបាសក កែវ ឡាប | | ១០ ដុល្លារ |
| លោក សួន ដេរ និងអ្នកស្រី ចាន់ សាំ | | ១០ ដុល្លារ |
| ឧបាសក ណែម រស និងឧបាសិកា អ៊ុត អែម | | ១០ ដុល្លារ |
| លោកស្រី លី អ៊ុំ ស៊ន់ និងស្វាមី | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| សឹន ឧត្តម | | ១០ ដុល្លារ |
| ឧបាសិកា សរ ង៉ា និង ឧបាសិកា វិញ ពូន | | ១០ ដុល្លារ |
| លោក លី ឡុង់ ធី | | ១០ ក្បាល |
| ឧបាសិកា ស្វូរីឡា ព្រមទាំងបុត្រ | | ៣២០០០៛+ ១០ ដុល្លារ |

## ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ឧបាសិកា មួង សុខុន | ព្រមទាំងបុត្រ | ១០ ដុល្លារ |
| ឧបាសិកា ខ្យង ប៉ុលា | និងកូន | ១០ ដុល្លារ |
| ឧបាសិកា ឌី គឹមសួ | ព្រទាំងកូនចៅ | ១០ ដុល្លារ |
| ឧបាសិកា ហ៊ុន សំអាត | ព្រមទាំងកូនចៅ | ១០ ដុល្លារ |
| ឧបាសិកា ស៊ួង ងី | | ៨ ដុល្លារ |
| លោក ឡេច ប៉េងសុងនិងភរិយា | | ៨ ដុល្លារ |
| ឧបាសិកា ហុង គឹមហ៊ួយ | | ៨ ដុល្លារ |
| ឧបាសិកា ឈន ឈឿន និងកញ្ញាវ៉ាត គឹម សាន | | ៨ ដុល្លារ |
| ទាយក ងិន វិសាល និងភរិយា | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ឧបាសិកា មាស លីដា និងស្វាមី | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ឧបាសិកា ភី ស្រី | | ៥ ដុល្លារ |
| ឧបាសិកា ហ៊ុល ថាវី ព្រមទាំងបុត្រ | | ៥ ដុល្លារ |
| ឧបាសិកា ឈាង វណ្ណា និងលោក ឃិ វង្សា | | ៥ដុល្លារ |
| ឧបាសិកា លង ឡេង ស៊ីម | | ៥ក្បាល |
| ឧបាសិក សោម សុខ និងឧបាសក គង់ សុលី | | ៥ដុល្លារ |
| ឧបាសិកា លី សារ៉េត | | ៥ ដុល្លារ |
| ឧបាសក ឡៃ ស៊ុយ ហ៊ រ និងឧបាសិកា លី គាន លាន | | ៥ ក្បាល |
| ឧបាសិកា មាស ចំរើន | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ឧបាសិកាយុន វ៉ារី | | ៥ ដុល្លារ |
| លោក អ៊ុក ចន្ថា និងអ្នកស្រី ផុន ឆៃរិត | ព្រមទាំងបុត្រ | ១៥ ដុល្លារ |
| លោក ឈួន សុវត្ថា និងភរិយា | ព្រមទាំងបុត្រ | ៥ដុល្លារ |
| លោក នៅ សុន្ធា និងភរិយា | ព្រមទាំងបុត្រ | ៥ដុល្លារ |
| ឧបាសិកា ព្រាប សុខ | ព្រមទាំងកូនចៅ | ៥ ដុល្លារ |
| ឧបាសិកា គឹម លន | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ឧ.ស តែ លាង ស្រុននិងឧ.សិ គឹម ហ៊ាង | ព្រមទាំងបុត្រ | ៥ដុល្លារ |
| ឧបាសិកា សៀង អ៊ុត | | ៥ ដុល្លារ |
| នុត សារឿន | | ៥ដុល្លារ |
| បង តំ និង គ្រួសារ | | ៥ដុល្លារ |

## ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ឧបាសិកា ម៉ុក សំបូរ | ព្រមទាំបុត្រ | ៥ដុល្លារ |
| លោក វឿនចាន់សុខ និង អ្នកស្រីសង រ័ត្ន ថៃ | ព្រមទាំងបុត្រ | ៥ដុល្លារ |
| ឧបាសិកា ចានណារី | | ៥ដុល្លារ |
| លោក លឹម ប៊ុនថុង និង ភរិយា | ព្រមទាំងបុត្រ | ៥ដុល្លារ |
| ឧបាសិកា កែ វសេន | ព្រមទាំងកូននឹងចៅ | ៥ដុល្លារ |
| លោក ទេព ប៊ុន ឆាយ ភរិយា | ព្រមទាំងកូនចៅ | ៥ក្បាល |
| ឧបាសិកា នាង ផប និង ស្វាមី | ព្រមទាំងបុត្រ | ៥ក្បាល |
| ឧបាសិកា វ៉ា សួរស្តី | | ៥ដុល្លារ |
| ឧបាសិកា ហ៊ឹម លួស | | ៥ដុល្លារ |
| លោក ណៃហុកស៊ិន | | ៥ដុល្លារ |
| ឧបាសិកា គឹន លន | | ៥ដុល្លា |
| ឧបាសិកា រស់ សុ ខុន | | ៥ដុល្លារ |
| ទាយក អ៊ុំ ប៊ុន ហៃ និងឧបាសិកា ហួត សារឿន ព្រមទាំងបុត្រ | | ៥ ក្បាល |
| ឧបាសិកា ព្រាប សុខ | | ៥ ដុល្លារ |
| ឧបាសក តែ ណងស្រ៊ុ ន | | ៥ ដុល្លារ |
| ឧបាសិកា ប៊ូ ចាន់ណា | | ៥ ដុល្លារ |
| ឧបាសិកា ច ចាន់ តារា | | ៥ ដុល្លារ |
| លោក រដ្ឋ និង ភរិយា | | ៥ ដុល្លារ |
| ឧបាសិកា ណៃ សារឿត | | ៥ ដុល្លារ |
| ឧបាសិកា អ៊ុំ គឹមលី | | ៥ ដុល្លារ |
| ឧបាសិកា ហុង តុលា | | ៥ ដុល្លារ |
| ឧបាសិកា អឿរ សារុន | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| សាន សុជា | | ៥ ដុល្លារ |
| ឧបាសក ហង្ស ចំប៉ា និងឧបាសិកា ផាន់ គឹមងន់ | | ៥ ដុល្លារ |
| ឧបាសក អ៊ាប អ៊ីង ស៊ង និងឧបាសិកា យក់ យន់ | | ៥ ដុល្លារ |
| ឧបាសិកា លិម ថុង ឈីវ | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ឧបាសិកា ប៉ែង មូយ | | ៥ ដុល្លារ |

# ពុទ្ធប្បវត្តិកថាសង្ខេប

| | | |
|---|---|---|
| ឧ.ស.កងស៊ុន្ដា រ៉ុង និងភរិយា សេងសោភា | ព្រមទាំងបុត្រ | ៥ ដុល្លារ |
| ឧបាសិកា ថោង សុគណ | ព្រមទាំងកូនចៅ | ៥ ដុល្លារ |
| ឧបាសិកាគាំ ជា | ព្រមទាំងកូនចៅ | ៥ ក្បាល |
| ឧបាសិកាមើសេរី និងស្វាមី | ព្រមទាំងកូន | ៥ ដុល្លារ |
| ឧបាសិកា ណៃ សាវៀត | | ៥ ដុល្លារ |
| បាន ស្រី | | ៥ ដុល្លារ |
| ឧបាសិកា ម៉ា លុច | | ៥ ដុល្លារ |
| ឧបាសិកា ជិប វ៉ាត | | ៥ ដុល្លារ |
| ឧបាសិកា ទូច សារី | | ៥ ដុល្លារ |
| ឧបាសក ហ៊ួត នួន និងឧបាសិកា គឹម ហេង | | ៥ ដុល្លារ |
| អ្នកស្រី គី | | ៥ ដុល្លារ |
| លោក រង្សី និងភរិយា | | ៥ ដុល្លារ |
| លោក ប៉ាតា កឺ និងសេង ណិ | | ៥ ដុល្លារ |
